រាជរដ្ឋាភិបាលកម្ពុជា

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

# របាយការណ៍

## ស្តីពី

## ការវាយតម្លៃពាក់កណ្តាលអាណត្តិ
## កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
## ដំណាក់កាលទី២ (២០២១-២០៣០)

ខែសីហា ឆ្នាំ២០២៥

# មាតិកា


មាតិកា ........ i

បញ្ជីអក្សរកាត់ ........ ii

លិខិតថ្លែងអំណរគុណ ........ iii

សេចក្តីសង្ខេប ........ iv

១. សេចក្តីផ្តើម ........ 1

២. គោលបំណងនៃការវាយតម្លៃពាក់កណ្តាលអាណត្តិ កជទី២ ........ 3

៣. វិសាលភាពនៃការវាយតម្លៃពាក់កណ្តាលអាណត្តិ កជទី២ ........ 3

៤. វិធីសាស្ត្រនៃការវាយតម្លៃពាក់កណ្តាលអាណត្តិ កជទី២ ........ 4

៤.១. វិធីសាស្ត្រ និងឧបករណ៍វាយតម្លៃ ........ 4

៤.២. តំបន់គោលដៅ និងអ្នកផ្តល់ព័ត៌មាន ........ 5

៥. របកគំហើញនៃការវាយតម្លៃពាក់កណ្តាលអាណត្តិ កជទី២ ........ 6

៥.១. របកគំហើញពាក់ព័ន្ធនឹងក្របខណ្ឌលទ្ធផលនៃ កជទី២ ........ 6

៥.២. របកគំហើញពាក់ព័ន្ធនឹងការអនុវត្តកម្មវិធី ........ 11

៥.៣. របកគំហើញពាក់ព័ន្ធនឹងការគ្រប់គ្រង និងការកាត់បន្ថយហានិភ័យ ........ 36

៥.៤. របកគំហើញពាក់ព័ន្ធនឹងការអនុវត្តថវិកានៃកម្មវិធី ........ 36

៦. ការវិភាគ ........ 38

៦.១. ក្របខណ្ឌលទ្ធផល ........ 38

៦.២. ការអនុវត្តកម្មវិធី ........ 40

៦.៣. ការគ្រប់គ្រង និងការកាត់បន្ថយហានិភ័យ ........ 41

៦.៤. ការអនុវត្តថវិកា ........ 42

៧. អនុសាសន៍ ........ 43

៧.១. ឯកសារ កជទី២ ........ 43

៧.២. ការអនុវត្ត កជទី២ ........ 44

៧.៣. កិច្ចការជាអាទិភាពសម្រាប់ ផអ៥ទី២ ........ 48

៨. សេចក្តីសន្និដ្ឋាន ........ 49

# បញ្ជីអក្សរកាត់

| អក្សរកាត់ | ពាក្យពេញ |
| --- | --- |
| គ.ជ.អ.ប. | គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ |
| គ.ដ.វ.វ. | គណៈកម្មការដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ |
| កជទី១ | កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដំណាក់កាលទី១ (២០១០-២០២០) |
| កជទី២ | កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដំណាក់កាលទី២ (២០២១-២០៣០) |
| ផអ៣ | ផែនការអនុវត្តរយៈពេលបីឆ្នាំនៃ កជទី១ |
| ផអ៥ទី១ | ផែនការអនុវត្តរយៈពេលប្រាំឆ្នាំ ដំណាក់កាលទី១ (២០២១-២០២៥) នៃ កជទី២ |
| ផ.ស.ថ. | ផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ |
| គ.ក.ស.ក. | គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ |
| គ.ក.ន.ក. | គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ |
| SNIF | មូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ (Sub-National Investment Fund) |
| D&D | វិមជ្ឈការ និងវិសហមជ្ឈការ (Decentralization and Deconcentration) |

# លិខិតថ្លែងអំណរគុណ

ក្នុងនាម គ.ជ.អ.ប. ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) ប្រចាំកម្ពុជា និងរាជរដ្ឋាភិបាលជប៉ុន ដែលបានគាំទ្រ គ.ជ.អ.ប. ក្នុងការវាយតម្លៃពាក់កណ្តាលអាណត្តិនៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដំណាក់កាលទី២ (កជទី២) តាមរយៈគម្រោង **«ការពង្រឹងតម្លាភាព និងគណនេយ្យភាពក្នុងអភិបាលកិច្ចមូលដ្ឋានតាមរយៈការចូលរួមរបស់ប្រជាពលរដ្ឋ»** ដែលផ្តល់ហិរញ្ញប្បទានជំនួយឥតសំណងពីរាជរដ្ឋាភិបាលជប៉ុន តាមរយៈស្ថានទូតជប៉ុនប្រចាំកម្ពុជា និងហិរញ្ញប្បទានផ្ទាល់របស់ UNDP។

សូមថ្លែងអំណរគុណ និងវាយតម្លៃខ្ពស់ចំពោះក្រុមទីប្រឹក្សាវាយតម្លៃ និងក្រុមការងារពិគ្រោះយោបល់នៃគម្រោងការពង្រឹងតម្លាភាព និងគណនេយ្យភាពក្នុងអភិបាលកិច្ចមូលដ្ឋានតាមរយៈការចូលរួមរបស់ប្រជាពលរដ្ឋ ដែលបានចំណាយពេលវេលា ចំណេះដឹង និងជំនាញក្នុងការចូលរួមកិច្ចដំណើរការវាយតម្លៃពាក់កណ្តាលអាណត្តិនៃកជទី២នេះ ប្រកបដោយស្មារតីទទួលខុសត្រូវ និងក្រមសីលធម៌វិជ្ជាជីវៈខ្ពស់។

ខ្ញុំក៏សូមថ្លែងអំណរគុណចំពោះក្រុមការងារវិមជ្ឈការ និងវិសហមជ្ឈការនៃក្រសួង ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល ក្រុមប្រឹក្សា ថ្នាក់ដឹកនាំ និងមន្ត្រីនៃរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ និងថ្នាក់ដឹកនាំនៃមន្ទីរជំនាញនៅថ្នាក់រាជធានី ខេត្តដែលបានចំណាយពេលដ៏មានតម្លៃចូលរួមយ៉ាងសកម្មក្នុងការសម្ភាស ផ្តល់ព័ត៌មាន ទិន្នន័យ និងអនុសាសន៍នានាពាក់ព័ន្ធនឹងការអនុវត្តកជទី២រយៈពេល៥ឆ្នាំកន្លងមក (២០២១-២០២៥) ដែលញ៉ាំងឱ្យក្រុមទីប្រឹក្សាវាយតម្លៃទទួលបានព័ត៌មាន និងទិន្នន័យជាច្រើនសម្រាប់វិភាគ វាយតម្លៃ និងរៀបចំជារបាយការណ៍ស្តីពីការវាយតម្លៃពាក់កណ្តាលអាណត្តិនៃកជទី២ នេះឡើង។ របាយការណ៍នេះ បានបង្ហាញអំពីវឌ្ឍនភាពសំខាន់ៗ បញ្ហាប្រឈមជាគន្លឹះដែលបានជួបប្រទះក្នុងពេលអនុវត្ត កជទី២ និងអនុសាសន៍សំខាន់ៗសម្រាប់ពិចារណាក្នុងការរៀបចំផែនការអនុវត្តរយៈពេល៥ឆ្នាំ ដំណាក់កាលទី២ (ផអ៥ទី២) ដែលត្រូវបន្តអនុវត្តពីឆ្នាំ២០២៦ ដល់ឆ្នាំ២០៣០ ឱ្យកាន់តែឆ្លុះបញ្ចាំងទៅនឹងការវិវឌ្ឍជាក់ស្តែងក្នុងសង្គមកម្ពុជា និងកាន់តែមានប្រសិទ្ធភាពខ្ពស់ក្នុងការអនុវត្ត។

ក្នុងន័យនេះ ក្នុងនាម គ.ជ.អ.ប. ខ្ញុំសូមលើកទឹកចិត្តឱ្យក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ អ្នករៀបចំគោលនយោបាយ ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិលប្រើប្រាស់របាយការណ៍នេះ ដើម្បីស្វែងយល់អំពីស្ថានភាពនៃការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ និងសូមអំពាវនាវឱ្យបន្តចូលរួមគាំទ្រដល់ការរៀបចំ និងអនុវត្ត ផអ៥ទី២ នៃកជទី២ ឱ្យបានសម្រេចតាមគោលបំណងដែលបានរំពឹងទុក។

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

និងជាប្រធាន គ.ជ.អ.ប.

អភិសន្តិបណ្ឌិត ស សុខា

# សេចក្តីសង្ខេប

កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ រយៈពេល១០ឆ្នាំ ដំណាក់កាលទី២ (កជទី២) ដែលត្រូវអនុវត្តពីឆ្នាំ២០២១ ដល់ឆ្នាំ២០៣០ បានរៀបចំឡើងក្នុងគោលបំណង លើកកម្ពស់ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន ស្របតាមគោលការណ៍នៃការអភិវឌ្ឍតាម បែបប្រជាធិបតេយ្យ បរិយាបន្ន សមធម៌សង្គម និងយុត្តិធម៌ តាមរយៈការរៀបចំរចនាសម្ព័ន្ធ និងប្រព័ន្ធ អភិបាលកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិឱ្យមានលក្ខណៈទំនើប មានស្វ័យភាព ប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាពក្នុងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន ឆ្លើយតបទៅនឹងតម្រូវការរបស់ ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ។

ដើម្បីឈានទៅដល់ការសម្រេចបានតាមគោលបំណងនេះ កជទី២ បានកំណត់សមាសភាគចំនួន៥ ដែលត្រូវអនុវត្ត គឺ (១). ការដឹកនាំ ការសម្របសម្រួលការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ (២). រចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ (៣). ការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធាន មនុស្ស (៤). វិមជ្ឈការហិរញ្ញវត្ថុ ប្រព័ន្ធផែនការ និងថវិការដ្ឋបាលថ្នាក់ក្រោមជាតិ និង(៥). ការផ្តល់សេវា សាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន។

ការអនុវត្ត កជទី២ បានបែងចែកជាពីរដំណាក់កាលដែលដំណាក់កាលនីមួយៗមានរយៈពេល ៥ឆ្នាំ គឺផែនការអនុវត្តរយៈពេល៥ឆ្នាំ ដំណាក់កាលទី១ (ផអ៥ទី១) ដែលត្រូវអនុវត្តពីឆ្នាំ២០២១ ដល់ ឆ្នាំ២០២៥ និងផែនការអនុវត្តរយៈពេល៥ឆ្នាំ ដំណាក់កាលទី២ (ផអ៥ទី២) ដែលត្រូវអនុវត្តពីឆ្នាំ២០២៦ ដល់ឆ្នាំ២០៣០។ ក្នុងឆ្នាំនីមួយៗ កជទី២ បានអនុវត្តតាមផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ (ផ.ស.ថ.) របស់ គ.ជ.អ.ប. ដែលតម្រូវឱ្យមានការចូលរួមរៀបចំ និងអនុវត្តដោយក្រសួង ស្ថាប័នពាក់ព័ន្ធនៅថ្នាក់ជាតិ រដ្ឋបាលថ្នាក់ក្រោមជាតិ ឬហៅថាស្ថាប័នអនុវត្ត កជទី២ និងដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធនានា។

ការគ្រប់គ្រង និងការអនុវត្ត កជទី២ ស្ថិតក្រោមការដឹកនាំ និងសម្របសម្រួលរបស់ គ.ជ.អ.ប. ដោយមានលេខាធិការដ្ឋាន គ.ជ.អ.ប. ជាសេនាធិការដែលមានភារកិច្ចចាត់ចែង សម្របសម្រួលការងារ ប្រចាំថ្ងៃ និងធ្វើសេចក្តីរាយការណ៍ជាប្រចាំជូន គ.ជ.អ.ប.។

ការវាយតម្លៃពាក់កណ្តាលអាណត្តិ កជទី២ គឺជាសកម្មភាពមួយដែលបានកំណត់ក្នុងជំពូកទី៤ ស្តីពីការគ្រប់គ្រង និងការអនុវត្តកម្មវិធីនៃឯកសារ កជទី២ និងគ្រោងអនុវត្តនៅក្នុងឆ្នាំទី៥ នៃ កជទី២ ឬ ក្នុងឆ្នាំចុងក្រោយនៃ ផអ៥ទី១។ ការវាយតម្លៃនេះ មានគោលបំណងសិក្សាវាយតម្លៃអំពីវឌ្ឍនភាព បញ្ហា ប្រឈម និងហានិភ័យនៃការអនុវត្ត កជទី២ ធៀបនឹងក្របខណ្ឌលទ្ធផលដែលបានកំណត់។ លទ្ធផល នៃការវាយតម្លៃពាក់កណ្តាលអាណត្តិនេះ នឹងធ្វើជាមូលដ្ឋានសម្រាប់ការរៀបចំតាក់តែង ផអ៥ទី២ ដែល ត្រូវអនុវត្តពីឆ្នាំ២០២៦ ដល់ឆ្នាំ២០៣០។

ការវាយតម្លៃពាក់កណ្ដាលអាណត្តិបានអនុវត្តចាប់ពីខែមីនា ដល់ខែកក្កដា ឆ្នាំ២០២៥ ក្រោមការសម្របសម្រួលរបស់ក្រុមការងារពិគ្រោះយោបល់មួយដែលដឹកនាំដោយលេខាធិការដ្ឋាន គ.ជ.អ.ប. និងមានការគាំទ្របច្ចេកទេស និងថវិកាពីគម្រោង "**ការពង្រឹងតម្លាភាព និងគណនេយ្យភាពក្នុងអភិបាលកិច្ចមូលដ្ឋានតាមរយៈការចូលរួមរបស់ប្រជាពលរដ្ឋ**" ក្រោមជំនួយហិរញ្ញប្បទានឥតសំណងរបស់រាជរដ្ឋាភិបាលជប៉ុន និងកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) ប្រចាំកម្ពុជា។

ការវាយតម្លៃនេះ បានធ្វើឡើងតាមរយៈការប្រមូល ការសិក្សាស្រាវជ្រាវលើឯកសារនានាដែលពាក់ព័ន្ធនឹងការអនុវត្ត កជទី២ ការប្រមូលទស្សនៈយល់ឃើញជាលក្ខណៈបុគ្គល និងការពិភាក្សាជាមួយក្រុមអ្នកផ្ដល់ព័ត៌មាននានាដែលជាអ្នកចូលរួមអនុវត្តផ្ទាល់ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ រួមមានតំណាងក្រសួង ស្ថាប័នសំខាន់ៗចំនួន១៥ រដ្ឋបាលខេត្តចំនួន៦ មន្ទីរជំនាញថ្នាក់ខេត្ត រដ្ឋបាលក្រុង ស្រុកចំនួន១២ និងរដ្ឋបាលឃុំ សង្កាត់ចំនួន២៤ ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និងភាគីពាក់ព័ន្ធផ្សេងទៀតដែលមានអ្នកចូលរួមសរុបចំនួន **១.២៧៥នាក់** ក្នុងនោះមានស្ត្រីចំនួន**២៨**%។

ជារួម ក្នុងរយៈពេល៥ឆ្នាំកន្លងមកនេះ ទោះបីការអនុវត្ត កជទី២ បានជួបវិបត្តិរីករាលដាលនៃជំងឺកូវីដ-១៩ក៏ដោយ ក៏ការអនុវត្ត កជទី២ បានដំណើរការយ៉ាងសកម្មក្រោមការដឹកនាំ សម្របសម្រួលរបស់ គ.ជ.អ.ប. ដោយមានកិច្ចសហការ និងការចូលរួមពីបណ្ដាក្រសួង ស្ថាប័នពាក់ព័ន្ធនៅថ្នាក់ជាតិ រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល វិស័យឯកជន និងភាគីពាក់ព័ន្ធនានា។ សកម្មភាពជាអាទិភាពចំនួន**៩០** ស្មើនឹង**៨០**% នៃសកម្មភាពជាអាទិភាពសរុបចំនួន**១១២** ត្រូវបានអនុវត្តក្នុងនោះសកម្មភាពជាអាទិភាពចំនួន**២៧** ស្មើនឹង**២៤**% បានអនុវត្តបញ្ចប់**១០០**% តាមផែនការកំណត់។ សូចនាករចំនួន**១២៧** ស្មើនឹង**៧៧**% នៃសូចនាករសរុបចំនួន**១៦៥** ត្រូវបានអនុវត្ត ក្នុងនោះសូចនាករចំនួន**៣៨** ស្មើនឹង**២៣**% បានសម្រេច**១០០**% តាមការគ្រោងទុក។

លទ្ធផលសំខាន់ៗដែលសម្រេចបានតាមសមាសភាគនីមួយៗមានសង្ខេបដូចខាងក្រោម៖

## ក. ក្របខណ្ឌលទ្ធផល

ឯកសារ កជទី២ បានរៀបចំតាមឋានានុក្រមនៃលទ្ធផល (តក្កភាពនៃលទ្ធផល) គឺមានន័យថាសកម្មភាពជាអាទិភាព និងលទ្ធផលរំពឹងទុកមានភាពប្រទាក់ក្រឡាគ្នា និងមានទំនាក់ទំនងគ្នាទៅវិញទៅមក ពោលគឺ បើការអនុវត្តដោយជោគជ័យនូវសកម្មភាពជាអាទិភាព នោះនឹងឈានទៅសម្រេចបាននូវលទ្ធផលរំពឹងទុក ការសម្រេចបានដោយជោគជ័យនូវលទ្ធផលរំពឹងទុក នោះនឹងឈានទៅសម្រេចបានសមិទ្ធផល ការសម្រេចបានដោយជោគជ័យនូវសមិទ្ធផល នោះនឹងឈានទៅសម្រេចបាននូវគោលដៅ គោលបំណង និងចក្ខុវិស័យ។ ដើម្បីសម្រេចសមិទ្ធផល គោលដៅ និងគោលបំណងនៃ កជទី២ ផអ៥ទី១ បានកំណត់លទ្ធផលរំពឹងទុកចំនួន**៣៧** សកម្មភាពជាអាទិភាពចំនួន**១១២** និងសូចនាករចំនួន១៦៥។

## ខ. ក្របខណ្ឌនៃការអនុវត្តកម្មវិធី

### សមាសភាគទី១ ៖ ការដឹកនាំ និងការសម្របសម្រួលការងារកំណែទម្រង់

សកម្មភាពចំនួន**២៣** ស្មើនឹង**៩៦**% បានអនុវត្ត ក្នុងនោះមានសកម្មភាពចំនួន**១៣** ស្មើនឹង**៥៤**% បានអនុវត្តចប់ជាស្ថាពរតាមការគ្រោងទុក។ សូចនាករចំនួន**៣២** ក្នុងចំណោមសូចនាករសរុបចំនួន**៣៣** ស្មើនឹង**៩៧**% បានអនុវត្ត ក្នុងនោះសូចនាករចំនួន**១៩** ស្មើនឹង**៥៨**% បានសម្រេចជាស្ថាពរ។ សកម្មភាពជាអាទិភាពសំខាន់ៗដែលបានអនុវត្ត រួមមាន៖

- គ.ជ.អ.ប. បានបន្តពង្រឹងការអនុវត្ត កជទី២ ឱ្យមានដំណើរការដោយរលូន ដោយមានក្រសួង ស្ថាប័នពាក់ព័ន្ធចំនួន២២ និងរដ្ឋបាលថ្នាក់ក្រោមជាតិទូទាំងប្រទេសចូលរួមគាំទ្រ និងអនុវត្ត។ កិច្ចប្រជុំ គ.ជ.អ.ប. បានរៀបចំតាមការកំណត់ គឺបានប្រជុំ២ដងក្នុងមួយឆ្នាំ ដើម្បីពិនិត្យលើវឌ្ឍនភាព បញ្ហាប្រឈម ការពិភាក្សាលើសេចក្តីព្រាងគោលនយោបាយ ច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងគោលការណ៍ណែនាំពាក់ព័ន្ធនានា
- គោលនយោបាយ ច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងសៀវភៅណែនាំជាង២៥០ ពាក់ព័ន្ធនឹងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្តពីឆ្នាំ២០២១ ដល់ឆ្នាំ២០២៥
- វេទិការវាងរាជរដ្ឋាភិបាល និងរដ្ឋបាលថ្នាក់ក្រោមជាតិស្តីពី **កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដើម្បីចូលរួមសម្រេចបានចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០** ដែលជាគំនិតផ្តួចផ្តើមរបស់ **សម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានរៀបចំដោយជោគជ័យ នាថ្ងៃទី៨ ខែមីនា ឆ្នាំ២០២៥ ដោយមានអ្នកចូលរួមផ្ទាល់ប្រមាណជាង ១.៤០០ នាក់ និងអ្នកចូលរួមតាមប្រព័ន្ធអនឡាញ (ZOOM) ប្រមាណជាង ១០.០០០នាក់។ វេទិកានេះ ជាព្រឹត្តិការណ៍ដ៏សំខាន់នៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការដែលបានរៀបចំឡើងក្នុងគោលបំណង រួមគ្នាវាយតម្លៃវឌ្ឍនភាព បញ្ហាប្រឈម និងការតម្រង់ទិសផ្នែកគោលនយោបាយ ដើម្បីសម្រួចការអនុវត្តកំណែទម្រង់នេះឱ្យកាន់តែស៊ីជម្រៅ សំដៅចូលរួមអនុវត្តកម្មវិធីនយោបាយ វិធានការគន្លឹះ និងយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ របស់រាជរដ្ឋាភិបាលនីតិកាលទី៧
- ក្រសួង ស្ថាប័នពាក់ព័ន្ធនៅថ្នាក់ជាតិចំនួន២២ និងរដ្ឋបាលថ្នាក់ក្រោមជាតិទាំងអស់តំណាងដោយរដ្ឋបាលរាជធានី ខេត្តទាំង២៥ បានចូលរួមអនុវត្តផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់ គ.ជ.អ.ប. ដោយបានវិភាជថវិការបស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិសាមីសម្រាប់គាំទ្រដល់ការអនុវត្តសកម្មភាពស្នូលក្នុងដែនសមត្ថកិច្ចរបស់ខ្លួនដែលបានកំណត់ក្នុងផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់ គ.ជ.អ.ប. ដែលមានថវិកាសរុបចំនួនជាមធ្យមពី៥-៦លានដុល្លារអាមេរិកក្នុងមួយឆ្នាំ។ ប្រការនេះ បានបង្ហាញអំពីការលើកកម្ពស់

ភាពម្ចាស់ការ និងការទទួលខុសត្រូវខ្ពស់របស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការចូលរួមគាំទ្រដល់ការអនុវត្ត កជទី២ ឬកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

- ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ និងអង្គការសង្គមស៊ីវិលនានា និងសាធារណជន កាន់តែមានការយល់ដឹងអំពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ថាជាគោលនយោបាយកំណែទម្រង់ដ៏សំខាន់របស់រាជរដ្ឋាភិបាល គឺមិនមែនជាកម្មវិធី ឬគម្រោងរបស់ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិលណាមួយនោះឡើយ
- សមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិបានបន្តដំណើរការយ៉ាងសកម្មក្នុងការអភិវឌ្ឍសមត្ថភាព និងគាំទ្រសមាជិករបស់ខ្លួនដែលជាក្រុមប្រឹក្សាថ្នាក់ក្រោមជាតិក្នុងការពង្រឹងការអនុវត្តសិទ្ធិអំណាច តួនាទី និងភារកិច្ចស្របច្បាប់របស់ខ្លួនឱ្យកាន់តែមានប្រសិទ្ធភាព
- លេខាធិការដ្ឋាន គ.ជ.អ.ប. ក៏បានដើរតួនាទីជាសេនាធិការជូន គ.ជ.អ.ប. យ៉ាងសកម្មក្នុងការគ្រប់គ្រង ចាត់ចែងការងារប្រចាំថ្ងៃ និងសម្របសម្រួលជាមួយដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល ដើម្បីកៀរគរការចូលរួម និងគាំទ្រការអនុវត្ត កជទី២
- ក្រៅពីការសម្របសម្រួល តាមដាន ត្រួតពិនិត្យលើការរៀបចំ និងអនុវត្តផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់ គ.ជ.អ.ប. លេខាធិការដ្ឋាន គ.ជ.អ.ប. ក្នុងនាមជាប្រធានប្តូរវេន បានចូលរួមដឹកនាំយន្តការសម្របសម្រួល កម្រិតបច្ចេកទេសនៃកំណែទម្រង់គន្លឹះទាំង៥ ជាអាទិ៍ កំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កំណែទម្រង់រដ្ឋបាលសាធារណៈ កំណែទម្រង់ច្បាប់ និងកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ ដើម្បីធានាឱ្យការរៀបចំ និងការអនុវត្តសកម្មភាពនានានៃកម្មវិធីកំណែទម្រង់គន្លឹះទាំងនេះមានភាពស៊ីសង្វាក់ ប្រទាក់ក្រឡាគ្នា គាំទ្រ និងបំពេញឱ្យគ្នាទៅវិញទៅមក
- ដោយមានការគាំទ្រពី UNDP គ.ជ.អ.ប. សហការជាមួយក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និងវិស័យឯកជនបានរៀបចំការវាយតម្លៃនានា រួមមាន (១). ការវាយតម្លៃកម្មវិធីជាតិ ដំណាក់កាលទី១ (២). ការអង្កេតអភិបាលកិច្ចដើម្បីបង្កើតសន្ទស្សន៍ដើមគ្រាផ្នែកអភិបាលកិច្ច សន្ទស្សន៍ដើមគ្រានៃការផ្តល់សេវា និងសន្ទស្សន៍ដើមគ្រាសមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិ និង(៣). ការវាយតម្លៃពាក់កណ្តាលអាណត្តិនៃកម្មវិធីជាតិដំណាក់កាលទី២។

## សមាសភាគទី២ ៖ រចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ

សកម្មភាពចំនួន**១៩** ស្មើនឹង**៧៦**% ត្រូវបានអនុវត្ត ក្នុងនោះមានសកម្មភាពចំនួន**២** ស្មើនឹង**៨**% ត្រូវបានអនុវត្តចប់ជាស្ថាពរតាមផែនការកំណត់។ សូចនាករចំនួន**២៨** ក្នុងចំណោមសូចនាករសរុបចំនួន**៣៨** ស្មើនឹង**៧៤**% ត្រូវបានអនុវត្ត ក្នុងនោះសូចនាករចំនួន**២** ស្មើនឹង**៥**% ត្រូវបានសម្រេចតាមផែនការគ្រោងទុក។ សកម្មភាពសំខាន់ៗដែលបានអនុវត្ត រួមមាន៖

- រដ្ឋបាលក្រុង ស្រុក ខណ្ឌបានខិតខំបំពេញការងារតាមមុខងារ និងរចនាសម្ព័ន្ធថ្មីរបស់ខ្លួន ដែលបានរៀបចំឡើងវិញនាចុងឆ្នាំ២០១៩ និងដើមឆ្នាំ២០២០។ ក្រុមប្រឹក្សា គណៈអភិបាល និងមន្ត្រីនៃរដ្ឋបាលក្រុង ស្រុក បានបង្ហាញពីភាពពេញចិត្តចំពោះមុខងារ និងរចនាសម្ព័ន្ធថ្មី របស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ
- ការគ្រប់គ្រងការអនុវត្តមុខងារអប់រំ យុវជន និងកីឡារបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌមាន ដំណើរការកាន់តែល្អប្រសើរ។ ការប្រើប្រាស់ថវិកាមានភ្ជាប់លក្ខខណ្ឌរបស់ការិយាល័យអប់រំ យុវជន និងកីឡា និងថវិកាដំណើរការគ្រឹះស្ថានសិក្សានានាបានផ្ទេរទាន់ពេលវេលា និងបាន ប្រើប្រាស់ស្របតាមលក្ខខណ្ឌដែលបានកំណត់
- ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិបង្ហាញភាពពេញចិត្តចំពោះការរៀបចំរដ្ឋបាលក្រុង ស្រុកឱ្យក្លាយជារដ្ឋបាលមូលដ្ឋានដែលមានសិទ្ធិអំណាច និងការទទួលខុសត្រូវទាំងការងារ រដ្ឋបាលដែនដី និងការងារវិស័យជំនាញនានាក្នុងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍ មូលដ្ឋានជូនប្រជាពលរដ្ឋ
- ក្រុមប្រឹក្សា និងគណៈអភិបាលរាជធានី ខេត្តបានផ្តោតការយកចិត្តទុកដាក់ក្នុងការជំរុញ តាមដាន ត្រួតពិនិត្យការផ្តល់សេវានៅតាមមន្ទីរពេទ្យ និងមណ្ឌលសុខភាព តាមរយៈកិច្ចប្រជុំ ក្រុមប្រឹក្សាប្រចាំខែ និងការចុះត្រួតពិនិត្យជាក់ស្តែង។ ប្រការនេះបានចូលរួមធ្វើឱ្យមានការ ប្រែប្រួលជាវិជ្ជមានចំពោះប្រសិទ្ធភាពនៃការផ្តល់សេវាសុខាភិបាលនៅតាមមន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាព។ ប្រជាពលរដ្ឋមកទទួលសេវានៅមណ្ឌលសុខភាព និងមន្ទីរពេទ្យបង្អែក កាន់តែច្រើនឡើង។ មណ្ឌលសុខភាពបានរៀបចំបុគ្គលិកប្រចាំការ ២៤ម៉ោងក្នុង១ថ្ងៃ។ អាកប្បកិរិយារបស់បុគ្គលិកពេទ្យមានភាពរួសរាយរាក់ទាក់ និងមានក្រមសីលធម៌វិជ្ជាជីវៈ
- លេខាធិការដ្ឋាន គ.ជ.អ.ប. បាននិងកំពុងសិក្សា និងចងក្រងឯកសារស្តីពីមេរៀនបទពិសោធន៍ ពីបណ្តាប្រទេសនានាក្នុងតំបន់ និងក្រៅតំបន់ និងកំពុងចុះសិក្សាអំពីស្ថានភាពជាក់ស្តែងនៅ រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីកំណត់ជម្រើសនានាសម្រាប់រៀបចំរដ្ឋបាលរាជធានីឱ្យទៅជា រដ្ឋបាលទីក្រុងមេត្រូប៉ូលីតែន និងរដ្ឋបាលខេត្តឱ្យទៅជារដ្ឋបាលតំបន់ (ខេត្ត)
- ការផ្តល់សេវារដ្ឋបាលតាមយន្តការច្រកចេញចូលតែមួយនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបាន ពង្រឹង និងកែលម្អនីតិវិធីផ្តល់សេវាឱ្យកាន់តែមានលក្ខណៈងាយស្រួល ឆាប់រហ័ស តម្លាភាព និងគណនេយ្យភាព ជាពិសេសនៅថ្នាក់រាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌមួយចំនួនបានធ្វើ ទំនើបកម្មប្រព័ន្ធ និងនីតិវិធីផ្តល់សេវារដ្ឋបាល និងការទូទាត់ថ្លៃសេវារដ្ឋបាលក្នុងវិស័យមួយ ចំនួនតាមប្រព័ន្ធអនឡាញ។ ការអង្កេតអភិបាលកិច្ចក្នុងឆ្នាំ២០២៤ បានបង្ហាញថា សន្ទស្សន៍ នៃភាពពេញចិត្តរបស់ប្រជាពលរដ្ឋចំពោះការផ្តល់សេវារដ្ឋបាលតាមយន្តការច្រកចេញចូល តែមួយមានតម្លៃ០,៦៧ ក្នុងចំណាត់ថ្នាក់ល្អបង្គួរ។

- ការងារគណនេយ្យភាពសង្គម ត្រូវបានពង្រីក និងអនុវត្តក្នុងឃុំ សង្កាត់គោលដៅចំនួន៩៤% នៃចំនួនឃុំ សង្កាត់សរុបទូទាំងប្រទេស។ លទ្ធផលនៃការវាយតម្លៃនាខែចុងឆ្នាំ២០២៤ បង្ហាញឱ្យដឹងថា**៩២**% នៃប្រជាពលរដ្ឋពេញចិត្ត និងបានចូលរួមយ៉ាងសកម្មក្នុងការលើកកម្ពស់ការបំពេញការងារ ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានដែលផ្តល់ដោយអង្គភាពផ្តល់សេវាទាំង៣ គឺរដ្ឋបាលឃុំ សង្កាត់ មណ្ឌលសុខភាព និងសាលាបឋមសិក្សា។

**សមាសភាគទី៣ ៖ ការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានមនុស្ស**

សកម្មភាពចំនួន**២៣** ស្មើនឹង**៧៤**% ត្រូវបានអនុវត្ត ក្នុងនោះមានសកម្មភាពចំនួន**៣** ស្មើនឹង**១០**% ត្រូវបានអនុវត្តចប់ជាស្ថាពរតាមផែនការ។ សូចនាករចំនួន**៣១** ក្នុងចំណោមសូចនាករសរុបចំនួន**៤៥** ស្មើនឹង**៦៩**% ត្រូវបានអនុវត្ត ក្នុងនោះសូចនាករចំនួន៤ ស្មើនឹង៩% ត្រូវបានអនុវត្តចប់ជាស្ថាពរតាមផែនការគ្រោងទុក។ លទ្ធផលសំខាន់ៗដែលសម្រេចបានក្នុងសមាសភាគទី៣ រួមមាន៖

- សេចក្តីណែនាំស្តីពីគោលការណ៍ និងនីតិវិធីសម្រាប់គ្រប់គ្រងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានរៀបចំបណ្តុះបណ្តាល។ អនុក្រឹត្យស្តីពីការកំណត់មុខតំណែងវិជ្ជាជីវៈ និងការពិពណ៌នាមុខតំណែងនានាក្នុងរចនាសម្ព័ន្ធរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌត្រូវដាក់ចេញ និងសេចក្តីណែនាំស្តីពីការប្រើប្រាស់ការពិពណ៌នាមុខតំណែងនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌបានរៀបចំផងដែរ
- ព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានធ្វើវិសោធនកម្ម ដើម្បីបើកផ្លូវឱ្យការតែងតាំងនាយកគ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ និងនាយកគ្រឹះស្ថានបឋមសិក្សាសាធារណៈត្រូវធ្វើឡើងដោយដីការបស់អភិបាលរាជធានី ខេត្ត
- អនុក្រឹត្យស្តីពីគោលការណ៍ និងនីតិវិធីនៃការតែងតាំង ការផ្លាស់ប្តូរ និងការបញ្ចប់មុខតំណែងនាយកគ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ និងនាយកគ្រឹះស្ថានបឋមសិក្សាសាធារណៈ និងនិយាមនីតិវិធីប្រតិបត្តិសម្រាប់តែងតាំង ផ្លាស់ប្តូរ និងបញ្ចប់មុខតំណែងនាយកគ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ និងនាយកគ្រឹះស្ថានបឋមសិក្សាសាធារណៈត្រូវបានរៀបចំ និងផ្សព្វផ្សាយដាក់ឱ្យអនុវត្តនៅដើមឆ្នាំ២០២៥
- រដ្ឋបាលថ្នាក់ក្រោមជាតិយល់ដឹងយ៉ាងទូលំទូលាយអំពីសមភាពយេនឌ័រ បរិយាបន្ន និងសមធម៌សង្គម។ រាល់ការតែងតាំង ឬផ្លាស់ប្តូរមុខតំណែងនានា តែងតែមានការប្រឹក្សាយោបល់ និងការចូលរួមពីប្រធាន គ.ក.ស.ក./ គ.ក.ន.ក. និងអភិបាលរងជាស្ត្រីក្នុងការពិចារណា និងគិតគូរពីបេក្ខភាពជាស្ត្រី។ ស្ត្រីកាន់មុខតំណែងគ្រប់គ្រងនៅថ្នាក់ក្រុង ស្រុក ខណ្ឌក្នុងឆ្នាំ២០២៤ មានចំនួន**២៣,០៧**% និងថ្នាក់រាជធានី ខេត្តមានចំនួន**២៧,៤៦**%
- ជារៀងរាល់ឆ្នាំ រដ្ឋបាលរាជធានី ខេត្តបានរៀបចំ និងអនុវត្តផែនការអភិវឌ្ឍន៍សមត្ថភាពសម្រាប់បុគ្គលិករបស់ខ្លួន និងបុគ្គលិកនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ផ្អែកលើការវាយតម្លៃ

អំពីតម្រូវការសមត្ថភាពដែលបានណែនាំ និងបណ្តុះបណ្តាលដោយសាលាជាតិរដ្ឋបាលមូលដ្ឋាន។ ជាមធ្យម រដ្ឋបាលរាជធានី ខេត្តបានអនុវត្តសកម្មភាពអភិវឌ្ឍសមត្ថភាពចំនួនជាង **២០០វគ្គ**ក្នុងមួយឆ្នាំ ដែលមានសិក្ខាកាមចូលរួមចំនួនជាង **៦.៧០០នាក់**

- សាលាជាតិរដ្ឋបាលមូលដ្ឋានបានដំណើរការយ៉ាងសកម្មក្នុងការអភិវឌ្ឍសមត្ថភាពដល់មន្ត្រីរាជការនៃរដ្ឋបាលថ្នាក់ក្រោមជាតិដោយសហការជិតស្និទ្ធជាមួយក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍន៍ និងភាគីពាក់ព័ន្ធនានា។ ជាមធ្យម សាលាបានអនុវត្តសកម្មភាពអភិវឌ្ឍសមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិចំនួន **៣៥វគ្គ**ក្នុងមួយឆ្នាំ ដែលមានសិក្ខាមចំនួនជាង **១.៥០០នាក់**។

### សមាសភាគទី៤ ៖ វិមជ្ឈការហិរញ្ញវត្ថុ ប្រព័ន្ធផែនការ និងថវិការដ្ឋបាលថ្នាក់ក្រោមជាតិ

សកម្មភាពចំនួន**១៥** ស្មើនឹង**៦៨**% បានអនុវត្ត ក្នុងនោះសកម្មភាពចំនួន**៩** ស្មើនឹង**៤១**% បានអនុវត្តចប់ជាស្ថាពរតាមផែនការ។ សូចនាករចំនួន**២៤** ក្នុងចំណោមសូចនាករសរុបចំនួន**៣៦** ស្មើនឹង**៦៧**% បានអនុវត្ត ក្នុងនោះសូចនាករចំនួន**១៣** ស្មើនឹង**៣៦**% ត្រូវបានអនុវត្តចប់ជាស្ថាពរតាមផែនការ។ សកម្មភាពសំខាន់ៗដែលបានអនុវត្ត រួមមាន៖

- ការរៀបចំគម្រោងថវិកាប្រចាំឆ្នាំមានភាពស៊ីសង្វាក់ជាមួយដំណើរការកសាងផែនការ។ ប្រការនេះ បានធ្វើឱ្យគម្រោងថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិឆ្លើយតបទៅនឹងគម្រោង សកម្មភាពជាអាទិភាពនានាដែលបានកំណត់នៅក្នុងកម្មវិធីវិនិយោគបីឆ្នាំរំកិលបានទាន់ពេលវេលា
- ការរៀបចំ និងអនុវត្តថវិកានិងមូលនិធិនៃរដ្ឋបាលថ្នាក់ក្រោមជាតិបានដំណើរការប្រកបដោយប្រសិទ្ធភាពតាមប្រព័ន្ធអនឡាញ FMIS
- រដ្ឋបាលរាជធានី ខេត្តទាំង២៥ បាននិងកំពុងប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ (SARMIS) ដែលបានដាក់ឱ្យអនុវត្តចាប់ពីឆ្នាំ២០២១
- ក្នុងអំឡុងពេលនៃការអនុវត្ត កជទី២ នេះ ជារួម ថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិមានការកើនឡើងគួរឱ្យកត់សម្គាល់ក្នុងនោះ៖
  - ថវិការដ្ឋបាលថ្នាក់ក្រោមជាតិទាំង ៣កម្រិតនៅឆ្នាំ២០២១ មានចំនួន **៨៥៨លានដុល្លារអាមេរិក** កើនដល់ចំនួន **១.៧៩០លានដុល្លារអាមេរិក**នៅឆ្នាំ២០២៥
  - ថវិការដ្ឋបាលរាជធានី ខេត្តនៅឆ្នាំ២០២១ មានចំនួន **៥៤៤លានដុល្លារអាមេរិក** កើនដល់ចំនួន **៨៦៧លានដុល្លារអាមេរិក**ក្នុងឆ្នាំ២០២៥
  - ថវិការដ្ឋបាលក្រុង ស្រុកនៅឆ្នាំ២០២១ មានចំនួន **១២៩លានដុល្លារអាមេរិក** កើនដល់ចំនួន **៥៨០លានដុល្លារអាមេរិក**ក្នុងឆ្នាំ២០២៥ ដោយបានធ្វើឱ្យរដ្ឋបាលក្រុង ស្រុកនីមួយៗ មានថវិកាជាមធ្យមប្រមាណ **២៧ម៉ឺនដុល្លារអាមេរិក**សម្រាប់ការអភិវឌ្ឍមូលដ្ឋាន

- ថវិកាសរុបរបស់រដ្ឋបាលឃុំ សង្កាត់នៅឆ្នាំ២០២១ មានចំនួន **១៨៤លានដុល្លារអាមេរិក** កើនដល់ចំនួន **៣៨៣លានដុល្លារអាមេរិក**ក្នុងឆ្នាំ២០២៥នេះ បានធ្វើឱ្យរដ្ឋបាលឃុំ សង្កាត់នីមួយៗមានថវិកាជាមធ្យមប្រមាណ **១១ម៉ឺនដុល្លារអាមេរិក**សម្រាប់ការអភិវឌ្ឍមូលដ្ឋាន។

– មូលនិធិមានភ្ជាប់លក្ខខណ្ឌសម្រាប់មុខងារវិស័យអប់រំ យុវជន និងកីឡា និងមូលនិធិមានភ្ជាប់លក្ខខណ្ឌសម្រាប់មុខងារវិស័យសុខាភិបាលត្រូវបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក និងរាជធានី ខេត្តនីមួយៗតាមពេលវេលាដែលបានកំណត់ និងបានអនុវត្តប្រកបដោយប្រសិទ្ធភាព

– រដ្ឋបាលថ្នាក់ក្រោមជាតិទាំង៣កម្រិត បានវិភាជថវិកាសម្រាប់អនុវត្តសកម្មភាពផ្តល់សេវាសង្គម និងអនាម័យបរិស្ថាន។ ប្រការនេះ ជាការវិវឌ្ឍប្រកបដោយវិជ្ជមានក្នុងការធានារដ្ឋបាលថ្នាក់ក្រោមជាតិបានប្រើប្រាស់ធនធានសាធារណៈប្រកបដោយបរិយាបន្ន និងសមធម៌សង្គម។

**សមាសភាគទី៥ ៖ ការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋាន**

សកម្មភាពចំនួន**១០** ស្មើនឹង**១០០%** ត្រូវបានអនុវត្ត។ សូចនាករចំនួន**១២** ក្នុងចំណោមសូចនាករចំនួន**១៣** ស្មើនឹង**៩២%** ត្រូវបានអនុវត្ត។ លទ្ធផល និងសកម្មភាពសំខាន់ៗដែលបានអនុវត្ត រួមមាន៖

– សេចក្តីណែនាំបច្ចេកទេសសម្រាប់អនុវត្តមុខងារដែលបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្តសម្រាប់វិស័យចំនួន**០៨** រួមមាន វិស័យសាធារណការ សង្គមកិច្ច ឧស្សាហកម្ម រ៉ែនិងថាមពល ទេសចរណ៍ គ្រប់គ្រងដែនដី វប្បធម៌ និងវិស័យអប់រំ

– រដ្ឋបាលក្រុង ស្រុកខិតខំទទួលខុសត្រូវលើអនុវត្តការងារវិស័យជំនាញតាមសមត្ថភាព និងធនធានដែលមាន

– ការផ្តល់សេវារដ្ឋបាលតាមយន្តការច្រកចេញចូលតែមួយនៅរដ្ឋបាលថ្នាក់ក្រោមជាតិ បាននិងកំពុងធ្វើទំនើបកម្មជាបណ្តើរៗ និងជាទូទៅបានដំណើរការប្រកបដោយប្រសិទ្ធភាព តម្លាភាព និងទទួលបានការពេញចិត្តពីប្រជាពលរដ្ឋ។ សន្ទស្សន៍ភាពពេញចិត្តរបស់ប្រជាពលរដ្ឋចំពោះការផ្តល់សេវារដ្ឋបាលតាមច្រកចេញចូលតែមួយទទួលបាន **០,៦៩ពិន្ទុ** ស្ថិតក្នុងចំណាត់ថ្នាក់បង្គួរផងដែរ (ការអង្កេតអភិបាលកិច្ចឆ្នាំ២០២៥)

– រដ្ឋបាលថ្នាក់ក្រោមជាតិទាំង៣កម្រិត បានបន្តរៀបចំការអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធ គម្រោងសេវាសង្គម និងអនាម័យបរិស្ថាន ដោយប្រើប្រាស់ថវិការបស់ខ្លួន និងថវិកាដែលគៀរគរបានពីប្រភពស្របច្បាប់ផ្សេងទៀត ជាមធ្យមប្រមាណជាង **២.៦០០គម្រោង**

– ការរៀបចំ និងអនុវត្តគម្រោងរដ្ឋបាលថ្នាក់ក្រោមជាតិ មានការនិន្នាការវិជ្ជមានលើការប្រើប្រាស់ថវិកាកាន់តែច្រើនសម្រាប់អនុវត្តគម្រោង ឬសកម្មភាពផ្តល់សេវាសង្គម និងអនាម័យបរិស្ថាន។ ការងារនេះ បានមើលឃើញថា បាននិងកំពុងផ្តោតការយកចិត្តទុកដាក់យ៉ាងខ្លាំងទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិក្នុងការរៀបចំលិខិតបទដ្ឋានគតិយុត្ត សេចក្តីណែនាំ និងការអនុវត្តជាក់ស្តែងយ៉ាងសកម្មនៅតាមរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗប្រកបដោយប្រសិទ្ធភាពក្រោមការដឹកនាំ និងសម្របសម្រួលរបស់ គ.ក.ស.ក. និង គ.ក.ន.ក.។

**ការគ្រប់គ្រង និងកាត់បន្ថយហានិភ័យ**

កជទី២ បានកំណត់ហានិភ័យសំខាន់ៗចំនួន**៣៦** ក្នុងនោះហានិភ័យចំនួន**៣៤** ស្មើនឹង**៩៤%** បានអនុវត្ត រួមបញ្ចូលហានិភ័យចំនួន**១៣** ស្មើនឹង**៣៦%** ត្រូវបានចាត់វិធានការទប់ស្កាត់ និងកាត់បន្ថយដោយជោគជ័យ។

**ការអនុវត្តថវិកា**

ថវិកាសកម្មភាពស្នូលនៃការងារកំណែទម្រង់សម្រាប់អនុវត្ត កជទី២ ពីឆ្នាំ២០២១ ដល់ឆ្នាំ២០២៥ មានចំនួន **៧៤១.១២៥លានរៀល** សមមូលនឹង **១៨៥លានដុល្លារអាមេរិក** រួមមាន សកម្មភាពស្នូលនៃកំណែទម្រង់របស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិមានចំនួន **១៣៦.៧៩៣លានរៀល** សមមូលនឹង **៣៤លានដុល្លារអាមេរិក** និងថវិកាសកម្មភាពជាក់លាក់របស់គម្រោង កម្មវិធីនានារបស់ដៃគូអភិវឌ្ឍន៍គាំទ្រទៅលើកំណែទម្រង់ស្នូលមានចំនួន **៦០៤.៣៣២លានរៀល** សមមូលនឹង **១៥១លានដុល្លារអាមេរិក** ស្មើនឹង**៥៤%**។

គិតត្រឹមឆ្នាំ២០២៤ ចំណាយថវិការបស់ស្ថាប័នរាជរដ្ឋាភិបាលមានចំនួន **៧៩.៣៨៥លានរៀល** សមមូលនឹង **២០លានដុល្លារអាមេរិក** ស្មើនឹង**៥៨%** និងចំណាយថវិការបស់ដៃគូអភិវឌ្ឍន៍មានចំនួន **៣២៧.៩៤៨លានរៀល** សមមូលនឹង **៨២លានដុល្លារអាមេរិក** ស្មើនឹង**៥៤%**។

**គ. បញ្ហាប្រឈម**

ក្នុងអំឡុងពេលនៃការអនុវត្ត កជទី២ រយៈពេល៥ឆ្នាំនេះ បានជួបប្រទះបញ្ហាប្រឈមជាគន្លឹះនានា រួមមាន៖

- ការរីករាលដាលនៃជំងឺកូវីដ-១៩ ដែលបានផ្អាក និងពន្យារពេលការអនុវត្ត កជទី២ រហូតដល់ដើមឆ្នាំ២០២២។ វិបត្តិសកលដែលបង្កឡើងដោយប្រទេសមហាអំណាចនានាបានផ្តល់ផលប៉ះពាល់ដល់ចំណូលថវិការដ្ឋ ក្នុងនោះរួមមាន ថវិកាដែលត្រូវវិភាជឱ្យទៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- វិបត្តិពាក់ព័ន្ធនឹងជម្លោះព្រំដែនរវាងកម្ពុជា-ថៃនាពេលថ្មីៗនេះ កំពុងរំខានដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការអនុវត្តផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់ គ.ជ.អ.ប. ដោយត្រូវផ្តល់អាទិភាពទៅលើការចាត់វិធានការ ថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ការផ្តល់អន្តរាគមន៍ជួយគ្រួសារភៀសសឹក និងពលករដែលវិលត្រឡប់មកពីប្រទេសថៃវិញ
- រដ្ឋបាលថ្នាក់ក្រោមជាតិកំពុងជួបប្រទះបញ្ហាខ្វះធនធានមនុស្សធ្ងន់ធ្ងរ ជាពិសេសការខ្វះបុគ្គលិកតាមការិយាល័យជំនាញនានារបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ
- បើទោះបីថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិមានការកើនឡើងក៏ដោយ ក៏រដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសរដ្ឋបាលក្រុង ស្រុក បានលើកឡើងអំពីការខ្វះថវិកាសម្រាប់គាំទ្រការអនុវត្ត

មុខងារតាមវិស័យមួយចំនួន ជាអាទិ៍ មុខងារក្នុងវិស័យអភិវឌ្ឍន៍ជនបទ សាធារណការ ធនធានទឹក កសិកម្ម ទេសចរណ៍ សង្គមកិច្ច ធនធានធម្មជាតិ និងបរិស្ថានជាដើម

- ពុំទាន់មានសេចក្តីណែនាំ និងនីតិវិធីច្បាស់លាស់អំពីការរៀបចំ និងការអនុវត្តគម្រោងសេវាសង្គម និងអនាម័យបរិស្ថានដែលប្រើប្រាស់ថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- សេវារដ្ឋបាលមួយចំនួនដែលបានផ្ទេរពីក្រសួង ស្ថាប័នឱ្យទៅរដ្ឋបាលក្រុង ស្រុក ខណ្ឌនៅមិនទាន់មាននីតិវិធីច្បាស់លាស់។ ដូចគ្នានេះដែរ មុខងារវិស័យជាច្រើនដែលបានផ្ទេរឱ្យក្រុង ស្រុក ខណ្ឌពុំទាន់មានសេចក្តីណែនាំ និងនីតិវិធីសម្រាប់អនុវត្តនៅឡើយ
- រដ្ឋបាលខេត្តភាគច្រើនកំពុងជួបប្រទះបញ្ហាកង្វះមន្ត្រីបច្ចេកទេស ដើម្បីគាំទ្ររដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់ក្នុងការរៀបចំ និងអនុវត្តគម្រោង។ ទន្ទឹមនេះ ការចុះត្រួតពិនិត្យតាមដាន និងគាំទ្រឃុំ សង្កាត់ក្នុងការរៀបចំ និងអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់មិនត្រូវបានអនុវត្តជាប្រចាំស្របតាមតម្រូវការ និងផែនការការងាររបស់ឃុំ សង្កាត់។

**ឃ. អនុសាសន៍**

ផ្អែកលើលទ្ធផល បញ្ហាប្រឈមដែលបានរៀបរាប់ខាងលើ គួរពិចារណាលើអនុសាសន៍សំខាន់ៗមួយចំនួនដូចខាងក្រោម៖

**ក្របខណ្ឌលទ្ធផល**

- ពិនិត្យ និងកែសម្រួលខ្លឹមសារនៃគោលបំណង និងគោលដៅនៃ កជទី២ ដើម្បីឆ្លើយតប និងមានសង្គតិភាពជាមួយចក្ខុវិស័យ
- កំណត់សូចនាករសម្រាប់ចក្ខុវិស័យ គោលដៅ គោលបំណង និងសមិទ្ធផល
- ពិនិត្យ និងកាត់បន្ថយចំនួនលទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាព តាមរយៈការដាក់បញ្ចូលគ្នានៃលទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាពដែលមានលក្ខណៈស្រដៀងគ្នា និងពាក់ព័ន្ធគ្នា
- កែសម្រួលលទ្ធផលរំពឹងទុក និងសកម្មភាពអាទិភាពនៃ កជទី២ ពីឆ្នាំ២០២៦-២០៣០ ដោយផ្តោតលើអាទិភាពដែលអាចគាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិ និងប្រជាពលរដ្ឋដែលរងគ្រោះដោយសារជម្លោះព្រំដែនថៃ-កម្ពុជា
- កំណត់សូចនាករតាមសកម្មភាពជាអាទិភាព ដើម្បីជាមូលដ្ឋាន និងមានភាពងាយស្រួលក្នុងការរៀបចំ ផ.ស.ថ. ការត្រួតពិនិត្យ ការវាយតម្លៃ និងការរៀបចំរបាយការណ៍។

**ការអនុវត្តកម្មវិធី**

- ពិនិត្យ និងកែសម្រួលរចនាសម្ព័ន្ធ និងតួនាទីភារកិច្ចរបស់ គ.ជ.វ.វ. នៅតាមក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយពង្រីកការទទួលខុសត្រូវលើការងារកំណែទម្រង់គន្លឹះទាំង៥ របស់រាជរដ្ឋាភិបាល និងពង្រឹងការអនុវត្តយន្តការនេះប្រកបដោយប្រសិទ្ធភាព

- លើកកម្ពស់ការផ្សព្វផ្សាយអំពី កជទី២ ផអ៥ទី១ ដល់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈសិក្ខាសាលា និងកិច្ចប្រជុំនានា ដោយមានបទបង្ហាញ និងសេចក្តីពន្យល់ឱ្យបានច្បាស់លាស់ ដើម្បីឱ្យស្ថាប័នទាំងនោះផ្សព្វផ្សាយបន្តដល់ក្នុងស្ថាប័នរបស់ខ្លួន និងអ្នកពាក់ព័ន្ធនានា
- កែសម្រួលសេចក្តីណែនាំស្តីពីការរៀបចំ និងអនុវត្ត ផ.ស.ថ. រួមបញ្ចូលការកែសម្រួលទម្រង់ និងខ្លឹមសារនៃ ផ.ស.ថ. របស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយកំណត់ឱ្យបានច្បាស់នូវលទ្ធផល និងសកម្មភាពនានាដែលត្រូវបញ្ចូលក្នុង ផ.ស.ថ.
- បន្តពង្រឹង និងគាំទ្ររដ្ឋបាលក្រុង ស្រុក ដើម្បីពង្រឹងការអនុវត្តតួនាទី និងភារកិច្ចរបស់ខ្លួនស្របតាមរចនាសម្ព័ន្ធ និងមុខងារដែលបានកែសម្រួល
- ផ្តល់អាទិភាព និងពន្លឿនការរៀបចំ និងដាក់ចេញនូវលិខិតបទដ្ឋាន និងសេចក្តីណែនាំស្តីពីការកំណត់កញ្ចប់ថវិកាដោយឡែកសម្រាប់ក្រុមប្រឹក្សា និងគណៈកម្មាធិការនានាចំណុះក្រុមប្រឹក្សារាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ ដើម្បីលើកកម្ពស់ការបំពេញតួនាទី និងភារកិច្ចរបស់យន្តការនេះ
- ពង្រឹង និងគាំទ្រការអនុវត្តតួនាទី និងភារកិច្ចរបស់ការិយាល័យប្រជាពលរដ្ឋនៅថ្នាក់រាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌក្នុងការទទួល និងសម្រុះសម្រួល ដោះស្រាយបណ្តឹងប្រជាពលរដ្ឋទាំងផ្នែកសេវារដ្ឋបាល និងគម្រោងនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ផ្តល់អាទិភាព និងយកចិត្តទុកដាក់ក្នុងការដោះស្រាយបញ្ហាប្រឈមរបស់ក្រុង ស្រុក ខណ្ឌ រួមមាន កង្វះបុគ្គលិក សមត្ថភាពជំនាញរបស់បុគ្គលិកនៅតាមការិយាល័យជំនាញនានាស្របតាមតួនាទី និងភារកិច្ចដែលបានកំណត់។ល។
- ពង្រឹងការត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការយុទ្ធសាស្រ្តស្តីពីការបង្កើនចំនួនស្រ្តីនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- យកចិត្តទុកដាក់ និងពន្លឿនការរៀបចំ និងវិភាជថវិកាសម្រាប់អនុវត្តមុខងារវិស័យនានាដែលបានផ្ទេរឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌឱ្យបានសមស្រប
- ពន្លឿនការរៀបចំ និងដាក់ចេញនូវសេចក្តីណែនាំ និងនីតិវិធីសម្រាប់ការងារត្រួតពិនិត្យផ្ទៃក្នុងនៅថ្នាក់ក្រុង ស្រុក
- ពន្លឿនការរៀបចំ និងដាក់ចេញសេចក្តីណែនាំ និងនីតិវិធីសម្រាប់អនុវត្តមុខងារវិស័យដែលផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ
- រៀបចំ និងដាក់ចេញសេចក្តីណែនាំ និងនីតិវិធីនានាសម្រាប់អនុវត្តគម្រោង សកម្មភាពនានាពាក់ព័ន្ធនឹងសេវាសង្គម និងអនាម័យបរិស្ថាននៃរដ្ឋបាលថ្នាក់ក្រោមជាតិ
- យកចិត្តទុកដាក់ និងពង្រឹងការត្រួតពិនិត្យ តាមដាន និងគាំទ្រការរៀបចំ និងអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់

- ជារៀងរាល់ឆ្នាំ លេខាធិការដ្ឋាន គ.ជ.អ.ប. ត្រូវរៀបចំផែនការការងារស្តីពីការគ្រប់គ្រង និងកាត់បន្ថយហានិភ័យប្រចាំឆ្នាំដោយមានការបែងចែកអ្នកទទួលខុសត្រូវ និងវិភាជថវិកាគាំទ្រឱ្យបានសមស្រប ដើម្បីធានាប្រសិទ្ធភាពក្នុងការអនុវត្តផែនការនេះ
- ពង្រឹងតួនាទីរបស់លេខាធិការដ្ឋាន គ.ជ.អ.ប. ក្នុងការពិនិត្យ និងផ្តល់ការឯកភាពលើគម្រោងថវិកាប្រចាំឆ្នាំរបស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់សកម្មភាពស្នូលនៃការងារកំណែទម្រង់មុននឹងដាក់ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុពិនិត្យ និងអនុម័ត។

## ១. សេចក្តីផ្តើម

កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដំណាក់កាលទី២ (២០២១-២០៣០) ហៅកាត់ "កជទី២" ត្រូវបានអនុម័តដោយរាជរដ្ឋាភិបាលនៅថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០២១។

កជទី២ បានរៀបចំឡើងក្នុងគោលបំណង "**លើកកម្ពស់ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ប្រកបដោយបរិយាបន្ន សមធម៌សង្គម និងយុត្តិធម៌ តាមរយៈការធ្វើទំនើបកម្មប្រព័ន្ធអភិបាលកិច្ចនៅថ្នាក់ក្រោមជាតិ និងការកែលម្អដំណើរការផ្តល់សេវា និងគុណភាពសេវា ដើម្បីចូលរួមចំណែកកាត់បន្ថយភាពក្រីក្រ លើកកម្ពស់គុណភាពជីវិតរបស់ប្រជាជនឱ្យកាន់តែល្អប្រសើរឡើង**"។

ដើម្បីសម្រេចបាននូវគោលបំណងខាងលើ កជទី២ បានកំណត់គោលដៅច្បាស់លាស់មួយ គឺ "**ការរៀបចំរចនាសម្ព័ន្ធ និងប្រព័ន្ធអភិបាលកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិឱ្យមានលក្ខណៈទំនើប មានស្វ័យភាព ប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាពក្នុងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចនៃរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ។ ទន្ទឹមនេះ រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗនឹងមានសិទ្ធិអំណាចសមស្រប និងសមត្ថភាពគ្រប់គ្រាន់សម្រាប់អនុវត្តមុខងារនានាក្រោមការត្រួតពិនិត្យពីក្រុមប្រឹក្សា ដើម្បីធានាដល់ការពង្រឹងគណនេយ្យភាពចំពោះប្រជាពលរដ្ឋ**"។

ដើម្បីធានាដល់ការសម្រេចបានគោលបំណង និងគោលដៅខាងលើ កជទី២ បានកំណត់សមាសភាគជាយុទ្ធសាស្ត្រសំខាន់ៗចំនួន៥ ដែលត្រូវរៀបចំ និងអនុវត្តដូចខាងក្រោម៖

សមាសភាគទី១ ៖ ការដឹកនាំ និងការសម្របសម្រួលការងារកំណែទម្រង់ ផ្តោតលើការបន្តពង្រឹងយន្តការដឹកនាំ សម្របសម្រួលការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សំដៅលើកកម្ពស់**ភាពជាម្ចាស់ និងការទទួលខុសត្រូវ**របស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការរៀបចំ និងអនុវត្តសកម្មភាពជាអាទិភាពនានានៃកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការឱ្យកាន់តែមានប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព។

សមាសភាគទី២ ៖ រចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ ផ្តោតលើការបន្តពិនិត្យ និងការកែសម្រួលមុខងារ រចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង ធនធាន និងសិទ្ធិអំណាចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិឱ្យស្របតាមចរិតលក្ខណៈជារដ្ឋបាលនៃតំបន់ទីក្រុងធំ រដ្ឋបាលនៃតំបន់ទីប្រជុំជន និងរដ្ឋបាលនៃតំបន់ជនបទ ដោយជំរុញការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការផ្តល់សេវា និងការប្រាស្រ័យទាក់ទងសាធារណៈ ព្រមទាំងដើម្បីធានាដល់ការឆ្លើយតបទៅនឹងការវិវឌ្ឍយ៉ាងឆាប់រហ័សនៃសកម្មភាពសេដ្ឋកិច្ច នគរូបនីយកម្ម បច្ចេកវិទ្យាព័ត៌មានវិទ្យា និន្នាការបម្លាស់ទីរបស់ប្រជាពលរដ្ឋមកកាន់ទីប្រជុំជន ការកើនឡើងនៃតម្រូវការសេវាសង្គម និងតម្រូវការនៃការកាត់បន្ថយហានិភ័យនានាដែលបង្កឡើងដោយគ្រោះធម្មជាតិ ការប្រែប្រួលអាកាសធាតុ និងវិបត្តិជាសកល។

**សមាសភាគទី៣ ៖ ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស** ផ្តោតលើការជំរុញ និងពង្រឹងការអនុវត្តសិទ្ធិអំណាច និងការទទួលខុសត្រូវរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការជ្រើសរើស ការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់បុគ្គលិករបស់ខ្លួន ផ្អែកលើទំហំការងារ និងលទ្ធភាពហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ព្រមទាំងការធានាឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិមានបុគ្គលិកប្រកបដោយឆន្ទៈម្ចាស់ការ ភក្តីភាព និងមនសិការជំនាញវិជ្ជាជីវៈស្របតាមតួនាទី ការទទួលខុសត្រូវរបស់ខ្លួន ព្រមទាំងទទួលបានការអភិវឌ្ឍសមត្ថភាព និងជំនាញវិជ្ជាជីវៈជាប្រចាំ។

**សមាសភាគទី៤ ៖ វិមជ្ឈការហិរញ្ញវត្ថុ និងប្រព័ន្ធផែនការនិងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ** ផ្តោតលើការបន្តរៀបចំឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិមានធនធានថវិកាដែលអាចព្យាករណ៍បាន និងមានទំហំសមស្រប ព្រមទាំងអាចវិភាជធនធានទាំងនោះប្រកបដោយភាពបត់បែនសម្រាប់ការប្រើប្រាស់លើអនុវត្តមុខងារ និងកិច្ចការអាទិភាពនានា ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋដែលបានកំណត់ក្នុងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគរបស់រដ្ឋបាលថ្នាក់ក្រោមជាតិឱ្យបានទាន់ពេល និងប្រកបដោយប្រសិទ្ធភាពខ្ពស់។

**សមាសភាគទី៥ ៖ ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន** ផ្តោតលើការបន្តធ្វើទំនើបកម្មយន្តការ និងនីតិវិធីផ្តល់សេវា ការអភិវឌ្ឍមូលដ្ឋាន និងការប្រាស្រ័យទាក់ទងជាសាធារណៈរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីលើកកម្ពស់ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន ឆ្លើយតបទៅនឹងតម្រូវការចាំបាច់របស់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗប្រកបដោយប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព បរិយាបន្ន និងសមធម៌សង្គម។

ក្រៅពីសមាសភាគទាំង៥ខាងលើ កជទី២ ក៏ផ្តោតលើកិច្ចការអន្តរវិស័យសំខាន់ចំនួន៣ គឺ៖

- ការលើកកម្ពស់សមភាពយេនឌ័រ បរិយាបន្ន និងសមធម៌សង្គម
- ការកាត់បន្ថយភាពងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុ និងហានិភ័យនៃគ្រោះមហន្តរាយ
- អភិបាលកិច្ចឌីជីថល។

កជទី២ ត្រូវបានរៀបចំ និងអនុវត្តជា២ដំណាក់កាល គឺការរៀបចំ និងការអនុវត្តផែនការអនុវត្តរយៈពេល៥ឆ្នាំ ដំណាក់កាលទី១ (ផអ៥ទី១) ដែលត្រូវអនុវត្តពីឆ្នាំ២០២១ ដល់ឆ្នាំ២០២៥ និងផែនការអនុវត្តរយៈពេល៥ឆ្នាំ ដំណាក់កាលទី២ (ផអ៥ទី២) ដែលត្រូវរៀបចំ និងអនុវត្តពីឆ្នាំ២០២៦ ដល់ឆ្នាំ២០៣០។

ការវាយតម្លៃពាក់កណ្តាលអាណត្តិនៃ កជទី២ គឺជាសកម្មភាពមួយនៃការវាយតម្លៃ កជទី២ ដែលកំណត់ក្នុងជំពូកទី៤ អំពីការគ្រប់គ្រង និងការអនុវត្តកម្មវិធីនៃឯកសារ កជទី២ (ចំណុច ៤.២.៦.៣.) និងជាសកម្មភាពជាអាទិភាពមួយក្នុងសមាសភាគទី១ (សកម្មភាពជាអាទិភាព ១.៣.៦.) ដែលគ្រោងអនុវត្តក្នុងអំឡុងឆ្នាំទី៥នៃផអ៥ទី១ គឺឆ្នាំ២០២៥។ ការវាយតម្លៃនេះ ត្រូវបានអនុវត្តដោយមានការគាំទ្រពីគម្រោង "**ការពង្រឹងតម្លាភាព និងគណនេយ្យភាពក្នុងអភិបាលកិច្ចមូលដ្ឋានតាមរយៈការចូលរួមរបស់**

**ប្រជាពលរដ្ឋ**” នៃកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) ប្រចាំកម្ពុជា ដែលទទួលបានការគាំទ្រហិរញ្ញប្បទានឥតសំណងពីរាជរដ្ឋាភិបាលជប៉ុន និងហិរញ្ញប្បទានផ្ទាល់មួយចំនួនរបស់ UNDP។ លក្ខខណ្ឌការងារសម្រាប់ការវាយតម្លៃពាក់កណ្តាលអាណត្តិនៃ កជទី២ មានបរិយាយនៅក្នុងឧបសម្ព័ន្ធទី១។

## ២. គោលបំណងនៃការវាយតម្លៃពាក់កណ្តាលអាណត្តិ កជទី២

ការវាយតម្លៃពាក់កណ្តាលអាណត្តិនៃ កជទី២ មានគោលបំណងដូចខាងក្រោម៖

- វាយតម្លៃលើវឌ្ឍនភាពដោយផ្តោតលើរចនាសម្ព័ន្ធ ប្រព័ន្ធអភិបាលកិច្ច ការអភិវឌ្ឍធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ការផ្ទេរមុខងារទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ការបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ប្រៀបធៀបទៅនឹងលទ្ធផលរំពឹងទុកដែលបានកំណត់តាមសមាសភាគនីមួយៗ និងការកំណត់បញ្ហាប្រឈមជាគន្លឹះ និងហានិភ័យនៃការអនុវត្ត ផអ៥ទី១
- ពិនិត្យ និងវាយតម្លៃភាពសមស្របនៃក្របខណ្ឌលទ្ធផលនៃ កជទី២ និង ផអ៥ទី១ ដោយផ្អែកលើគោលការណ៍ SMART (ភាពជាក់លាក់ អាចវាស់វែងបាន អាចសម្រេចបាន ភាពពាក់ព័ន្ធ និងពេលវេលាកំណត់) និងពិចារណាលើរយៈពេល៥ឆ្នាំចុងក្រោយនៃ កជទី២
- ពិនិត្យ និងកំណត់លទ្ធផល និងសកម្មភាពជាអាទិភាពដែលត្រូវអនុវត្តក្នុងដំណាក់កាលទី២ នៃ កជទី២ ពីឆ្នាំ២០២៦ ដល់ឆ្នាំ២០៣០
- កំណត់អនុសាសន៍សម្រាប់ដោះស្រាយបញ្ហាប្រឈមសំខាន់ៗដែលបានកំណត់ និងការកាត់បន្ថយហានិភ័យ
- លទ្ធផលនៃការសិក្សាវាយតម្លៃពាក់កណ្តាលអាណត្តិនៃ កជទី២ នេះ ក៏នឹងត្រូវប្រើប្រាស់សម្រាប់ការរៀបចំ ផអ៥ទី២ និងធ្វើជាទិន្នន័យដើមគ្រាសម្រាប់ការវាយតម្លៃបញ្ចប់នៃ កជទី២។

## ៣. វិសាលភាពនៃការវាយតម្លៃពាក់កណ្តាលអាណត្តិ កជទី២

ការវាយតម្លៃពាក់កណ្តាលអាណត្តិ កជទី២ គឺជាការត្រួតពិនិត្យមើលលើវឌ្ឍនភាពនៃការអនុវត្ត កជទី២ ពីឆ្នាំ២០២១ ដល់ឆ្នាំ២០២៥ ដោយផ្តោតជាសំខាន់លើការសម្រេចបាននូវលទ្ធផលនៃការអនុវត្ត កជទី២ ក្នុងកម្រិតលទ្ធផលរំពឹងទុក (Expected Outputs) រួមទាំងសូចនាករពាក់ព័ន្ធ និងសកម្មភាពជាអាទិភាព (Priority Activities) ព្រមទាំងការកំណត់អំពីបញ្ហាប្រឈម និងហានិភ័យដែលបានជួបប្រទះ និងដោះស្រាយក្នុងអំឡុងពេលនៃការអនុវត្តនេះ។ ក្នុងន័យនេះ វិសាលភាពនៃការវាយតម្លៃពាក់កណ្តាលអាណត្តិនៃ កជទី២ មិនគ្របដណ្តប់លើការវិភាគផលប៉ះពាល់ដែលសម្រេចបាននៅកម្រិតគោលដៅ គោលបំណង និងចក្ខុវិស័យរបស់ កជទី២ ឬ ផអ៥ទី១ ឡើយ។

## ៤. វិធីសាស្ត្រនៃការវាយតម្លៃពាក់កណ្ដាលអាណត្តិ កជទី២

ការវាយតម្លៃពាក់កណ្ដាលអាណត្តិនៃ កជទី២ ឬការវាយតម្លៃចុងបញ្ចប់នៃ ផអ៥ទី១ ត្រូវបានអនុវត្តក្នុងរយៈពេល៥ខែ ចាប់ពីខែមីនា ដល់ខែកក្កដា ឆ្នាំ២០២៥ តាមរយៈការប្រជុំពិភាក្សា ដើម្បីប្រមូលព័ត៌មាននៅតាមក្រសួង ស្ថាប័នពាក់ព័ន្ធថ្នាក់ជាតិ រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធនានាដែលបានជ្រើសរើសតាមវិធីសាស្ត្រដូចមានសង្ខេបខាងក្រោម៖

### ៤.១. វិធីសាស្ត្រ និងឧបករណ៍វាយតម្លៃ

វិធីសាស្ត្រសំខាន់ៗដែលប្រើប្រាស់សម្រាប់ការវាយតម្លៃពាក់កណ្ដាលអាណត្តិនៃ កជទី២ រួមមាន៖

- ការសិក្សា ស្រាវជ្រាវ និងវិភាគលើឯកសារគោលនយោបាយ ច្បាប់ លិខិតបទដ្ឋានគតិយុត្ត របាយការណ៍ និងឯកសារនានាដែលពាក់ព័ន្ធនឹងការអនុវត្ត កជទី២/ ផអ៥ទី១
- ការចុះប្រមូលទិន្នន័យ និងព័ត៌មានសំខាន់ៗពាក់ព័ន្ធនឹងការអនុវត្ត ផអ៥ទី១ តាមរយៈការជួបពិភាក្សា និងសម្ភាសន៍ជាមួយក្រុមអ្នកផ្ដល់ព័ត៌មានពាក់ព័ន្ធទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដោយប្រើប្រាស់សំណួរជាគន្លឹះ និងបញ្ជីសំណួរដែលត្រូវរៀបចំសម្រាប់ប្រភេទផ្សេងៗគ្នានៃក្រុមអ្នកផ្ដល់ព័ត៌មាននីមួយៗ
- ការបញ្ចូលទិន្នន័យ និងការវិភាគទិន្នន័យដែលប្រមូលបាន ទាំងការវិភាគបែបវិទ្យាសាស្ត្រ និងការវិភាគតាមបែបទស្សនៈយល់ឃើញ
- ការរៀបចំសេចក្ដីព្រាងបឋមរបាយការណ៍ស្ដីពីរបកគំហើញនៃការវាយតម្លៃពាក់កណ្ដាលអាណត្តិនៃ កជទី២ ផ្អែកលើលទ្ធផលនៃការវិភាគទិន្នន័យ
- ការរៀបចំ និងសម្របសម្រួលការពិភាក្សា និងការពិគ្រោះយោបល់លើសេចក្ដីព្រាងបឋមរបាយការណ៍ស្ដីពីរបកគំហើញនៃការវាយតម្លៃ តាមរយៈការរៀបចំកិច្ចប្រជុំ ឬសិក្ខាសាលាជាមួយអ្នកពាក់ព័ន្ធនានាទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិដែលមានអ្នកពាក់ព័ន្ធចូលរួមយ៉ាងតិចចំនួន ៥០នាក់
- ការពិនិត្យ កែសម្រួល និងរៀបចំបញ្ចប់សេចក្ដីព្រាងរបាយការណ៍ស្ដីពីការវាយតម្លៃពាក់កណ្ដាលអាណត្តិ កជទី២ ដើម្បីដាក់ជូនលេខាធិការដ្ឋាន គ.ជ.អ.ប.។

ការវាយតម្លៃពាក់កណ្ដាលអាណត្តិ កជទី២ ត្រូវបានអនុវត្តតាមរយៈការប្រើប្រាស់បញ្ជីសំណួរលក្ខណៈជាបុគ្គល (វាយតម្លៃក្នុងប្រព័ន្ធ Google Form) និងបញ្ជីសំណួរជាគន្លឹះសម្រាប់ពិភាក្សាជាក្រុមដែលត្រូវបានរៀបចំតាមប្រភេទអ្នកផ្ដល់ព័ត៌មានដូចខាងក្រោម៖

**ថ្នាក់ជាតិ៖**

សំណួរនៅថ្នាក់ជាតិមាន ៣ប្រភេទគឺ៖

១. សំណួរសម្រាប់លេខាធិការដ្ឋាន គ.ជ.អ.ប.

២. សំណួរសម្រាប់ក្រសួង ស្ថាប័នពាក់ព័ន្ធ

៣. សំណួរសម្រាប់ដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិល។

**ថ្នាក់ក្រោមជាតិ៖**

សំណួរនៅថ្នាក់ក្រោមជាតិរួមមាន ៥ប្រភេទគឺ៖

១. ក្រុមប្រឹក្សា និងគណៈកម្មាធិការពាក់ព័ន្ធនៃរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

២. គណៈអភិបាល នាយក នាយករង និងអង្គភាពចំណុះសាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

៣. មន្ទីរ អង្គភាពជំនាញថ្នាក់រាជធានី ខេត្ត

៤. អង្គការសង្គមស៊ីវិលពាក់ព័ន្ធនៅថ្នាក់រាជធានី ខេត្ត

៥. ក្រុមប្រឹក្សាឃុំ សង្កាត់ គណៈកម្មាធិការនានា មេឃុំ ចៅ សង្កាត់ និងមន្ត្រីពាក់ព័ន្ធ។

បញ្ជីសំណួរទាំងអស់ ត្រូវបានរៀបចំជា ២ផ្នែកគឺ៖

១. សំណួរអំពីក្របខណ្ឌលទ្ធផលនៃ កជទី២/ ផអ៥ទី១ និង

២. សំណួរអំពីវឌ្ឍនភាព បញ្ហាប្រឈម និងហានិភ័យនៃការអនុវត្ត កជទី២ ឬ ផអ៥ទី១ តាមសមាសភាគនីមួយៗពីឆ្នាំ២០២១-២០២៥។

### ៤.២. តំបន់គោលដៅ និងអ្នកផ្តល់ព័ត៌មាន

ការវាយតម្លៃពាក់កណ្តាលអាណត្តិនៃ កជទី២ ត្រូវបានអនុវត្តក្នុងខេត្តចំនួន៦ (ខេត្តកំពង់ស្ពឺ កំពង់ចាម ស្ទឹងត្រែង ពោធិ៍សាត់ កោះកុង និងឧត្តរមានជ័យ) រួមបញ្ចូលរដ្ឋបាលក្រុង ស្រុកចំនួន**១២** និងរដ្ឋបាលឃុំ សង្កាត់ចំនួន**២៤** ព្រមទាំងក្រសួង ស្ថាប័ន និងអង្គការសង្គមស៊ីវិលពាក់ព័ន្ធនានា។

អ្នកផ្តល់ព័ត៌មានដែលបានចូលរួមវាយតម្លៃ កជទី២ សរុបមានចំនួន **១.២៧៥នាក់** ក្នុងនោះអ្នកផ្តល់ព័ត៌មានជាស្ត្រីមានចំនួន**២៨%** ដូចមានបង្ហាញក្នុងតារាងខាងក្រោម៖

តារាងទី១ ៖ សេចក្តីសង្ខេបអំពីអ្នកផ្តល់ព័ត៌មាននៃការវាយតម្លៃពាក់កណ្តាលអាណត្តិ កជទី២

| ល.រ. | ស្ថាប័ន | ប្រុស | ស្រី | សរុប |
|---|---|---|---|---|
| ១ | ក្រសួង ស្ថាប័ន | 79 | 24 | 103 |
| ២ | រដ្ឋបាលខេត្ត | 154 | 42 | 196 |
| ៣ | មន្ទីរ អង្គភាពជំនាញថ្នាក់ខេត្ត | 132 | 45 | 177 |
| ៤ | អង្គការសង្គមស៊ីវិល | 37 | 26 | 63 |
| ៥ | រដ្ឋបាលក្រុង ស្រុក | 280 | 108 | 388 |
| ៦ | រដ្ឋបាលឃុំ សង្កាត់ | 239 | 109 | 348 |
| | **សរុប** | 921 | 354 (28%) | 1,275 |

បញ្ជីរដ្ឋបាលថ្នាក់ក្រោមជាតិ ក្រសួង ស្ថាប័ន និងអង្គការសង្គមស៊ីវិលដែលបានជ្រើសរើស និងវាយតម្លៃពាក់កណ្តាលអាណត្តិ កជទី២ មានរៀបរាប់នៅក្នុងឧបសម្ព័ន្ធទី៦។

## ៥. របកគំហើញនៃការវាយតម្លៃពាក់កណ្តាលអាណត្តិ កជទី២

ផ្អែកតាមគោលបំណងនៃការវាយតម្លៃពាក់កណ្តាលអាណត្តិនៃ កជទី២ នេះ របកគំហើញ ឬ លទ្ធផលនៃការវាយតម្លៃត្រូវបានរៀបចំ និងបែងចែកជា២ផ្នែក គឺរបកគំហើញពាក់ព័ន្ធនឹងក្របខណ្ឌលទ្ធផល និងរបកគំហើញពាក់ព័ន្ធនឹងការអនុវត្តកម្មវិធី រួមបញ្ចូលទាំងវឌ្ឍនភាពនៃការគ្រប់គ្រង ការកាត់បន្ថយហានិភ័យ និងការអនុវត្តថវិកា។

### ៥.១. របកគំហើញពាក់ព័ន្ធនឹងក្របខណ្ឌលទ្ធផលនៃ កជទី២

តាមការសិក្សាលើឯកសារ កជទី២ បានបង្ហាញឱ្យឃើញថា ឯកសារ កជទី២ បានរៀបចំតាមឋានានុក្រមនៃលទ្ធផល (តក្កភាព) ដែលរួមមាន៖

- ចក្ខុវិស័យ
- គោលបំណង
- គោលដៅ
- សមិទ្ធផល (តាមសមាសភាគនីមួយៗ)
- លទ្ធផលរំពឹងទុក (រួមបញ្ចូលសូចនាករ)
- សកម្មភាពជាអាទិភាព

ការអនុវត្ត កជទី២ ធ្វើឡើងតាមរយៈផែនការអនុវត្តរយៈពេល៥ឆ្នាំ រួមមាន ផអ៥ទី១ (២០២១-២០២៥) និង ផអ៥ទី២ (២០២៦-២០៣០)។ ទោះបី ឋានានុក្រម និងខ្លឹមសារលទ្ធផលនៃ ផអ៥ទី១ មានលក្ខណៈដូចគ្នាស្ទើរតែទាំងស្រុងទៅនឹងឋានានុក្រម និងខ្លឹមសារលទ្ធផលនៃ កជទី២ ក៏ដោយ ក៏ឯកសារ ផអ៥ទី១ បានកំណត់នូវសូចនាករ និងចំណុចដៅតាមលទ្ធផលរំពឹងទុកនីមួយៗដែលត្រូវសម្រេចតាមឆ្នាំនីមួយៗយ៉ាងច្បាស់លាស់។

ជារួម ផអ៥ទី១ បានកំណត់សកម្មភាពអាទិភាពចំនួន**១១២** លទ្ធផលរំពឹងទុកចំនួន**៣៧** និងសូចនាករចំនួន**១៦៥**។ សកម្មភាពជាអាទិភាព និងលទ្ធផលរំពឹងទុកទាំងនេះមានភាពប្រទាក់ក្រឡាគ្នា និងមានទំនាក់ទំនងឆ្លើយឆ្លងគ្នាទៅវិញទៅមក ពោលគឺ បើការអនុវត្តបានជោគជ័យនូវសកម្មភាពជាអាទិភាព នោះនឹងឈានទៅការសម្រេចបាននូវលទ្ធផលរំពឹងទុក បើលទ្ធផលរំពឹងទុកត្រូវបានសម្រេចដោយជោគជ័យ នោះនឹងឈានទៅសម្រេចបានសមិទ្ធផល ហើយបើសមិទ្ធផលត្រូវបានសម្រេចដោយជោគជ័យ នោះនឹងនាំទៅសម្រេចបានដោយជោគជ័យនូវគោលដៅ គោលបំណង និងចក្ខុវិស័យ។

ទោះបីយ៉ាងនេះក្តី ឯកសារ កជទី២ ពុំមានតារាងក្របខណ្ឌលទ្ធផលរួមមួយដែលកំណត់អំពីសូចនាករ និងចំណុចដៅសម្រាប់ការអនុវត្តក្នុងរយៈពេល១០ឆ្នាំនៃ កជទី២ ឡើយ។ បញ្ហានេះនាំឱ្យមានការលំបាកក្នុងការត្រួតពិនិត្យ និងការវាយតម្លៃការអនុវត្តកជទី២។

### ក. របកគំហើញពាក់ព័ន្ធនឹងចក្ខុវិស័យ

ចក្ខុវិស័យរបស់ កជទី២ គឺ "*ប្រជាពលរដ្ឋទទួលបានសេវាសាធារណៈ និងផលប្រយោជន៍ពីការអភិវឌ្ឍមូលដ្ឋានដែលផ្តល់ដោយរដ្ឋបាលថ្នាក់ក្រោមជាតិប្រកបដោយបរិយាបន្ន និងសមធម៌សង្គមដែលរួមចំណែកសម្រេចឱ្យបាននូវគោលបំណងដ៏ទូលំទូលាយក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមជាតិ និងប្រែក្លាយប្រទេសកម្ពុជាឱ្យទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០*"។

ខ្លឹមសារសំខាន់នៃចក្ខុវិស័យនេះ **គឺប្រជាពលរដ្ឋទទួលបានសេវាសាធារណៈ និងផលប្រយោជន៍ពីការអភិវឌ្ឍមូលដ្ឋានដែលផ្តល់ដោយរដ្ឋបាលថ្នាក់ក្រោមជាតិប្រកបដោយបរិយាបន្ន និងសមធម៌សង្គម។**

ទោះបីចក្ខុវិស័យនៃ កជទី២ បានកំណត់អំពីបំណងប្រាថ្នាច្បាស់លាស់ដែលចង់សម្រេចនៅឆ្នាំ២០៣០ក៏ដោយក៏ កជទី២ ពុំបានកំណត់សូចនាករសម្រាប់ជាមូលដ្ឋានក្នុងការវាយតម្លៃការសម្រេចបានចក្ខុវិស័យនេះឡើយ។

ក្រៅពីនេះ ការប្រើពាក្យ "**សេវាសាធារណៈ**" និងពាក្យ "**ការអភិវឌ្ឍមូលដ្ឋាន**" ក្នុងប្រយោគចក្ខុវិស័យនៃ កជទី២ និងក្នុងឯកសារផ្សេងទៀតពាក់ព័ន្ធនឹងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការពុំមានសង្គតិភាពជាមួយនឹងឯកសារក្នុងវិស័យផ្សេងទៀតឡើយ។ ទីប្រឹក្សាវាយតម្លៃសង្កេតឃើញថា ពាក្យ "**សេវាសាធារណៈ**" ក្នុងក្របខណ្ឌនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ គឺសំដៅដល់សេវាទាំងឡាយណាដែលកើតចេញពីការអនុវត្តមុខងារជាកាតព្វកិច្ច ដែលបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ឬដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដូចជាសេវារដ្ឋបាល សេវាសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ សេវាសុខាភិបាល សេវាអប់រំ សេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនជាដើម។ ចំពោះពាក្យ "**ការអភិវឌ្ឍមូលដ្ឋាន**" សំដៅដល់ការអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធ និងគម្រោងសេវាកម្មរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលបានប្រើប្រាស់ថវិកាឆន្ទានុសិទ្ធិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ជាពិសេស ថវិកាសមាសភាគអភិវឌ្ឍន៍មូលដ្ឋាននៃមូលនិធិឃុំ សង្កាត់ មូលនិធិក្រុង ស្រុក និងថវិកាគុណប្រយោជន៍រាជធានី ខេត្ត ដូចជា គម្រោងសាងសង់ផ្លូវ ថ្នល់ ស្ពាន លូ សួនច្បារសាធារណៈ អគារសាលារៀន ស្រះទឹក សាងសង់ទំនប់ ប្រព័ន្ធធារាសាស្ត្រខ្នាតតូចជាដើម។ ក្នុងក្របខណ្ឌនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ពាក្យទាំងពីរនេះត្រូវបានសង្កេតឃើញថា តែងតែប្រើជាប់ជាមួយគ្នា (ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន) គឺសំដៅដល់ការអនុវត្តសកម្មភាពទាំងឡាយណាដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីឆ្លើយតបទៅនឹងតម្រូវការជាអាទិភាពរបស់ប្រជាពលរដ្ឋ និងដោះស្រាយបញ្ហាប្រឈមនានានៅតាមមូលដ្ឋានក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ។

ចំពោះពាក្យ **សេវាសាធារណៈ** ដែលបានប្រើប្រាស់ក្នុងឯកសារសាធារណៈនៅក្នុងវិស័យផ្សេងទៀត គឺសំដៅដល់ការអនុវត្តសកម្មភាពទាំងឡាយដែលធ្វើឡើងដោយស្ថាប័នមានសមត្ថកិច្ច (ស្ថាប័នរដ្ឋ ឬភ្នាក់ងាររដ្ឋ ឬអាជ្ញាធរគ្រប់លំដាប់ថ្នាក់របស់រដ្ឋ) និងស្ថាប័នទទួលសមត្ថកិច្ច (ផ្នែកឯកជន និងសង្គមស៊ី

វិលដែលទទួលបានសិទ្ធិ និងភារកិច្ចពីរដ្ឋ) ក្នុងគោលដៅបម្រើប្រយោជន៍សាធារណៈ។

ការប្រើប្រាស់ពាក្យគន្លឹះដែលមិនមានសង្គតិភាពគ្នានេះ អាចធ្វើឱ្យមានការភាន់ច្រឡំ មានការយល់ឃើញខុសៗគ្នា និងការបកស្រាយផ្សេងៗគ្នាចំពោះអត្ថន័យនៃពាក្យទាំងនេះ។ ប្រការនេះ ក្នុងករណីដែលពុំបានកំណត់សូចនាករច្បាស់លាស់សម្រាប់ជាមូលដ្ឋានក្នុងការវាយតម្លៃ និងនាំឱ្យមានការលំបាកក្នុងការវាស់វែងឆ្លុះបញ្ចាំងអំពីលទ្ធផលនៃការសម្រេចបានចក្ខុវិស័យនៃ កជទី២។

### ខ. របកគំហើញពាក់ព័ន្ធនឹងគោលបំណង

ដើម្បីរួមចំណែកសម្រេចបានចក្ខុវិស័យខាងលើ កជទី២ បានកំណត់គោលបំណងជាក់លាក់មួយ គឺ *លើកកម្ពស់ការផ្តល់សេវា និងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យប្រកបដោយបរិយាបន្ន សមធម៌សង្គម និងយុត្តិធម៌ តាមរយៈការធ្វើទំនើបកម្មប្រព័ន្ធអភិបាលកិច្ចថ្នាក់ក្រោមជាតិ និងការកែលម្អនូវដំណើរការផ្តល់សេវា និងគុណភាពសេវា ដើម្បីរួមចំណែកលុបបំបាត់ភាពក្រីក្រ និងការលើកកម្ពស់គុណភាពជីវិតរបស់ប្រជាពលរដ្ឋឱ្យកាន់តែប្រសើរឡើង។*

ខ្លឹមសារសំខាន់នៃគោលបំណង គឺ **លើកកម្ពស់ការផ្តល់សេវាសាធារណៈ ការអភិវឌ្ឍមូលដ្ឋាន និងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យប្រកបដោយបរិយាបន្ន សមធម៌សង្គម និងយុត្តិធម៌។**

កជទី២ ពុំបានកំណត់សូចនាករ និងចំណុចដៅសម្រាប់ជាមូលដ្ឋានក្នុងការវាយតម្លៃការសម្រេចបានគោលបំណងដែលបានកំណត់ឡើយ។ ក្រៅពីនេះ ក៏មានការកត់សម្គាល់ថា ពុំមានភាពច្បាស់លាស់ក្នុងការធានាថា ការសម្រេចបានគោលបំណងនេះនឹងឈានទៅសម្រេចបានចក្ខុវិស័យនោះឡើយ។

ពាក់ព័ន្ធនឹងបញ្ហានេះ ទីប្រឹក្សាវាយតម្លៃយល់ឃើញថា ដើម្បីសម្រេចបានចក្ខុវិស័យដែលប្រាថ្នាចង់ឱ្យប្រជាពលរដ្ឋទទួលបានសេវាសាធារណៈ និងផលប្រយោជន៍ពីការអភិវឌ្ឍមូលដ្ឋានដែលផ្តល់ដោយរដ្ឋបាលថ្នាក់ក្រោមជាតិប្រកបដោយបរិយាបន្ន និងសមធម៌សង្គម គួរតែកំណត់គោលបំណងឱ្យបានជាក់លាក់ដែលត្រូវឆ្លើយតបទៅនឹងទិដ្ឋភាពសំខាន់ចំនួន៣ ដែលបានកំណត់ក្នុងចក្ខុវិស័យ គឺ (១). ការលើកកម្ពស់ការផ្តល់សេវាសាធារណៈ (២). ការជំរុញការអភិវឌ្ឍមូលដ្ឋាន (៣). ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានត្រូវផ្តល់ផលប្រយោជន៍ប្រកបដោយបរិយាបន្ន និងសមធម៌សង្គម។

ក្នុងន័យនេះ គោលបំណងនៃ កជទី២ គួរកែសម្រួលថា "*លើកកម្ពស់ការផ្តល់សេវាសាធារណៈ និងជំរុញការអភិវឌ្ឍមូលដ្ឋាន ស្របតាមគោលការណ៍នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ដើម្បីរួមចំណែកលុបបំបាត់ភាពក្រីក្រ និងលើកកម្ពស់គុណភាពជីវិតរបស់ប្រជាពលរដ្ឋឱ្យកាន់តែល្អប្រសើរឡើង*"។ ទន្ទឹមនឹងការកែសម្រួលគោលបំណងនេះ ក៏ចាំបាច់ត្រូវកំណត់សូចនាករ និងចំណុចដៅឱ្យបានច្បាស់លាស់សម្រាប់ជាមូលដ្ឋានក្នុងការអនុវត្ត ការតាមដានត្រួតពិនិត្យ និងការវាយតម្លៃ។

### គ. របកគំហើញពាក់ព័ន្ធនឹងគោលដៅ

ដើម្បីសម្រេចគោលបំណងខាងលើ គោលដៅនៃ កជទី២ បានកំណត់ថា □*រចនាសម្ព័ន្ធ និងប្រព័ន្ធអភិបាលកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិមានលក្ខណៈទំនើប មានស្វ័យភាព ប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាពក្នុងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានឆ្លើយតបទៅនឹងតម្រូវការជាអាទិភាពរបស់ប្រជាពលរដ្ឋប្រកបដោយបរិយាបន្ន និងសមធម៌សង្គមក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ។ រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗមានសិទ្ធិអំណាចសមស្រប និងសមត្ថភាពគ្រប់គ្រាន់សម្រាប់អនុវត្តមុខងារទាំងឡាយក្រោមការត្រួតពិនិត្យពីក្រុមប្រឹក្សារបស់ខ្លួន ដើម្បីធានាដល់ការពង្រឹងគណនេយ្យភាពចំពោះប្រជាពលរដ្ឋ។*

ខ្លឹមសារសំខាន់នៃគោលបំណងនេះ គឺ □**រចនាសម្ព័ន្ធ និងប្រព័ន្ធអភិបាលកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិមានលក្ខណៈទំនើប មានស្វ័យភាព ប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព**”។

ដូចគ្នានឹងចក្ខុវិស័យ និងគោលបំណងដែរ កជទី២ ក៏ពុំបានកំណត់សូចនាករ និងចំណុចដៅសម្រាប់ធ្វើមូលដ្ឋានក្នុងការវាយតម្លៃ ឆ្លុះបញ្ចាំងកម្រិតនៃការសម្រេចបានគោលដៅដែលបានកំណត់នេះឡើយ។ ជាមួយគ្នានេះ ឃ្លាគោលដៅវែងពេកដោយរួមបញ្ចូលនូវ ៣ប្រយោគផ្សេងគ្នា។ ប្រការនេះ គោលដៅនៃ កជទី២ គួរត្រូវបានកែសម្រួលឱ្យមានលក្ខណៈងាយយល់ ហើយឆ្លើយតបទៅនឹងគោលបំណងដែលបានកំណត់។ ក្នុងន័យនេះ គោលដៅនៃ កជទី២ គួរពិចារណាផ្តោតលើលទ្ធផល ៣កម្រិតគឺ៖

- រចនាសម្ព័ន្ធ និងប្រព័ន្ធអភិបាលកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិមានភាពទំនើប មានស្វ័យភាព ប្រសិទ្ធភាព តម្លាភាព និងមានគណនេយ្យភាព
- រដ្ឋបាលថ្នាក់ក្រោមជាតិមានមុខងារ ធនធានហិរញ្ញវត្ថុ និងធនធានមនុស្សសមស្រប ដែលធ្វើឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិមានភាពធន់ រឹងមាំ ម្ចាស់ការក្នុងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- រដ្ឋបាលថ្នាក់ក្រោមជាតិមាននីតិវិធីផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានដែលមានលក្ខណៈទំនើប ងាយស្រួល ឆាប់រហ័ស ប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងភាពជឿទុកចិត្ត។

ទន្ទឹមគ្នានេះ ក៏ត្រូវកំណត់សូចនាករ និងចំណុចដៅឱ្យបានច្បាស់លាស់សម្រាប់ជាមូលដ្ឋានក្នុងការអនុវត្ត ការត្រួតពិនិត្យ និងការវាយតម្លៃលើកម្រិតនៃការសម្រេចបាននូវគោលដៅទាំងនេះ។

### ឃ. របកគំហើញពាក់ព័ន្ធនឹងសមិទ្ធផលតាមសមាសភាគនីមួយៗ

ក្នុងឯកសារ កជទី២ បានបែងចែកជា ៥សមាសភាគដែលត្រូវរៀបចំ និងអនុវត្ត ដើម្បីធានាដល់ការសម្រេចបាននូវគោលដៅខាងលើ។ ក្នុងសមាសភាគនីមួយៗបានកំណត់សមិទ្ធផលរំពឹងទុក ដែលត្រូវសម្រេចក្នុងអំឡុង កជទី២។ សមាសភាគទាំង៥ នៃ កជទី២ មានក្នុងតារាងខាងក្រោម៖

| សមាសធាតុ | សមិទ្ធផល |
|---|---|
| សមាសភាគទី១ | យន្តការដឹកនាំ សម្របសម្រួល និងគាំទ្រនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិត្រូវបានពង្រឹង ដើម្បីលើកកម្ពស់ភាពជាម្ចាស់ និងការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិនៅក្នុងការរៀបចំតាក់តែង និងអនុវត្តកម្មវិធីកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព។ |
| សមាសភាគទី២ | រចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង សិទ្ធិអំណាច និងមុខងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានកំណត់យ៉ាងច្បាស់លាស់តាមកម្រិត និងតាមប្រភេទរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗស្របតាមចរិតលក្ខណៈជារដ្ឋបាលតំបន់ទីក្រុងធំ រដ្ឋបាលតំបន់ទីប្រជុំជន និងរដ្ឋបាលតំបន់ជនបទ ដោយជំរុញការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រង ការផ្តល់សេវាសាធារណៈ ការអភិវឌ្ឍមូលដ្ឋាន និងការប្រាស្រ័យទាក់ទងសាធារណៈ។ |
| សមាសភាគទី៣ | រដ្ឋបាលថ្នាក់ក្រោមជាតិមានសិទ្ធិជ្រើសរើស គ្រប់គ្រង ចាត់ចែង និងប្រើប្រាស់បុគ្គលិករបស់ខ្លួនផ្អែកលើទំហំការងារ និងលទ្ធភាពហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ និងមានបុគ្គលិកដែលប្រកបដោយឆន្ទៈម្ចាស់ការ ភក្តីភាព និងមនសិការជំនាញវិជ្ជាជីវៈស្របតាមតួនាទី និងការទទួលខុសត្រូវរបស់ខ្លួន ព្រមទាំងទទួលបានការអភិវឌ្ឍសមត្ថភាព និងជំនាញវិជ្ជាជីវៈជាប្រចាំ។ |
| សមាសភាគទី៤ | រដ្ឋបាលថ្នាក់ក្រោមជាតិមានធនធានថវិកាដែលអាចព្យាករណ៍បាន និងមានទំហំសមស្របទៅនឹងមុខងារ និងអាទិភាពគោលនយោបាយជាតិ ហើយត្រូវបានវិភាជសម្រាប់ការប្រើប្រាស់ប្រកបដោយភាពបត់បែនក្នុងការឆ្លើយតបទៅនឹងតម្រូវការនានាដូចមានកំណត់នៅក្នុងផែនការអភិវឌ្ឍន៍ កម្មវិធីវិនិយោគ និងផែនការយុទ្ធសាស្ត្រថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ |
| សមាសភាគទី៥ | រដ្ឋបាលថ្នាក់ក្រោមជាតិមានយន្តការ នីតិវិធី និងស្តង់ដាសម្រាប់ការផ្តល់សេវាសាធារណៈ ការអភិវឌ្ឍមូលដ្ឋាន និងការប្រាស្រ័យទាក់ទងសាធារណៈប្រកបដោយប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព បរិយាបន្ន និងសមធម៌សង្គមតាមរយៈការអនុវត្តមុខងារជាមុខងារជាជម្រើស និងមុខងារជាកាតព្វកិច្ច ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ |

ទីប្រឹក្សាវាយតម្លៃបានកត់សម្គាល់ឃើញថា ការកំណត់សមិទ្ធផលរំពឹងទុកតាមសមាសភាគនីមួយៗ គឺពុំបានកំណត់នូវសូចនាករ និងចំណុចដៅសម្រាប់ជាមូលដ្ឋានក្នុងការអនុវត្ត ការត្រួតពិនិត្យ និងការ

វាយតម្លៃលើកម្រិតនៃការសម្រេចបាននូវសមិទ្ធផលទាំងនេះ។ ទន្ទឹមគ្នានេះ ឃ្លាសមិទ្ធផលរំពឹងទុកនីមួយៗវែង និងពិបាកចងចាំ។

### ង. លទ្ធផលរំពឹងទុក សកម្មភាពជាអាទិភាព និងសូចនាករ

កជទី២ បានកំណត់លទ្ធផលរំពឹងទុកសរុបចំនួន**៣៧** និងសកម្មភាពជាអាទិភាពចំនួន**១១២** ដោយពុំបានកំណត់សូចនាករតាមលទ្ធផលរំពឹងទុក និងតាមសកម្មភាពជាអាទិភាពនោះឡើយ។ ទោះបី កជទី២ ពុំបានកំណត់សូចនាករក៏ដោយ ក៏ ផអ៥ទី១ បានកំណត់សូចនាករចំនួន**១៦៥** ដែលត្រូវសម្រេចតាមរយៈការអនុវត្តសកម្មភាពជាអាទិភាពនានា។ លទ្ធផលរំពឹងទុក សកម្មភាពជាអាទិភាពនៃ កជទី២ និងសូចនាករដែលបានកំណត់ក្នុង ផអ៥ទី២ មានបង្ហាញសង្ខេបក្នុងតារាងខាងក្រោម៖

តារាង៖ លទ្ធផលរំពឹងទុក សកម្មភាពជាអាទិភាព និងសូចនាករនៃ កជទី២ និង ផអ៥ទី២

| សមាសភាគ | ចំនួនលទ្ធផលរំពឹងទុក | ចំនួនសកម្មភាពជាអាទិភាព | ចំនួនសូចនាករ |
|---|---|---|---|
| **សមាសភាគទី១** | 5 | 24 | 33 |
| **សមាសភាគទី២** | 8 | 25 | 38 |
| **សមាសភាគទី៣** | 10 | 31 | 45 |
| **សមាសភាគទី៤** | 10 | 22 | 36 |
| **សមាសភាគទី៥** | 4 | 10 | 13 |
| **សរុប** | 37 | 112 | 165 |

ពាក់ព័ន្ធនឹងលទ្ធផលរំពឹងទុក សកម្មភាពអាទិភាព និងសូចនាករនៃ ផអ៥ទី១នេះ ទីប្រឹក្សាវាយតម្លៃបានកត់សម្គាល់បញ្ហាមួយចំនួនដូចខាងក្រោម៖

- លទ្ធផលរំពឹងទុកនៅតាមសមាសភាគមួយចំនួន ដូចជា សមាសភាគទី៣ និងសមាសភាគទី៤ មានចំនួនច្រើនពេក និងសកម្មភាពជាអាទិភាពតាមលទ្ធផលរំពឹងទុកមួយចំនួនមានចំនួនច្រើន និងលម្អិតពេក
- សូចនាករតាមលទ្ធផលរំពឹងទុកនីមួយៗនៃ ផអ៥ទី១ មានចំនួនច្រើន និងសូចនាករភាគច្រើនគឺផ្តោតលើសូចនាករបែបបរិមាណ និងមិនផ្តោតលើសូចនាករបែបគុណភាព។

### ៥.២. របកគំហើញពាក់ព័ន្ធនឹងការអនុវត្តកម្មវិធី

ចំពោះការអនុវត្តកម្មវិធីការវាយតម្លៃពាក់កណ្តាលអាណត្តិនៃ កជទី២នេះ ផ្តោតជាសំខាន់លើវឌ្ឍនភាពនៃការអនុវត្តសកម្មភាពជាអាទិភាព និងសូចនាករដែលបានកំណត់ក្នុង ផអ៥ទី១ ដោយហេតុថាសកម្មភាពជាអាទិភាព និងសូចនាករទាំងនេះត្រូវបានប្រើប្រាស់ជាមូលដ្ឋានសម្រាប់រៀបចំ ផ.ស.ថ. ប្រចាំឆ្នាំរបស់ គ.ជ.អ.ប. ដែលត្រូវអនុវត្តដោយស្ថាប័នអនុវត្តនានា។ ទន្ទឹមនេះ វឌ្ឍនភាពនៃការអនុវត្តកម្មវិធីក៏ត្រូវផ្តោតផងដែរទៅលើវឌ្ឍនភាពនៃការលើកកម្ពស់សមភាពយេនឌ័រ បរិយាបន្ន និងសមធម៌សង្គម

ការប្រែប្រួលអាកាសធាតុ គ្រោះមហន្តរាយ និងជំងឺឆ្លងរាតត្បាតកាចសាហាវនានាផងដែរ។

ជារួម គិតត្រឹមឆមាសទី១ ឆ្នាំ២០២៥ សកម្មភាពជាអាទិភាពចំនួន៩០ ស្មើនឹង៨០% នៃសកម្មភាពជាអាទិភាពសរុបចំនួន**១១២** របស់ កជទី២ បានអនុវត្ត ក្នុងនោះសកម្មភាពជាអាទិភាពចំនួន **២៧** ស្មើនឹង២៤% បានអនុវត្តបញ្ចប់ជាស្ថាពរ១០០% តាមផែនការ។ សូចនាករចំនួន**១២៧** ស្មើនឹង **៧៧**% នៃសូចនាករសរុបចំនួន**១៦៥** ត្រូវបានអនុវត្ត ក្នុងនោះសូចនាករចំនួន**៣៨** ស្មើនឹង**២៣**% បានសម្រេចជាស្ថាពរ១០០% តាមការគ្រោងទុក។ លទ្ធផលនេះ ស្របគ្នាជាមួយនឹងលទ្ធផលនៃការវាយតម្លៃជាលក្ខណៈបុគ្គលដោយអ្នកផ្តល់ព័ត៌មាននានាអំពីការអនុវត្ត កជទី២ តាមសមាសភាគនីមួយៗដែលបានឆ្លើយថា ការអនុវត្ត កជទី២ បានសម្រេចជាមធ្យម៨០%។

វឌ្ឍនភាពនៃការអនុវត្តតាមសមាសភាគនីមួយៗនៃ កជទី២ មានពិពណ៌នាដូចខាងក្រោម៖

### ៤.២.១. សមាសភាគទី១ ៖ ការដឹកនាំ និងការសម្របសម្រួលការងារកំណែទម្រង់

សមាសភាគទី១ ផ្តោតលើការបន្តពង្រឹងយន្តការដឹកនាំ សម្របសម្រួលការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីលើកកម្ពស់ភាពជាម្ចាស់ និងការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការរៀបចំ និងអនុវត្តសកម្មភាពជាអាទិភាពនៃកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការឱ្យកាន់តែមានប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព។ សមាសភាគនេះមានលទ្ធផលរំពឹងទុកចំនួន**៥** សកម្មភាពអាទិភាព**២៤** និងសូចនាករចំនួន**៣៣**។

#### ក. វឌ្ឍនភាព

គិតត្រឹមឆមាសទី១ ឆ្នាំ២០២៥ សកម្មភាពចំនួន២៣ ស្មើនឹង៩៦% ត្រូវបានអនុវត្ត ក្នុងនោះមានសកម្មភាពចំនួន**១៣** ស្មើនឹង៥៤% ត្រូវបានអនុវត្តចប់ជាស្ថាពរតាមតាមផែនការ។ សូចនាករចំនួន**៣២** ក្នុងចំណោមសូចនាករសរុបចំនួន**៣៣** ស្មើនឹង**៩៧**% ត្រូវបានអនុវត្ត ក្នុងនោះសូចនាករចំនួន **១៩** ស្មើនឹង៥៨% ត្រូវបានអនុវត្តចប់ជាស្ថាពរតាមផែនការគ្រោងទុក។



ផ្អែកតាមលទ្ធផលនៃការឆ្លើយទៅនឹងបញ្ជីសំណួរជាលក្ខណៈបុគ្គលរបស់អ្នកផ្តល់ព័ត៌មាននានាដែលជាមន្ត្រីថ្នាក់ដឹកនាំក្រសួងស្ថាប័នពាក់ព័ន្ធនៅថ្នាក់ជាតិ ក្រុមប្រឹក្សា មន្ត្រីនៃរដ្ឋបាលថ្នាក់ក្រោមជាតិ និងថ្នាក់ដឹកនាំមន្ទីរជំនាញនៅថ្នាក់រាជធានី ខេត្តចំនួន ២៣២នាក់ បានវាយតម្លៃថា ការអនុវត្តសកម្មភាពនានានៃសមាសភាគទី១ បានសម្រេចជាមធ្យម៨៩% គឺស្ថិតក្នុងចំណាត់ថ្នាក់ពីកម្រិតមធ្យម ល្អ និងល្អប្រសើរ។




សកម្មភាព និងលទ្ធផលគួរឱ្យកត់សម្គាល់សំខាន់ៗដែលបានអនុវត្តមានសង្ខេបដូចខាងក្រោម៖

- គ.ជ.អ.ប. ដែលមានឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃជាប្រធាន បានបន្តជំរុញ និងពង្រឹងការដឹកនាំសម្របសម្រួលក្រសួង ស្ថាប័នពាក់ព័ន្ធនៅថ្នាក់ជាតិ រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការអនុវត្ត កជទី២ ដោយបានរៀបចំកិច្ចប្រជុំ គ.ជ.អ.ប. ចំនួន **៨លើក** ដើម្បីតាមដាន ត្រួតពិនិត្យវឌ្ឍនភាព បញ្ហាប្រឈម ការពិភាក្សា និងពិគ្រោះយោបល់លើសេចក្តីព្រាងគោលនយោបាយ ច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងបទដ្ឋានបច្ចេកទេសសម្រាប់ពង្រឹង និងជំរុញការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ
- ក្នុងឆ្នាំ២០២៣ បន្ទាប់ពីការបង្កើតរាជរដ្ឋាភិបាលអាណត្តិទី៧ គ.ជ.អ.ប. បានពិនិត្យ កែសម្រួលសមាសភាពរបស់ខ្លួនឱ្យស្របទៅនឹងសមាសភាពថ្មីនៃរាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា និងបានបន្ថែមសមាសភាពទេសរដ្ឋមន្ត្រីទទួលបេសកម្មពិសេស ១រូប ឱ្យទទួលបន្ទុកជាអនុប្រធានអចិន្ត្រៃយ៍នៃ គ.ជ.អ.ប. ដើម្បីជំរុញការដឹកនាំ ការសម្របសម្រួលកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់
- ទន្ទឹមគ្នានេះ អនុគណៈកម្មាធិការនានារបស់ គ.ជ.អ.ប. ក៏បានពិនិត្យ និងកែសម្រួល ដោយបានកាត់បន្ថយអនុគណៈកម្មាធិការដែលមានចំនួន៥នាពេលកន្លងមក បង្រួមមកត្រឹមចំនួន៣អនុគណៈកម្មាធិការ រួមមាន (១). អនុគណៈកម្មាធិការមុខងារ និងធនធាន (២). អនុគណៈកម្មាធិការកិច្ចការសារពើពន្ធ និងហិរញ្ញវត្ថុ និង(៣). អនុគណៈកម្មាធិការបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ
- ពីឆ្នាំ២០២១-២០២៥ ក្រោមការដឹកនាំសម្របសម្រួលរបស់ គ.ជ.អ.ប. គោលនយោបាយ ច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងសៀវភៅណែនាំចំនួនជាង**២៥០** ពាក់ព័ន្ធនឹងកំណែទម្រង់វិមជ្ឈការ

និងវិសហមជ្ឈការត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត (សូមមើលឧបសម្ព័ន្ធទី៥)

- ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ក្រោមការដឹកនាំរបស់ គ.ជ.វ.វ. បាននិងកំពុងបន្តខិតខំពង្រឹងភាពម្ចាស់ការ និងការទទួលខុសត្រូវលើការរៀបចំ និងការអនុវត្តផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់ គ.ជ.អ.ប. ដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ គិតរហូតមកដល់បច្ចុប្បន្ននេះ ក្រសួង ស្ថាប័ននៅថ្នាក់ជាតិចំនួន២២ និងរដ្ឋបាលរាជធានី ខេត្តទាំង២៥ បានវិភាជធនធានថវិការបស់ខ្លួនសម្រាប់គាំទ្រដល់ការអនុវត្តសកម្មភាពស្នូលពាក់ព័ន្ធនានាដែលបានកំណត់ក្នុងផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់ គ.ជ.អ.ប.

- រដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសរដ្ឋបាលរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌបានត្រួតពិនិត្យ និងវាយតម្លៃ និងគាំទ្រដល់ការអនុវត្តសកម្មភាពកំណែទម្រង់ក្នុងដែនសមត្ថកិច្ចរបស់ខ្លួនជាប្រចាំតាមយន្តការផ្សេងៗដូចជា កិច្ចប្រជុំប្រចាំខែ ឬប្រចាំត្រីមាស កិច្ចប្រជុំរបស់ក្រុមប្រឹក្សា កិច្ចប្រជុំរបស់គណៈអភិបាល និងកិច្ចប្រជុំពាក់ព័ន្ធផ្សេងទៀត

- ក្នុងឆ្នាំ២០២៤ និងឆ្នាំ២០២៥ ក្រោមគំនិតផ្តួចផ្តើមរបស់**នាយករដ្ឋមន្ត្រីអាណត្តិទី៧** វេទិកាវាងរាជរដ្ឋាភិបាល និងរដ្ឋបាលថ្នាក់ក្រោមជាតិស្តីពី "**កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដើម្បីចូលរួមសម្រេចបានចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០**" ត្រូវបានរៀបចំឡើងក្នុងបំណងរួមគ្នាវាយតម្លៃវឌ្ឍនភាព បញ្ហាប្រឈម និងផ្តល់ការតម្រង់ទិសផ្នែកគោលនយោបាយដើម្បីសម្រួចការអនុវត្តកំណែទម្រង់នេះឱ្យកាន់តែស៊ីជម្រៅ សំដៅចូលរួមអនុវត្តកម្មវិធីនយោបាយ វិធានការគន្លឹះ និងយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ របស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា។ ពាក់ព័ន្ធកិច្ចការនេះ គ.ជ.អ.ប. បានដាក់ចេញសេចក្តីណែនាំ និងផ្តល់ការបណ្តុះបណ្តាលដល់រដ្ឋបាលថ្នាក់ក្រោមជាតិអំពីដំណើរការរៀបចំវេទិកា ដែលត្រូវចាប់ផ្តើមពីការពិនិត្យ និងពិភាក្សាលើសមិទ្ធផល និងបញ្ហាប្រឈមនៃការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅរដ្ឋបាលថ្នាក់ក្រោមជាតិតាមលំដាប់ថ្នាក់នីមួយៗ ដែលកិច្ចដំណើរការនេះត្រូវអនុវត្តពីក្រោមឡើងលើ គឺពីថ្នាក់ឃុំ សង្កាត់ មកក្រុង ស្រុក ខណ្ឌ និងបន្ទាប់មក គឺថ្នាក់រាជធានី ខេត្ត។ រដ្ឋបាលរាជធានី ខេត្តត្រូវរៀបចំវេទិកាបូកសរុបសមិទ្ធផល និងបញ្ហាប្រឈមពីរដ្ឋបាលថ្នាក់ឃុំ សង្កាត់ និងក្រុង ស្រុក ខណ្ឌ ដើម្បីធ្វើសេចក្តីរាយការណ៍ជូន គ.ជ.អ.ប. ពិនិត្យ ពិភាក្សា និងដោះស្រាយតាមរយៈយន្តការអនុគណៈកម្មាធិការនានា ព្រមទាំងធ្វើសេចក្តីរាយការណ៍ជូនអង្គវេទិកានៅថ្នាក់ជាតិ ក្រោមអធិបតីភាពរបស់**សម្តេចនាយករដ្ឋមន្ត្រី**។ ការរៀបចំវេទិកានេះបានប្រើប្រាស់រយៈពេលជិត១ឆ្នាំ ដោយចាប់ផ្តើមពីដើមឆ្នាំ២០២៤ និងបញ្ចប់នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២៥។ ជារួម វេទិកាវាងរាជរដ្ឋាភិបាល និងរដ្ឋបាលថ្នាក់ក្រោមជាតិស្តីពី "**កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដើម្បីចូលរួមសម្រេចបានចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០**"នេះ ដែលបានរៀបចំឡើងនៅថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២៥ ដោយមានអ្នកចូលរួមដោយផ្ទាល់ប្រមាណជាង **១.៤០០នាក់** ដែលមានសមាសភាពមកពីតំណាងព្រឹទ្ធសភា រដ្ឋសភា ក្រុមប្រឹក្សាធម្មនុញ្ញ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត សមាជិករាជរដ្ឋាភិបាល ឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់ ក្រសួង ស្ថាប័ននៃរាជរដ្ឋាភិបាល

រដ្ឋបាលថ្នាក់ក្រោមជាតិ អង្គការសង្គមស៊ីវិល ដៃគូអភិវឌ្ឍន៍ វិស័យឯកជន និងអ្នកពាក់ព័ន្ធនានា ព្រមទាំងមានការចូលរួមតាមប្រព័ន្ធZOOM នៅតាមរដ្ឋបាលរាជធានី ខេត្ត និងរដ្ឋបាលក្រុង ស្រុក ខណ្ឌទាំងអស់ ដែលមានការចូលរួមពីថ្នាក់ដឹកនាំ និងមន្ត្រីនៃរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ មន្ទីរ អង្គភាពជំនាញនានា និងនៅតាមក្រសួងមួយចំនួនសរុបចំនួន **២៣៧គណនី** មានអ្នកចូលរួមសរុបប្រមាណជាង **១០.០០០នាក់**ផងដែរ។ ជារួម ការរៀបចំវេទិកានេះ គឺជាព្រឹត្តិការណ៍ដ៏មានសារៈសំខាន់ ដែលបានបង្ហាញឱ្យឃើញអំពីឆន្ទៈមោះមុតរបស់រាជរដ្ឋាភិបាលអាណត្តិទី៧ ក្នុងការបន្តជំរុញ និងពង្រឹងការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការសម្រាប់រយៈពេលវែង

- លេខាធិការដ្ឋាន គ.ជ.អ.ប. ក៏បានដើរតួនាទីជាសេនាធិការជូន គ.ជ.អ.ប. យ៉ាងសកម្មក្នុងការដឹកនាំ គ្រប់គ្រង ចាត់ចែងការងារប្រចាំថ្ងៃ និងការសម្របសម្រួលកិច្ចសហការជាមួយកម្មវិធីកំណែទម្រង់ស្នូលនានា ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល ដើម្បីកៀរគរការចូលរួម និងការគាំទ្រដល់ការអនុវត្ត កជទី២។ ក្រៅពីការសម្របសម្រួល តាមដាន ត្រួតពិនិត្យលើការរៀបចំ និងអនុវត្តផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់ គ.ជ.អ.ប. លេខាធិការដ្ឋាន គ.ជ.អ.ប. ក្នុងនាមជាប្រធានប្តូរវេន ក៏បានចូលរួមដឹកនាំយន្តការសម្របសម្រួលកម្រិតបច្ចេកទេសនៃកំណែទម្រង់គន្លឹះទាំង៥ ជាអាទិ៍ កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ កំណែទម្រង់រដ្ឋបាលសាធារណៈ កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កំណែទម្រង់ច្បាប់ និងកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ ដើម្បីធានាឱ្យការរៀបចំ និងការអនុវត្តសកម្មភាពជាអាទិភាពនានានៃកម្មវិធីកំណែទម្រង់ស្នូលទាំងនេះមានភាពស៊ីសង្វាក់ ប្រទាក់ក្រឡាគ្នា គាំទ្រ និងបំពេញ ឱ្យគ្នាទៅវិញទៅមក។ កិច្ចប្រជុំប្រចាំត្រីមាសនៃយន្តការនេះត្រូវបានរៀបចំយ៉ាងទៀងទាត់។ ទន្ទឹមគ្នានេះ ឯកសារចក្ខុវិស័យ និងយុទ្ធសាស្ត្រស្តីពី **សុខដុមនីយកម្មកិច្ចការកែទម្រង់គន្លឹះ** ដែលជាផែនការបង្ហាញផ្លូវសម្រាប់ធានាឱ្យភាពប្រទាក់ក្រឡា និងស៊ីសង្វាក់គ្នានៃការរៀបចំ និងការអនុវត្តកម្មវិធីកំណែទម្រង់ស្នូលទាំងនេះ ក៏ត្រូវបានរៀបចំផ្សព្វផ្សាយឱ្យអនុវត្តនាខែកក្កដា ឆ្នាំ២០២៥ ផងដែរ។ ទន្ទឹមគ្នានេះ លេខាធិការដ្ឋាន គ.ជ.អ.ប. ក៏បានរៀបចំកិច្ចប្រជុំជាមួយដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលនានាជាច្រើនលើក ដើម្បីពង្រឹងកិច្ចសហការ និងកៀរគរការគាំទ្រដល់ការរៀបចំ និងការអនុវត្ត កជទី២ ផងដែរ

- ពាក់ព័ន្ធនឹងការបង្កើនការយល់ដឹងអំពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ក៏ត្រូវបានមើលឃើញថា មានផ្សព្វផ្សាយជាប្រចាំដល់ក្រសួង ស្ថាប័ននៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងសាធារណជនតាមរយៈមធ្យោបាយផ្សេងៗមានដូចជា កិច្ចប្រជុំ គ.ជ.អ.ប. វេទិកាសាធារណៈ កិច្ចប្រជុំតាមភូមិជាមួយប្រជាពលរដ្ឋ កិច្ចប្រជុំក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ កិច្ចប្រជុំ គ.ក.ស.ក. កិច្ចប្រជុំ គ.ក.ន.ក. កិច្ចប្រជុំការងាររដ្ឋបាល សិក្ខាសាលា វគ្គបណ្តុះបណ្តាល ការផ្សព្វផ្សាយព័ត៌មានតាមគេហទំព័រ តាមបណ្តាញសង្គម និងព្រឹត្តិការណ៍ពាក់ព័ន្ធផ្សេងទៀត

- ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ និងអង្គការសង្គមស៊ីវិលក៏មានការយល់កាន់តែច្រើនអំពីការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ជាពិសេសពាក់ព័ន្ធនឹងការផ្ទេរមុខងារ ការផ្ទេរ

សិទ្ធិអំណាច ការផ្ទេរធនធានទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការផ្តល់សេវារដ្ឋបាលតាមយន្តការច្រកចេញចូលតែមួយ និងការអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធ គម្រោងសេវាសង្គមរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ល។

– ពាក់ព័ន្ធនឹងការកៀរគរការគាំទ្រពីគម្រោងដាច់ដោយឡែកៗរបស់ដៃគូអភិវឌ្ឍន៍នានា ក៏ត្រូវបានវាយតម្លៃបានថាមានការវិវឌ្ឍជាវិជ្ជមាន ដែលជាមធ្យមគម្រោងដៃគូអភិវឌ្ឍន៍ដែលគាំទ្រការអនុវត្ត កជទី២ មានចំនួន **១៣គម្រោង**ក្នុងមួយឆ្នាំ ពីឆ្នាំ២០២១-២០២៥ ដែលមានថវិកាសរុបចំនួនជាង **១៩៩លានដុល្លារអាមេរិក** មានដូចជា CNP/WB, ISAF/WB, ISAF/CSOs, NALSA/ADB, SNIF/ADB, STA/UNDP, ISD/GIZ, LGCC/UNCDF, Empower/UNEP ។ល។

– ការដឹកនាំ ការសម្របសម្រួល និងការអនុវត្តការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការក្នុងអំឡុងនៃកជទី២នេះ ត្រូវបានមើលឃើញថាមានការវិវឌ្ឍជាវិជ្ជមានក្នុងការសហការជាមួយអង្គការសង្គមស៊ីវិលដោយផ្តល់លើការផ្តល់សេវាសង្គម ដូចជា ការលើកកម្ពស់សុខភាពមាតានិងកុមារ កិច្ចគាំទ្រកុមារ ការងារអាហារូបត្ថម្ភ និងការលើកកម្ពស់សមភាពយេនឌ័រ បរិយាបន្ន និងសមធម៌សង្គម ដែលត្រូវបានបញ្ជ្រាបយ៉ាងពេញលេញក្នុងផែនការសកម្មភាពប្រចាំឆ្នាំរបស់ គ.ជ.អ.ប ក៏ដូចជាផែនការសកម្មភាពប្រចាំឆ្នាំ និងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិផងដែរ។

– ក្នុងអំឡុងពេលនៃការអនុវត្ត កជទី២ ដោយមានការគាំទ្រពី UNDP គ.ជ.អ.ប. បានសម្របសម្រួលជាមួយក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និងវិស័យឯកជនក្នុងការរៀបចំការវាយតម្លៃ និងការអង្កេតចាំបាច់មួយចំនួន ដើម្បីមានមូលដ្ឋានច្បាស់លាស់សម្រាប់ជំរុញ ពង្រឹង និងកែលម្អការអនុវត្ត កជទី២ ក៏ដូចជាការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការទៅពេលអនាគត។ ការវាយតម្លៃ និងការអង្កេតសំខាន់ៗទាំងនោះរួមមាន៖

- ការវាយតម្លៃចុងក្រោយនៃកម្មវិធីជាតិ ដំណាក់កាលទី១ ដែលជាការវាយតម្លៃស៊ីជម្រៅផ្តោតលើវឌ្ឍនភាពកម្រិតលទ្ធផលរំពឹងទុក និងការវិភាគផលជះពីការអនុវត្តកម្មវិធីជាតិដំណាក់កាលទី១ លើជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ការរួមចំណែកកាត់បន្ថយភាពក្រីក្រ ក៏ដូចជាការចូលរួមជំរុញ និងលើកកម្ពស់កំណើនសេដ្ឋកិច្ចជាតិ។ ការវាយតម្លៃនេះក៏បានចងក្រងមេរៀនបទពិសោធន៍អំពីការរៀបចំ និងការអនុវត្តកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការក្នុងបរិបទជាក់ស្តែងនៅកម្ពុជាផងដែរ
- ការអង្កេតអភិបាលកិច្ចដើម្បីបង្កើតសន្ទស្សន៍ដើមគ្រាផ្នែកអភិបាលកិច្ច សន្ទស្សន៍ដើមគ្រានៃការផ្តល់សេវា និងសន្ទស្សន៍ដើមគ្រាសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក៏ត្រូវបានរៀបចំ និងអនុវត្តនៅក្នុងឆ្នាំ២០២៥។ ជាលទ្ធផល សន្ទស្សន៍ដើមគ្រាផ្នែកអភិបាលកិច្ច គឺមានតម្លៃស្មើនឹង**០,៦៤** ចំណាត់ថ្នាក់ **បង្គួរ** សន្ទស្សន៍ដើមគ្រាការផ្តល់សេវាមានតម្លៃស្មើនឹង**០,៦៩** ចំណាត់ថ្នាក់ **បង្គួរ** និងសន្ទស្សន៍ដើមគ្រាសមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិមានតម្លៃស្មើនឹង**០,៧៥** ចំណាត់ថ្នាក់ **ល្អ**។ សន្ទស្សន៍ដើមគ្រាទាំងនេះ គឺ

ជាមូលដ្ឋានសម្រាប់ការវាស់វែង ការប្រែប្រួលគុណភាពអភិបាលកិច្ច គុណភាពការផ្តល់សេវា និងសមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងក្របខណ្ឌនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

- ការវាយតម្លៃពាក់កណ្តាលអាណត្តិនៃកម្មវិធីជាតិ ដំណាក់កាលទី២ ក៏ត្រូវបានរៀបចំនៅក្នុងឆ្នាំ២០២៥នេះផងដែរ។ គោលបំណងសំខាន់នៃការវាយតម្លៃពាក់កណ្តាលអាណត្តិនេះគឺដើម្បីឆ្លុះបញ្ចាំងអំពីវឌ្ឍនភាព និងបញ្ហាប្រឈមនៃការអនុវត្តកម្មវិធីជាតិ ដំណាក់កាលទី២ រយៈពេល៥ឆ្នាំកន្លងមកសម្រាប់ធ្វើជាមូលដ្ឋានក្នុងការរៀបចំផែនការអនុវត្តរយៈពេល៥ឆ្នាំបន្ទាប់ (២០២៦-២០៣០) ឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់។

– សមាគមរដ្ឋបាលថ្នាក់ក្រោមជាតិ ក៏មានដំណើរការល្អប្រសើរ ដោយបានរៀបចំមហាសន្និបាតរៀងរាល់ប្រាំឆ្នាំម្តង ផ្អែកតាមការកំណត់នៃលក្ខន្តិកៈរបស់ខ្លួន ដើម្បីបោះឆ្នោតជ្រើសរើសអង្គអភិបាលកិច្ច ក៏ដូចជាអនុម័តលើឯកសារចាំបាច់ផ្សេងៗ ដូចជាការធ្វើវិសោធនកម្មលក្ខន្តិកៈ ផែនការយុទ្ធសាស្ត្ររបស់សមាគមក្នុងអាណត្តិថ្មី ដោយបានពិនិត្យ និងអនុម័តលើរចនាសម្ព័ន្ធនៃអង្គអភិបាលកិច្ចថ្នាក់ដឹកនាំ គណៈកម្មាធិការប្រតិបត្តិ និងក្រុមប្រឹក្សាជាតិរបស់ខ្លួន។

– សមាគមក្រុមប្រឹក្សាខណ្ឌ សង្កាត់ និងសមាគមក្រុមប្រឹក្សាក្រុង ស្រុក ឃុំ សង្កាត់ថ្នាក់រាជធានី ខេត្ត និងសាខាសមាគមនៅថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវបានបង្កើត និងបានដំណើរការក្នុងការអភិវឌ្ឍសមត្ថភាព (ដូចជាការរៀបចំវគ្គបណ្តុះបណ្តាលសម្រាប់សមាជិកថ្មី) និងគាំទ្រសមាជិករបស់ខ្លួន ដោយសហការជិតស្និទ្ធជាមួយរដ្ឋបាលរាជធានី ខេត្ត។

លទ្ធផលលម្អិតដែលសម្រេចបានតាមសកម្មភាពនីមួយៗមានរៀបរាប់ក្នុងឧបសម្ព័ន្ធទី២ និងទី៣។

### ខ. សកម្មភាពជាអាទិភាពដែលមិនទាន់បានអនុវត្ត

ផ្អែកតាមរបាយការណ៍ប្រចាំឆ្នាំស្តីពីការអនុវត្ត ផ.ស.ថ. របស់ គ.ជ.អ.ប. ពីឆ្នាំ២០២១-២០២៥ សកម្មភាពជាអាទិភាពក្នុងសមាសភាគទី១ ដែលមិនទាន់បានអនុវត្តមានចំនួន១ គឺសកម្មភាពដែលពាក់ព័ន្ធនឹងការសិក្សាជម្រើសនានាអំពីតួនាទី គ.ជ.អ.ប. និងលេខាធិការដ្ឋាន គ.ជ.អ.ប. ក្នុងការដឹកនាំ សម្របសម្រួល និងការគាំទ្រដល់កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនាពេលអនាគត។

### គ. បញ្ហាប្រឈម

ទន្ទឹមនឹងលទ្ធផលសម្រេចបានខាងលើ ផ្អែកតាមរបាយការណ៍ប្រចាំឆ្នាំស្តីពីការអនុវត្ត ផ.ស.ថ. របស់ គ.ជ.អ.ប. ពីឆ្នាំ២០២១-២០២៥ និងកិច្ចប្រជុំពិភាក្សាជាមួយក្រុមប្រឹក្សា មន្ត្រីថ្នាក់ដឹកនាំនៃរដ្ឋបាលថ្នាក់ក្រោមជាតិបានបង្ហាញឱ្យឃើញថា ការអនុវត្តសមាសភាគទី១ បានជួបនូវបញ្ហាប្រឈមសំខាន់ៗមួយចំនួនដូចខាងក្រោម៖

– វិបត្តិដែលកើតឡើងដោយសារការរីករាលដាលនៃជំងឺកូវីដ-១៩ បានធ្វើឱ្យផ្អាក និងពន្យារពេលការអនុវត្ត កជទី២ រហូតដល់ដើមឆ្នាំ២០២២។ ប្រការនេះ បានធ្វើឱ្យទាំងរាជធានី ខេត្ត និងក្រសួង ស្ថាប័នពាក់ព័ន្ធនៅថ្នាក់ជាតិមិនអាចចុះផ្តល់អន្តរាគមន៍គាំទ្រទាំងការអភិវឌ្ឍសមត្ថភាព និងការគាំទ្រផ្នែកបច្ចេកទេសដល់រដ្ឋបាលក្រុង ស្រុក ខណ្ឌក្នុងការអនុវត្តមុខងារ និងរចនាសម្ព័ន្ធថ្មីរបស់ខ្លួនដែលទើបនឹងកែសម្រួលនៅចុងឆ្នាំ២០១៩ និងដើមឆ្នាំ២០២០

– វិបត្តិសកលដែលបង្កឡើងដោយប្រទេសមហាអំណាចនានា ក៏បានផ្តល់ផលប៉ះពាល់ដល់សកម្មភាពសេដ្ឋកិច្ច និងចំណូលថវិការដ្ឋ ក្នុងនោះរួមមានថវិកាដែលត្រូវវិភាជឱ្យទៅរដ្ឋបាលថ្នាក់ក្រោមជាតិ

– វិបត្តិពាក់ព័ន្ធនឹងជម្លោះព្រំដែនរវាងកម្ពុជា-ថៃនាពេលថ្មីៗនេះ ក៏កំពុងបន្តការរំខានដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការអនុវត្តផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់ គ.ជ.អ.ប. ដោយត្រូវផ្តល់អាទិភាពទៅលើការចាត់វិធានការ ថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ការផ្តល់អន្តរាគមន៍ជួយគ្រួសារភៀសសឹក និងពលករដែលវិលត្រឡប់មកពីប្រទេសថៃវិញ

– បើទោះបី ការយល់ដឹងអំពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ជាទូទៅមានការកើនឡើង ក៏ប៉ុន្តែការស្គាល់ ការចងចាំ ឬការយល់ដឹងអំពី កជទី២ ជាពិសេសនៅរដ្ឋបាលថ្នាក់ក្រោមជាតិហាក់នៅមានកម្រិតទាបគួរឱ្យកត់សម្គាល់។ ថ្នាក់ដឹកនាំ និងមន្ត្រីភាគច្រើននៃរដ្ឋបាលថ្នាក់ក្រោមជាតិនៅមានការចងចាំយ៉ាងច្បាស់ "ផអ៣" ដែលជាផែនការអនុវត្ត៣ឆ្នាំតាមដំណាក់កាលនីមួយៗនៃកម្មវិធីជាតិដំណាក់កាលទី១ (កជទី១)។ ប្រការនេះបង្ហាញថា ការផ្សព្វផ្សាយអំពី កជទី២ នៅមានកម្រិតទាប

– ជាទូទៅ រដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសរដ្ឋបាលរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌភាគច្រើនដែលក្រុមការងារវាយតម្លៃបានចុះជួប បានរាយការណ៍ថា យន្តការ គ.ជ.វ.វ. មិនមានដំណើរការឡើយ ក៏ប៉ុន្តែការដឹកនាំ ការគ្រប់គ្រង និងការអនុវត្តសកម្មភាពកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការជាពិសេសការរៀបចំ និងការអនុវត្តផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់ គ.ជ.អ.ប. ក្នុងអំឡុងពេលនៃ កជទី២ ត្រូវបានដឹកនាំ គ្រប់គ្រងសម្របសម្រួលដោយយន្តការស្ថាប័នដែលមានស្រាប់ ដូចជាកិច្ចប្រជុំក្រុមប្រឹក្សា កិច្ចប្រជុំគណៈអភិបាល កិច្ចប្រជុំគណៈកម្មាធិការនានា និងការងារប្រចាំថ្ងៃរបស់អង្គភាពចំណុះនៃរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ

– ផ.ស.ថ. ប្រចាំឆ្នាំរបស់រដ្ឋបាលរាជធានី ខេត្តមានបញ្ចូលថវិកាតិចតួចនៃសកម្មភាពកំណែទម្រង់ស្នូលរបស់មន្ទីរ អង្គភាពជំនាញពាក់ព័ន្ធនានា

– សមាជិកនៃសមាគមក្រុមប្រឹក្សាក្រុង ស្រុក ឃុំ សង្កាត់ រួមទាំងអ្នកពាក់ព័ន្ធមួយចំនួននៅមិនទាន់យល់អំពីបេសកកម្ម តួនាទី និងភារកិច្ចរបស់សមាគម ព្រមទាំងសកម្មភាពនានាដែលសមាគមបានអនុវត្ត។

### ៥.២.២. សមាសភាគទី២ ៖ រចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ

សមាសភាគទី២ ផ្តោតលើការកែសម្រួលមុខងារ រចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង ធនធាន និងសិទ្ធិ

អំណាចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិឱ្យស្របតាមចរិតលក្ខណៈរដ្ឋបាលនៃតំបន់ទីក្រុងធំ រដ្ឋបាលទីប្រជុំជន និងរដ្ឋបាលតំបន់ជនបទ ដោយជំរុញការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការផ្តល់សេវា និងការប្រាស្រ័យទាក់ទងសាធារណៈ ដើម្បីធានាឆ្លើយតបទៅនឹងការវិវឌ្ឍយ៉ាងឆាប់រហ័សនៃសកម្មភាពសេដ្ឋកិច្ច នគរូបនីយកម្ម បច្ចេកវិទ្យាព័ត៌មានវិទ្យា និន្នាការបម្លាស់ទីរបស់ប្រជាពលរដ្ឋមកកាន់ទីប្រជុំជន ការកើនឡើងនៃតម្រូវការសេវាសង្គម និងការកាត់បន្ថយហានិភ័យនានាដែលបង្កឡើងដោយគ្រោះធម្មជាតិ ការប្រែប្រួលអាកាសធាតុ និងវិបត្តិជាសកល។

សមាសភាគទី២នេះ មានលទ្ធផលរំពឹងទុកចំនួន៨ សកម្មភាពជាអាទិភាពចំនួន**២៥** និងសូចនាករចំនួន**៣៨**។

### ក. វឌ្ឍនភាព




គិតត្រឹមឆមាសទី១ ឆ្នាំ២០២៥ សកម្មភាពចំនួន**១៩** ស្មើនឹង**៧៦**% ត្រូវបានអនុវត្ត ក្នុងនោះមានសកម្មភាពចំនួន**២** ស្មើនឹង៨% ត្រូវបានអនុវត្តចប់ជាស្ថាពរតាមផែនការកំណត់។ សូចនាករចំនួន**២៨** ក្នុងចំណោម សូចនាករសរុបចំនួន**៣៨** ស្មើនឹង**៧៤**% ត្រូវបានអនុវត្ត ក្នុងនោះ សូចនាករចំនួន**២** ស្មើនឹង**៥**% ត្រូវបានសម្រេចតាមផែនការគ្រោងទុក។




ផ្អែកតាមលទ្ធផលនៃការឆ្លើយទៅនឹងបញ្ជីសំណួរជាលក្ខណៈបុគ្គលរបស់អ្នកផ្តល់ព័ត៌មាននានាដែលជាមន្ត្រីថ្នាក់ដឹកនាំក្រសួង ស្ថាប័នពាក់ព័ន្ធនៅថ្នាក់ជាតិ ក្រុមប្រឹក្សា មន្ត្រីនៃរដ្ឋបាលថ្នាក់ក្រោមជាតិ និងថ្នាក់ដឹកនាំមន្ទីរជំនាញនៅថ្នាក់រាជធានីខេត្តចំនួន ២៦៥នាក់ បានវាយតម្លៃថាការអនុវត្តសកម្មភាពនានានៃសមាសភាគទី២ សម្រេចជាមធ្យមបាន**៧៣**% (ចំណាត់ថ្នាក់វាយតម្លៃពីកម្រិតមធ្យម ល្អ និងល្អប្រសើរ)។

សកម្មភាពជាអាទិភាពសំខាន់ៗដែលបានអនុវត្តរួមមានសង្ខេបដូចខាងក្រោម៖

- រដ្ឋបាលក្រុង ស្រុក ខណ្ឌបានខិតខំបំពេញការងារតាមមុខងារ និងរចនាសម្ព័ន្ធថ្មីរបស់ខ្លួន

ដែលបានរៀបចំឡើងវិញនាចុងឆ្នាំ២០១៩ និងដើមឆ្នាំ២០២០ តាមរយៈការធ្វើសមាហរណកម្ម ការិយាល័យខ្សែបណ្ដោយរបស់ក្រសួង ស្ថាប័នចូលទៅក្នុងរចនាសម្ព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌស្របតាមគោលការណ៍នៃរដ្ឋបាលឯកភាព។ ជារួម ក្រុមប្រឹក្សា គណៈអភិបាល និងមន្ត្រីនៃរដ្ឋបាល ក្រុង ស្រុក បានបង្ហាញពីភាពពេញចិត្តចំពោះមុខងារ និងរចនាសម្ព័ន្ធថ្មីរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ដោយភាគច្រើនបានលើកឡើងថា រចនាសម្ព័ន្ធថ្មីនេះមានលក្ខណៈសមស្រប និងបានធ្វើឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌអាចប្រមូលផ្ដុំកម្លាំង និងគ្រប់គ្រងបុគ្គលិកមានប្រសិទ្ធភាពល្អជាងមុន ព្រមទាំងបានធ្វើឱ្យ រដ្ឋបាលក្រុង ស្រុក ខណ្ឌពិតជាមានសមត្ថភាព និងលទ្ធភាពក្នុងការផ្ដល់សេវាសាធារណៈ និងអន្តរាគមន៍ ដោះស្រាយបញ្ហា និងការលំបាកនានារបស់ប្រជាពលរដ្ឋបានច្រើន និងមានប្រសិទ្ធភាពជាងមុន

- ទន្ទឹមគ្នានេះ ការដឹកនាំ ការគ្រប់គ្រង និងការសម្រេចចិត្តនានារបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ក៏ត្រូវបានលើកឡើងថា មានលក្ខណៈល្អប្រសើរជាងមុន ដោយសារមានការពិគ្រោះ ពិភាក្សា និងការផ្ដល់ មតិយោបល់ពីមន្ត្រីការិយាល័យ/អង្គភាពជំនាញតាមវិស័យនានាចំណុះឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌសាមី នីមួយៗ។ ទំនាក់ទំនងការងារផ្ទៃក្នុង និងផ្ទៃក្រៅនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌក៏ត្រូវបានមើលឃើញថា មានលក្ខណៈកាន់តែល្អប្រសើរជាបណ្ដើរៗផងដែរ

- ចំពោះការដឹកនាំ ការគ្រប់គ្រងការអនុវត្តមុខងារអប់រំ យុវជន និងកីឡារបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌក៏បានបង្ហាញឱ្យឃើញថា មានដំណើរការកាន់តែល្អប្រសើរជាងមុន ជាពិសេសការប្រើប្រាស់ថវិកា មានភ្ជាប់លក្ខខណ្ឌរបស់ការិយាល័យអប់រំ យុវជន និងកីឡា និងថវិកាដំណើរការគ្រឹះស្ថានសិក្សានានា ត្រូវបានលើកឡើងថា បានផ្ទេរទាន់ពេលវេលា និងបានប្រើប្រាស់តាមលក្ខខណ្ឌដែលបានកំណត់។ ទិន្នន័យដើមគ្រាពាក់ព័ន្ធនឹងការអនុវត្តមុខងារអប់រំ យុវជន និងកីឡាក៏ត្រូវបានរៀបចំសម្រាប់ជាមូលដ្ឋាន ក្នុងការវាយតម្លៃលើការអនុវត្តមុខងារអប់រំ យុវជន និងកីឡារបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌផងដែរ

- ជារួម ទាំងក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិមានភាពពេញចិត្តចំពោះការរៀបចំ រដ្ឋបាលក្រុង ស្រុក ខណ្ឌឱ្យក្លាយជារដ្ឋបាលមូលដ្ឋានស្របតាមគោលការណ៍នៃរដ្ឋបាលឯកភាព ដែល ធ្វើឱ្យរដ្ឋបាលក្រុង ស្រុកមានសិទ្ធិអំណាច ធនធាន និងការទទួលខុសត្រូវកាន់តែច្បាស់លាស់ទាំងទៅ លើការងាររដ្ឋបាលដែនដី និងការងារតាមវិស័យជំនាញនានាក្នុងការផ្ដល់សេវាសាធារណៈ និងការអភិវឌ្ឍ មូលដ្ឋានជូនប្រជាពលរដ្ឋ។ ទោះយ៉ាងនេះក្ដី គ្រប់រដ្ឋបាលក្រុង ស្រុក ខណ្ឌដែលក្រុមការងារវាយតម្លៃ បានចុះជួប បានលើកឡើងអំពីការខ្វះទាំងចំនួនបុគ្គលិក ជំនាញបច្ចេកទេស និងធនធានថវិកាសម្រាប់ អនុវត្តមុខងារតាមវិស័យនានាដែលបានផ្ទេរឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ លើកលែងមុខងារអប់រំ យុវជន និងកីឡា

- ការសម្របសម្រួល កិច្ចសហការ និងទំនាក់ទំនងការងាររវាងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ក៏ដំណើរការបានល្អ។ រដ្ឋបាលខេត្ត និងក្រុង ស្រុកបានចុះត្រួតពិនិត្យ និងគាំទ្រផ្នែក បច្ចេកទេសជាប្រចាំដល់រដ្ឋបាលឃុំ សង្កាត់ ជាពិសេសការកសាងផែនការ និងកម្មវិធីវិនិយោគ ការរៀបចំ និងអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ និងការចូលរួមកិច្ចប្រជុំនានារបស់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ

ការរៀបចំវេទិកាពិគ្រោះយោបល់ជាធារណៈជាដើម

– នៅរដ្ឋបាលរាជធានី ខេត្ត កិច្ចការដែលមានការវិវឌ្ឍខ្លាំងគួរឱ្យកត់សម្គាល់នៅក្នុងអំឡុងពេលនៃការអនុវត្ត កជទី២ រយៈពេល៥ឆ្នាំនេះ គឺប្រសិទ្ធភាពនៃការគ្រប់គ្រងការផ្តល់សេវាសុខាភិបាលដែលបានផ្ទេរទៅឱ្យរដ្ឋបាលរាជធានី ខេត្ត។ ក្រុមប្រឹក្សា គណៈអភិបាល ប្រធានមន្ទីរសុខាភិបាលរាជធានី ខេត្ត មន្ត្រីពាក់ព័ន្ធ និងតំណាងអង្គការសង្គមស៊ីវិលស្ទើរតែគ្រប់គ្នាដែលក្រុមការងារវាយតម្លៃបានជួបពិភាក្សា បានលើកឡើងអំពីភាពប្រែប្រួលជាវិជ្ជមានចំពោះប្រសិទ្ធភាពនៃការគ្រប់គ្រងការផ្តល់សេវាសុខាភិបាលនៅតាមមន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាព បន្ទាប់ពីការផ្ទេរមុខងារនេះមកស្ថិតក្រោមការគ្រប់គ្រងរបស់រដ្ឋបាលរាជធានី ខេត្ត។ ជារួម ត្រូវបានសង្កេតឃើញថា ប្រជាពលរដ្ឋដែលមកទទួលសេវានៅតាមមណ្ឌលសុខភាព និងមន្ទីរពេទ្យបង្អែកមានចំនួនកាន់តែច្រើនឡើង នៅតាមមណ្ឌលសុខភាពបានរៀបចំឱ្យមានបុគ្គលិកប្រចាំការ២៤ម៉ោងក្នុង១ថ្ងៃ និង៧ថ្ងៃក្នុងមួយសប្តាហ៍ អាកប្បកិរិយារបស់បុគ្គលិកពេទ្យមានភាពរួសរាយ រាក់ទាក់ ទន់ភ្លន់ និងមានក្រមសីលធម៌វិជ្ជាជីវៈ។

– អ្នកផ្តល់ព័ត៌មានមួយចំនួនដែលក្រុមការងារវាយតម្លៃបានជួប បានលើកឡើងនូវហេតុផលមួយចំនួនដែលធ្វើឱ្យមានការប្រែប្រួលជាវិជ្ជមានក្នុងការផ្តល់សេវាសុខាភិបាល គឺទាំងក្រសួងសុខាភិបាលក្នុងអាណត្តិទី៧នេះ បានផ្តោតការយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការជំរុញ និងគាំទ្រទាំងផ្នែកបច្ចេកទេស សមត្ថភាព ការបើកផ្តល់ឱសថ សម្ភារបរិក្ខារដល់មន្ទីរពេទ្យ និងមណ្ឌលសុខភាពទូទាំងប្រទេស។ ក្រុមប្រឹក្សា និងគណៈអភិបាលរាជធានី ខេត្តក៏បានផ្តោតការយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការជំរុញតាមដាន ត្រួតពិនិត្យការផ្តល់សេវានៅតាមមន្ទីរពេទ្យ និងមណ្ឌលសុខភាព តាមរយៈកិច្ចប្រជុំក្រុមប្រឹក្សាប្រចាំខែ និងការចុះត្រួតពិនិត្យជាក់ស្តែងនៅតាមមន្ទីរពេទ្យ និងមណ្ឌលសុខភាពជាដើម។ ការអនុវត្តការងារគណនេយ្យភាពសង្គម ដែលតម្រូវឱ្យប្រជាពលរដ្ឋតាមសហគមន៍ចូលរួមវាយតម្លៃអំពីប្រសិទ្ធភាពនៃការផ្តល់សេវាសុខភាពនៅតាមមណ្ឌលសុខភាពនានាក៏ជាកត្តាដ៏មានសារៈសំខាន់មួយដែលជួយធ្វើឱ្យប្រសិទ្ធភាព និងគុណភាពនៃការផ្តល់សេវាតាមមណ្ឌលសុខភាពកាន់តែមានភាពល្អប្រសើរ

– ពាក់ព័ន្ធនឹងការសិក្សាអំពីជម្រើសនានាសម្រាប់កែសម្រួលមុខងារ និងរចនាសម្ព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលរាជធានីឱ្យក្លាយជារដ្ឋបាលទីក្រុងមេត្រូប៉ូលីតែន និងរដ្ឋបាលខេត្តឱ្យក្លាយជារដ្ឋបាលតំបន់ក៏មានការរីកចម្រើនគួរឱ្យកត់សម្គាល់។ លេខាធិការដ្ឋាន គ.ជ.អ.ប. បានរៀបចំឯកសារទស្សនាទានសម្រាប់ការសិក្សានេះ ដោយទទួលបានការឯកភាពពីប្រធាន គ.ជ.អ.ប. នៅចុងឆ្នាំ២០២៣។ ផ្អែកតាមឯកសារទស្សនាទាននេះ លេខាធិការដ្ឋាន គ.ជ.អ.ប. សហការជាមួយក្រសួងមហាផ្ទៃ ក្រសួងមុខងារសាធារណៈ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងផែនការបានសិក្សា ស្រាវជ្រាវលើឯកសារពាក់ព័ន្ធព្រមទាំងបានប្រមូលចងក្រងមេរៀនបទពិសោធន៍ដែលមានជាលក្ខណៈអន្តរជាតិពីបណ្តាប្រទេសនានាទាំងនៅក្នុង និងក្រៅតំបន់។ ទន្ទឹមគ្នានេះ ក៏បានធ្វើទស្សនកិច្ចសិក្សាដោយផ្ទាល់នៅតាមបណ្តាប្រទេសមួយចំនួនរួមមានដូចជា ប្រទេសអាល្លឺម៉ង់ ស៊ុយអែត ឥណ្ឌូនេស៊ីជាដើម។ ជាមួយគ្នានេះ ការសិក្សាវាយតម្លៃលើស្ថានភាពនៃការអនុវត្តមុខងារ និងរចនាសម្ព័ន្ធគ្រប់គ្រងបច្ចុប្បន្នរបស់រដ្ឋបាលរាជធានី ខេត្ត ក៏បាននិង

កំពុងអនុវត្តជាបណ្តើរៗនៅក្នុងឆមាសទី២ ឆ្នាំ២០២៥នេះ

– ការងារគណនេយ្យភាពសង្គមត្រូវបានមើលឃើញថា ជាកិច្ចការដ៏មានសារៈសំខាន់ និងទទួលបានការគាំទ្រយ៉ាងច្រើនពីក្រសួង ស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលនៅក្នុងអំឡុងពេលនៃការអនុវត្ត កជទី២ ផងដែរ។ ជារួម ការងារគណនេយ្យភាពសង្គមត្រូវបានបន្តពង្រីក និងអនុវត្តក្នុងឃុំ សង្កាត់គោលដៅចំនួន**៩៣**% នៃចំនួនឃុំ សង្កាត់សរុបទូទាំងប្រទេស ដោយសហការយ៉ាងជិតស្និទ្ធជាមួយអង្គការដៃគូនានា មានដូចជា WVI, OXFAM, FHI 360, CARE។ ការវាយតម្លៃបញ្ចប់គម្រោងគាំទ្រការងារគណនេយ្យភាពសង្គមមួយដែលបានធ្វើឡើងកាលពីខែតុលា ឆ្នាំ២០២៤ បង្ហាញឱ្យឃើញថា តាមរយៈការអនុវត្តការងារគណនេយ្យភាពសង្គម រួមមាន**៩២**% នៃប្រជាពលរដ្ឋពេញចិត្ត និងបានចូលរួមយ៉ាងសកម្មក្នុងការលើកកម្ពស់ការបំពេញការងារ ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានដែលផ្តល់ដោយអង្គភាពផ្តល់សេវាទាំង៣ គឺរដ្ឋបាលឃុំ សង្កាត់ មណ្ឌលសុខភាព និងសាលាបឋមសិក្សា

– យន្តការផ្តល់សេវារដ្ឋបាលតាមច្រកចេញចូលតែមួយនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ក៏បានពង្រឹង និងកែលម្អនីតិវិធីផ្តល់សេវាឱ្យកាន់តែមានលក្ខណៈងាយស្រួល ឆាប់រហ័ស តម្លាភាព និងគណនេយ្យភាព ជាពិសេសនៅថ្នាក់រាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌមួយចំនួនបានធ្វើទំនើបកម្មប្រព័ន្ធ និងនីតិវិធីផ្តល់សេវារដ្ឋបាល និងការទូទាត់ថ្លៃសេវារដ្ឋបាលក្នុងវិស័យមួយចំនួនតាមប្រព័ន្ធអនឡាញ។ ផ្អែកតាមលទ្ធផលនៃការអង្កេតអភិបាលកិច្ចដែលបានអនុវត្តនៅក្នុងឆ្នាំ២០២៤ បានបង្ហាញឱ្យដឹងថា សន្ទស្សន៍នៃភាពពេញចិត្តរបស់ប្រជាពលរដ្ឋចំពោះការផ្តល់សេវារដ្ឋបាលតាមយន្តការច្រកចេញចូលតែមួយនៅតាមរដ្ឋបាលថ្នាក់ក្រោមជាតិ គឺមានតម្លៃ**០,៦៧** ក្នុងចំណាត់ថ្នាក់ល្អបង្គួរ

– ក្នុងការជំរុញការផ្សព្វផ្សាយព័ត៌មាន និងការលើកកម្ពស់ការប្រាស្រ័យទាក់ទងរវាងរដ្ឋបាលថ្នាក់ក្រោមជាតិជាមួយប្រជាពលរដ្ឋ ក៏ត្រូវបានលើកឡើងថា មានការវិវឌ្ឍជាវិជ្ជមាន ដោយរដ្ឋបាលថ្នាក់ក្រោមជាតិភាគច្រើនបានបង្កើត និងដាក់ឱ្យដំណើរការប្រព័ន្ធព័ត៌មានវិទ្យាដូចជា Website, Facebook, Telegram... ដើម្បីផ្សព្វផ្សាយ និងទំនាក់ទំនងការងាររបស់ខ្លួន

– ចំពោះយន្តការទទួល ប្រមូលបណ្តឹង និងសម្រុះសម្រួលដោះស្រាយបណ្តឹងក្រៅប្រព័ន្ធតុលាការក៏កំពុងដំណើរការអនុវត្តយ៉ាងសកម្ម តាមរយៈការិយាល័យប្រជាពលរដ្ឋ។ ជាមធ្យម បណ្តឹងក្នុងសមត្ថកិច្ចចំនួន៨០% ត្រូវបានសម្រុះសម្រួល និងដោះស្រាយជារៀងរាល់ឆ្នាំ។

លទ្ធផលលម្អិតដែលសម្រេចបានតាមសកម្មភាពនីមួយៗមានរៀបរាប់ក្នុងឧបសម្ព័ន្ធទី២ និងទី៣។

### ខ. សកម្មភាពជាអាទិភាពដែលមិនទាន់បានអនុវត្ត

ផ្អែកតាមរបាយការណ៍ប្រចាំឆ្នាំស្តីពីការអនុវត្ត ផ.ស.ថ. របស់ គ.ជ.អ.ប. ពីឆ្នាំ២០២១-២០២៥ សកម្មភាពជាអាទិភាពក្នុងសមាសភាគទី២ ដែលមិនទាន់បានចាប់ផ្តើមអនុវត្តមានចំនួន**៦** គឺ៖

– ការពិនិត្យ និងការកែលម្អរចនាសម្ព័ន្ធ មុខងារ និងធនធានរបស់រដ្ឋបាលក្រុង ស្រុក និងឃុំ

សង្កាត់ស្ថិតនៅក្នុងតំបន់ទីប្រជុំជន

- ការពិនិត្យ និងការសម្រួលរចនាសម្ព័ន្ធ មុខងារ និងធនធានរបស់រដ្ឋបាលស្រុក និងឃុំស្ថិតនៅក្នុងតំបន់ជនបទ
- ការពិនិត្យ កែសម្រួល និងពង្រឹងទំនាក់ទំនងការងារ និងគណនេយ្យភាពរវាងរដ្ឋបាលថ្នាក់ក្រោមជាតិ និងរដ្ឋបាលថ្នាក់ជាតិ
- ការពង្រឹងទំនាក់ទំនងការងារ និងខ្សែគណនេយ្យភាពរវាងរដ្ឋបាលថ្នាក់ក្រោមជាតិដែលមានកម្រិតខុសៗគ្នា
- ការកែសម្រួល និងការបង្កើតគណៈកម្មាធិការនានាបន្ថែមទៀតរបស់ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ
- ការពង្រឹងលេខាធិការដ្ឋានរបស់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ។

### គ. បញ្ហាប្រឈម

ផ្អែកតាមរបាយការណ៍ប្រចាំឆ្នាំស្ដីពីការអនុវត្ត ផ.ស.ថ. របស់ គ.ជ.អ.ប. ពីឆ្នាំ២០២១-២០២៥ និងការជួបប្រជុំពិភាក្សាជាមួយក្រុមប្រឹក្សា ថ្នាក់ដឹកនាំ មន្ត្រីនៃរដ្ឋបាលថ្នាក់ក្រោមជាតិបានបង្ហាញឱ្យឃើញថា ការអនុវត្តសមាសភាគទី២ បានជួបបញ្ហាប្រឈមជាគន្លឹះមួយចំនួនដូចខាងក្រោម៖

- ចំពោះមុខងារ និងរចនាសម្ព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ទោះបីមានការលើកឡើងភាគច្រើនថា មុខងារ និងរចនាសម្ព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌបច្ចុប្បន្នមានលក្ខណៈសមស្របទៅនឹងតម្រូវការជាក់ស្ដែង ព្រមទាំងធ្វើឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌមានការទទួលខុសត្រូវកាន់តែច្បាស់លាស់ទាំងលើការងាររដ្ឋបាលដែនដី និងការផ្ដល់សេវាសាធារណៈតាមវិស័យជំនាញនានាក៏ដោយ ក៏ប៉ុន្តែអង្គភាពចំណុះមួយចំនួនមិនទាន់អាចបំពេញការងារតាមតួនាទី ភារកិច្ចរបស់ខ្លួនបាននៅឡើយ ដូចជាការិយាល័យត្រួតពិនិត្យផ្ទៃក្នុង និងការិយាល័យនីតិកម្ម និងសម្រុះសម្រួលវិវាទមូលដ្ឋានជាដើម ដោយសារនៅខ្វះបទដ្ឋានបច្ចេកទេស គោលការណ៍ណែនាំ ស្តង់ដាសេវាសម្រាប់ការប្រតិបត្តិ ហើយអង្គភាពទាំងនេះក៏ពុំដែលបានទទួលការបណ្តុះបណ្តាលអំពីបែបបទ និងនីតិវិធីសម្រាប់អនុវត្តមុខងាររបស់អង្គភាពខ្លួនឡើយ។ ទន្ទឹមគ្នានេះ ការិយាល័យមួយចំនួនផ្សេងទៀតដែលមានតួនាទីផ្តល់សេវាតាមវិស័យនានា ដូចជាការិយាល័យកសិកម្ម ធនធានធម្មជាតិ និងបរិស្ថាន ការិយាល័យសេដ្ឋកិច្ច និងអភិវឌ្ឍន៍សហគមន៍ ការិយាល័យសង្គមកិច្ច និងសុខមាលភាពសង្គម ការិយាល័យសាធារណការ ដឹកជញ្ជូន កសិកម្ម សណ្តាប់ធ្នាប់សាធារណៈជាដើម ក៏ខ្វះទាំងធនធានមនុស្ស និងធនធានហិរញ្ញវត្ថុសម្រាប់បំពេញការងារផងដែរ។ ប្រការនេះ ទាមទារឱ្យមានការបន្តជំរុញ និងបំពេញចំណុចខ្វះខាតទាំងនេះចៀសជាងការកែសម្រួល ឬកាត់បន្ថយរចនាសម្ព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌឡើងវិញ
- ចំពោះរចនាសម្ព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលរាជធានី ខេត្ត ត្រូវបានមើលឃើញថា នៅពុំទាន់មានភាពងាយស្រួលក្នុងការសម្របសម្រួល និងជំរុញការផ្តល់សេវាសាធារណៈតាមវិស័យនានា

ដើម្បីឆ្លើយតបទៅនឹងតម្រូវការជាអាទិភាពដែលបានកំណត់ក្នុងផែនការអភិវឌ្ឍន៍៥ឆ្នាំ និងកម្មវិធីវិនិយោគ៣ឆ្នាំរំកិលនៅឡើយ ដោយសារមុខងារ ការទទួលខុសត្រូវ និងធនធាននានាសម្រាប់ផ្តល់សេវាសាធារណៈតាមវិស័យនានាទាំងនោះ គឺស្ថិតនៅក្រោមការទទួលខុសត្រូវរបស់មន្ទីរជំនាញខ្សែបណ្តោយរបស់ក្រសួង ស្ថាប័ននៅថ្នាក់ជាតិ លើកលែងវិស័យសុខាភិបាលដែលបានផ្ទេរមកស្ថិតក្រោមការគ្រប់គ្រងផ្ទាល់របស់រដ្ឋបាលរាជធានី ខេត្ត

- ទោះបីមានការសាទរយ៉ាងខ្លាំងចំពោះការផ្ទេរមុខងារក្នុងវិស័យសុខាភិបាលទៅឱ្យរដ្ឋបាលរាជធានី ខេត្ត ដែលបានធ្វើឱ្យការគ្រប់គ្រងសេវាសុខាភិបាលកាន់តែមានប្រសិទ្ធភាពក៏ដោយ ក៏មានការលើកឡើងនូវបញ្ហាមួយចំនួនពាក់ព័ន្ធនឹងភាពមិនច្បាស់លាស់នៃការគ្រប់គ្រងការងាររដ្ឋបាល និងថវិកាប្រចាំឆ្នាំសម្រាប់មន្ទីរសុខាភិបាល។ មន្ត្រីមួយចំនួនបានយល់ឃើញថា ក្នុងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្តតែមួយ បែរជាមានប្រព័ន្ធគ្រប់គ្រងកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ ២ដាច់ដោយឡែកផ្សេងគ្នា គឺប្រព័ន្ធគ្រប់គ្រងកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុរបស់សាលារាជធានី ខេត្ត និងប្រព័ន្ធកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុសម្រាប់មន្ទីរសុខាភិបាល។ ប្រការនេះ ទាមទារឱ្យមានការបកស្រាយបំភ្លឺឱ្យបានច្បាស់លាស់ដល់អ្នកពាក់ព័ន្ធនានា

- ការយល់ដឹង និងការអនុវត្តខ្សែគណនេយ្យភាពអន្តររដ្ឋបាល និងគណនេយ្យភាពតាមបែបប្រជាធិបតេយ្យនៅមានកម្រិត។ ក្រុមប្រឹក្សារាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌមិនទាន់យល់ច្បាស់ និងមិនទាន់អនុវត្តបានល្អនូវខ្សែគណនេយ្យភាពចំពោះក្រុមប្រឹក្សាឃុំ សង្កាត់ដែលជាអ្នកបោះឆ្នោតឱ្យខ្លួន និងផ្ទុយមកវិញ ក្រុមប្រឹក្សាឃុំ សង្កាត់ក៏មិនសូវយល់ដឹងអំពីតម្រូវការដែលត្រូវធ្វើឱ្យក្រុមប្រឹក្សារាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌធ្វើគណនេយ្យភាពចំពោះខ្លួនឡើយ

- ទោះបី មន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិភាគច្រើនបានលើកឡើងថា បានប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាឌីជីថលក្នុងការផ្តល់សេវា និងការបំពេញការងារក៏ដោយ ក៏ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានវិទ្យា និងឌីជីថលដែលបានលើកឡើងទាំងនេះ គឺសំដៅលើការប្រើប្រាស់ទូរស័ព្ទវៃឆ្លាត (smart phone) ដោយប្រើប្រាស់កម្មវិធីទំនាក់ទំនងក្រៅផ្លូវការមួយចំនួន ដូចជា telegram, messenger និងបណ្តាញសង្គមផ្សេងទៀត ដែលមិនមែនជាប្រព័ន្ធឌីជីថលត្រូវបានរៀបចំ និងដាក់ឱ្យប្រើប្រាស់ជាផ្លូវការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិទាំងនោះឡើយ

- ការិយាល័យប្រជាពលរដ្ឋដែលជាយន្តការប្រមូល ទទួល និងសម្រុះសម្រួលបណ្តឹង ឬទំនាស់ផ្នែករដ្ឋបាលក្រៅប្រព័ន្ធតុលាការនៅតាមរដ្ឋបាលរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌពុំទាន់ត្រូវបានផ្សព្វផ្សាយឱ្យមានការយល់ដឹងទូលំទូលាយដល់ប្រជាពលរដ្ឋនៅឡើយ។

### ៤.២.៣. សមាសភាគទី៣ ៖ ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស

សមាសភាគទី៣ ផ្តោតលើការជំរុញ និងពង្រឹងការអនុវត្តសិទ្ធិអំណាច និងការទទួលខុសត្រូវរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រងបុគ្គលិករបស់ខ្លួន និងធានាឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិមាន

បុគ្គលិកប្រកបដោយឆន្ទៈម្ចាស់ការ ភក្តីភាព និងមនសិការជំនាញវិជ្ជាជីវៈស្របតាមតួនាទី ការទទួលខុសត្រូវរបស់ខ្លួន ព្រមទាំងទទួលបានការអភិវឌ្ឍសមត្ថភាព និងជំនាញវិជ្ជាជីវៈជាប្រចាំ។ សមាសភាគទី៣នេះ រួមមានលទ្ធផលរំពឹងទុកចំនួន១០ សកម្មភាពជាអាទិភាពចំនួន៣១ និងសូចនាករចំនួន៤៥។

### ក. វឌ្ឍនភាព

គិតត្រឹមឆមាសទី១ ឆ្នាំ២០២៥ សកម្មភាពចំនួន**២៣** ស្មើនឹង**៧៤%** ត្រូវបានអនុវត្ត ក្នុងនោះមានសកម្មភាពចំនួន **៣** ស្មើនឹង**១០%** ត្រូវបានអនុវត្តចប់ជាស្ថាពរតាមផែនការ។ សូចនាករចំនួន**៣១** ក្នុងចំណោមសូចនាករសរុបចំនួន**៤៥** ស្មើនឹង**៦៩%** ត្រូវបានអនុវត្ត ក្នុងនោះ សូចនាករចំនួន៤ ស្មើនឹង៩% ត្រូវបានអនុវត្តចប់ជាស្ថាពរតាមផែនការគ្រោងទុក។




ផ្អែកតាមការឆ្លើយតបទៅនឹងបញ្ជីសំណួរជាលក្ខណៈបុគ្គលរបស់អ្នកផ្ដល់ព័ត៌មាននានាដែលជាថ្នាក់ដឹកនាំក្រសួង ស្ថាប័នពាក់ព័ន្ធនៅថ្នាក់ជាតិ ក្រុមប្រឹក្សា មន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិ និងថ្នាក់ដឹកនាំមន្ទីរជំនាញនៅថ្នាក់រាជធានី ខេត្តចំនួន ២៤៨នាក់ បានវាយតម្លៃថា ការអនុវត្តសកម្មភាពនានានៃសមាសភាគទី៣ សម្រេចជាមធ្យមបាន ៨៧% នៅក្នុងចំណាត់ពីមធ្យមទៅល្អ។




សកម្មភាពជាអាទិភាពសំខាន់ៗដែលបានអនុវត្តរួមមានសង្ខេបដូចខាងក្រោម៖

– ក្នុងឆ្នាំ២០២២ ក្រសួងមុខងារសាធារណៈ បានសហការជាមួយក្រសួងមហាផ្ទៃ ក្រោមការសម្របសម្រួលរបស់ គ.ជ.អ.ប. បានរៀបចំ និងដាក់ចេញសេចក្តីណែនាំស្តីពីគោលការណ៍ និងនីតិវិធីសម្រាប់គ្រប់គ្រងបុគ្គលិករដ្ឋបាលរាជធានី និងរដ្ឋបាលខណ្ឌ សេចក្តីណែនាំស្តីពីគោលការណ៍ និងនីតិវិធីសម្រាប់គ្រប់គ្រងបុគ្គលិករដ្ឋបាលខេត្ត និងសេចក្តីណែនាំស្តីពីគោលការណ៍ និងនីតិវិធីសម្រាប់គ្រប់គ្រង

បុគ្គលិករដ្ឋបាលក្រុង ស្រុក។ សេចក្តីណែនាំទាំង៣នេះ ត្រូវបានផ្សព្វផ្សាយ និងបណ្តុះបណ្តាលជូនដល់រដ្ឋបាលថ្នាក់ក្រោមជាតិជាបន្តបន្ទាប់

- ក្នុងឆ្នាំ២០២៣ អនុក្រឹត្យស្តីពីការកំណត់មុខតំណែងវិជ្ជាជីវៈ និងការពិពណ៌នាមុខតំណែងនានាក្នុងរចនាសម្ព័ន្ធរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌត្រូវបានដាក់ចេញ និងសេចក្តីណែនាំស្តីពីការប្រើប្រាស់ការពិពណ៌នាមុខតំណែងនានានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌបានរៀបចំផងដែរ

- នៅចុងឆ្នាំ២០២៤ ផ្អែកតាមអនុសាសន៍របស់**សម្តេចនាយករដ្ឋមន្ត្រី** ក្រសួងមុខងារសាធារណៈបានសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា ក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័នពាក់ព័ន្ធនានាក្នុងការរៀបចំសេចក្តីព្រាងវិសោធនកម្មព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែក សម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីបើកផ្លូវឱ្យការតែងតាំងនាយកគ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ និងនាយកគ្រឹះស្ថានបឋមសិក្សាសាធារណៈត្រូវធ្វើឡើងដោយដីការបស់អភិបាលរាជធានី ខេត្ត។ សេចក្តីព្រាងវិសោធនកម្មព្រះរាជក្រឹត្យនេះត្រូវបានអនុម័ត និងដាក់ឱ្យប្រើនៅចុងឆ្នាំ២០២៤

- អនុក្រឹត្យស្តីពីគោលការណ៍ និងនីតិវិធីនៃការតែងតាំង ការផ្លាស់ប្តូរ និងការបញ្ចប់មុខតំណែងនាយកគ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ និងនាយកគ្រឹះស្ថានបឋមសិក្សាសាធារណៈ និងនិយាមនីតិវិធីប្រតិបត្តិសម្រាប់តែងតាំង ផ្លាស់ប្តូរ និងបញ្ចប់មុខតំណែងនាយកគ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ និងនាយកគ្រឹះស្ថានបឋមសិក្សាសាធារណៈក៏ត្រូវបានរៀបចំ អនុម័ត និងផ្សព្វផ្សាយដាក់ឱ្យអនុវត្តពីដើមឆ្នាំ២០២៥

- ផ្អែកតាមការផ្ទេរមុខងារ និងការផ្ទេរសិទ្ធិអំណាចទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ គិតមកដល់ឆ្នាំ២០២៥នេះ រាជរដ្ឋាភិបាល និងក្រសួង ស្ថាប័នថ្នាក់ជាតិបានផ្ទេរបុគ្គលិកឱ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិសរុបជាង **១០០.០០០នាក់** រួមមាន បុគ្គលិកក្រសួងមហាផ្ទៃចំនួន **៧.០០០នាក់** គ្រូបង្រៀនជាង **៧០.០០០នាក់** បុគ្គលិកជំនាញវិស័យនានាប្រមាណ **១០.០០០នាក់** និងគ្រូពេទ្យជាង **២០.០០០នាក់** ដែលក្នុងនោះ (១). បុគ្គលិករបស់រដ្ឋបាលរាជធានី ខេត្ត មានប្រមាណជាង **២៥.០០០នាក់** និង(២). បុគ្គលិករបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ មានប្រមាណជាង **៨០.០០០នាក់**។

- រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌមួយចំនួនបានរៀបចំលក្ខខណ្ឌការងារសម្រាប់បុគ្គលិកម្នាក់ៗ ផ្អែកតាមគោលការណ៍ណែនាំដែលបានកំណត់ក្នុងសៀវភៅណែនាំស្តីពីការគ្រប់គ្រងកិច្ចការរដ្ឋបាលរបស់រដ្ឋបាលរាធានី ខេត្ត និងសៀវភៅណែនាំស្តីពីគ្រប់គ្រងកិច្ចការរដ្ឋបាលរបស់រដ្ឋបាលក្រុង ស្រុក

- ថ្នាក់ដឹកនាំ និងមន្ត្រីនៃរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានវាយតម្លៃថា មានការយល់ដឹងយ៉ាងទូលំទូលាយអំពីសមភាពយេនឌ័រ បរិយាបន្ន និងសមធម៌សង្គម។ រាល់ការតែងតាំង ផ្លាស់ប្តូរមុខតំណែងនានា តែងតែមានការប្រឹក្សាយោបល់ និងការចូលរួមយ៉ាងជិតស្និទ្ធពីប្រធាន គ.ក.ស.ក./ គ.ក.ន.ក. និងអភិបាលរងជាស្ត្រីក្នុងការពិចារណា និងគិតគូរពីបេក្ខភាពជាស្ត្រី។ នៅថ្នាក់ក្រុង ស្រុក ខណ្ឌ ស្ត្រីដែល

កាន់មុខតំណែងគ្រប់គ្រង (អភិបាល អភិបាលរង នាយករដ្ឋបាល នាយករងរដ្ឋបាល និងប្រធាន/អនុប្រធានការិយាល័យ)៖ ឆ្នាំ២០២១ មានចំនួន១៨,៧២% ឆ្នាំ២០២២ មានចំនួន **៧៦៦នាក់ ១៩.៥២%** ឆ្នាំ២០២៣ មានចំនួន **១.៦៨៦នាក់ ២៣,៥៨** % និងឆ្នាំ២០២៤ មានចំនួន **២៣,០៧**% និងថ្នាក់រាជធានីខេត្តមានចំនួន**២៧**,៤៦%

– ជារៀងរាល់ឆ្នាំ រដ្ឋបាលរាជធានី ខេត្តបានរៀបចំ និងអនុវត្តផែនការអភិវឌ្ឍន៍សមត្ថភាពសម្រាប់បុគ្គលិករបស់ខ្លួន និងបុគ្គលិកនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ផ្អែកលើលទ្ធផលនៃការវាយតម្លៃអំពីតម្រូវការសមត្ថភាពដែលបានណែនាំ និងបណ្តុះបណ្តាលដោយសាលាជាតិរដ្ឋបាលមូលដ្ឋាន។ ជាមធ្យម រដ្ឋបាលរាធានី ខេត្តបានអនុវត្តសកម្មភាពអភិវឌ្ឍសមត្ថភាពចំនួនជាង **២០០វគ្គ** ក្នុងមួយឆ្នាំ ដែលមានសិក្ខាកាមចូលរួមចំនួនជាង **៦.៧០០នាក់**

– ក្នុងអំឡុងពេលនៃការអនុវត្ត កជទី១ នេះ សាលាជាតិរដ្ឋបាលមូលដ្ឋានបានដំណើរការយ៉ាងសកម្មក្នុងការអភិវឌ្ឍសមត្ថភាពដល់មន្ត្រីរាជការនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយសហការយ៉ាងជិតស្និទ្ធជាមួយក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍន៍ និងភាគីពាក់ព័ន្ធនានាលើប្រធានបទជាច្រើនដូចជា រចនាសម្ព័ន្ធ មុខងារ សិទ្ធិអំណាច និងតួនាទី ភារកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ភាពជាអ្នកដឹកនាំ សមភាពយេនឌ័រ បរិយាបន្ន និងសមធម៌សង្គម ការកសាងផែនការ គណនេយ្យភាពសង្គម ការប្រែប្រួលអាកាសធាតុ។ល។ ជាមធ្យម សាលាបានអនុវត្តសកម្មភាពអភិវឌ្ឍសមត្ថភាពដល់រដ្ឋបាលថ្នាក់ក្រោមជាតិចំនួន **៣៥វគ្គ**ក្នុងមួយឆ្នាំ ដែលមានសិក្ខាកាមចំនួនជាង **១.៥០០នាក់**។ ទន្ទឹមនេះ សាលាជាតិរដ្ឋបាលមូលដ្ឋានក៏បានរៀបចំ និងដាក់ចេញសៀវភៅណែនាំជាច្រើនអំពីការបណ្តុះបណ្តាល ការអនុវត្តមុខងារ និងប្រធានបទពាក់ព័ន្ធផ្សេងទៀត

– ក្រៅពីនេះ រដ្ឋបាលថ្នាក់ក្រោមជាតិក៏ទទួលបានវគ្គបណ្តុះបណ្តាលជាក់លាក់ដែលបានរៀបចំដោយក្រសួង ស្ថាប័ននានា។

លទ្ធផលលម្អិតដែលសម្រេចបានតាមសកម្មភាពនីមួយៗមានរៀបរាប់ក្នុងឧបសម្ព័ន្ធទី២ និងទី៣។

### ខ. សកម្មភាពជាអាទិភាពដែលមិនទាន់បានអនុវត្ត

ផ្អែកតាមរបាយការណ៍ប្រចាំឆ្នាំស្តីពីការអនុវត្ត ផ.ស.ថ. របស់ គ.ជ.អ.ប. ពីឆ្នាំ២០២១-២០២៥ សកម្មភាពជាអាទិភាពក្នុងសមាសភាគទី៣ ដែលមិនទាន់បានអនុវត្តមាន **៦**សកម្មភាព គឺ៖

– ការរៀបចំ និងដាក់ឱ្យអនុវត្តប្រព័ន្ធផ្តល់ការលើកទឹកចិត្តដល់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិផ្អែកតាមលទ្ធផលការងារ

– ការរៀបចំ និងដាក់ឱ្យអនុវត្តនូវសេចក្តីណែនាំស្តីពីការវាយតម្លៃអំពីតម្រូវការធនធានមនុស្សទាំងបរិមាណ និងវិជ្ជាជីវៈនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

– ការរៀបចំ និងអនុវត្តផែនការអភិវឌ្ឍន៍សមត្ថភាពប្រចាំឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិផ្អែកតាមតម្រូវការអភិវឌ្ឍន៍សមត្ថភាព

- ការបង្កើតស្ថាប័នបណ្តុះបណ្តាលថ្នាក់តំបន់ និងរៀបចំកម្មវិធីអភិវឌ្ឍន៍សមត្ថភាពនៅថ្នាក់តំបន់
- ការលើកទឹកចិត្តដល់ស្វ័យសិក្សា និងស្រាវជ្រាវ ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការសិក្សា
- ការរៀបចំ និងការអនុម័តក្របខណ្ឌអភិវឌ្ឍន៍ជំនាញវិជ្ជាជីវៈសម្រាប់បុគ្គលិកនៃរដ្ឋបាលថ្នាក់ក្រោមជាតិ។

## គ. បញ្ហាប្រឈម

ផ្អែកតាមរបាយការណ៍ប្រចាំឆ្នាំស្តីពីការអនុវត្ត ផ.ស.ថ. របស់ គ.ជ.អ.ប. ពីឆ្នាំ២០២១-២០២៥ និងការជួបប្រជុំពិភាក្សាជាមួយក្រុមប្រឹក្សា ថ្នាក់ដឹកនាំ មន្ត្រីនៃរដ្ឋបាលថ្នាក់ក្រោមជាតិបានបង្ហាញឱ្យឃើញថា ការអនុវត្តសមាសភាគទី៣ បានជួបបញ្ហាប្រឈមជាគន្លឹះមួយចំនួនដូចខាងក្រោម៖

- ការខ្វះទាំងចំនួនបុគ្គលិក និងការខ្វះបុគ្គលិកដែលមានជំនាញវិជ្ជាជីវៈសម្រាប់បំពេញការងារនៅតាមអង្គភាពនានានៃរដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសរដ្ឋបាលថ្នាក់ក្រុង ស្រុក គឺជាបញ្ហាប្រឈមខ្លាំងដែលបានលើកឡើងដោយគ្រប់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលក្រុមការងារវាយតម្លៃបានចុះជួប និងបានលើកឡើងក្នុងគ្រប់របាយការណ៍ប្រចាំឆមាស ប្រចាំឆ្នាំស្តីពីវឌ្ឍនភាពនៃការអនុវត្ត ផ.ស.ថ. របស់ គ.ជ.អ.ប. និងរបាយការណ៍ដែលបានរាយការណ៍ជូនអង្គវេទិការវាងរាជរដ្ឋាភិបាល និងរដ្ឋបាលថ្នាក់ក្រោមជាតិនាថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២៥
- ថ្នាក់ដឹកនាំរដ្ឋបាលខេត្ត និងក្រុង ស្រុកដែលក្រុមការងារបានជួបពិភាក្សា បានលើកឡើងថា ទោះបីរដ្ឋបាលខេត្ត ក្រុង ស្រុកនីមួយៗបានរៀបចំផែនការបុគ្គលិកផ្អែកតាមតម្រូវការ និងបន្ទុកការងារជាក់ស្តែងក៏ដោយ ក៏រដ្ឋបាលខេត្ត ក្រុង ស្រុកពុំទទួលបានការអនុញ្ញាតឱ្យជ្រើសរើសបុគ្គលិក ទាំងបុគ្គលិកក្របខណ្ឌរដ្ឋ និងបុគ្គលិកកិច្ចសន្យាតាមចំនួនដែលបានស្នើឡើងតាមរយៈផែនការបុគ្គលិកប្រចាំឆ្នាំនោះឡើយ។ បញ្ហាប្រឈមនេះ បានកើតឡើងជាច្រើនឆ្នាំមកហើយ ដោយសារបុគ្គលិកដែលមានស្រាប់បានចូលនិវត្តន៍ជាបន្តបន្ទាប់ ហើយរដ្ឋបាលថ្នាក់ក្រោមជាតិពុំត្រូវបានអនុញ្ញាតឱ្យជ្រើសរើសបុគ្គលិកថ្មីមកជំនួសតាមចំនួនមន្ត្រីដែលបានចូលនិវត្តន៍នោះឡើយ អាស្រ័យហេតុនេះបានធ្វើឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិកាន់តែមានបញ្ហាប្រឈមក្នុងការខ្វះបុគ្គលិកបំពេញការងារនៅតាមអង្គភាពនីមួយៗកាន់តែច្រើន
- ទាំងក្រុមប្រឹក្សា ថ្នាក់ដឹកនាំ និងមន្ត្រីនៃរដ្ឋបាលថ្នាក់ក្រោមជាតិដែលក្រុមការងារវាយតម្លៃបានជួបពិភាក្សា បានលើកឡើងថា បន្ទាប់ពីការធ្វើសមាហរណកម្មការិយាល័យជំនាញចូលទៅក្នុងថ្នាក់ក្រុង ស្រុក ខណ្ឌនាដើមឆ្នាំ២០២០ មន្ត្រីជំនាញដែលបានធ្វើសមាហរណកម្មភាគច្រើនពុំទាន់បានទទួលការបណ្តុះបណ្តាលអំពីបែបបទ និងនីតិវិធីអនុវត្តការងារនៅតាមអង្គភាពរបស់ខ្លួនឡើយ
- ទោះបីអនុក្រឹត្យស្តីពីការកំណត់មុខតំណែងវិជ្ជាជីវៈ និងការពិពណ៌នាមុខតំណែងក្នុងរចនាសម្ព័ន្ធរដ្ឋបាលក្រុង ស្រុក ខណ្ឌត្រូវបានដាក់ចេញនៅក្នុងឆ្នាំ២០២៣ក៏ដោយ ក៏អនុក្រឹត្យនេះពុំទាន់ត្រូវបានផ្សព្វផ្សាយដាក់ឱ្យអនុវត្តនៅឡើយ។ ដោយសារការខ្វះចំនួនបុគ្គលិក ដើម្បីដោះស្រាយបញ្ហាចំពោះមុខ រដ្ឋបាលក្រុង ស្រុកបានប្រមូលផ្តុំបុគ្គលិកដែលមានចំនួនតិចតួចនៅតាមអង្គភាពនីមួយៗឱ្យមក

រួមគ្នាអនុវត្តការងារដែលមានតម្រូវការបន្ទាន់ណាមួយ ឬច្រើន ដោយគ្មានផែនការច្បាស់លាស់ និងមិនគិតពីជំនាញវិជ្ជាជីវៈដែលបុគ្គលិកម្នាក់ៗមាន ដែលប្រការនេះបានធ្វើឱ្យមុខងារ និងភារកិច្ចស្នូលនៅតាមអង្គភាពមួយចំនួនពុំត្រូវបានយកចិត្តទុកដាក់អនុវត្តឡើយ

- ប្រធានការិយាល័យជំនាញនៃរដ្ឋបាលក្រុង ស្រុកភាគច្រើនបានលើកឡើងអំពីការលំបាកក្នុងការអនុវត្តមុខងារ ភារកិច្ចនៅតាមការិយាល័យជំនាញរបស់ខ្លួន ដោយសារតែខ្វះបុគ្គលិកជំនាញទទួលខុសត្រូវមុខងារវិស័យជំនាញនីមួយៗ បានធ្វើឱ្យប្រធានការិយាល័យជួបការលំបាកយ៉ាងខ្លាំង
- វគ្គបណ្តុះបណ្តាល ដែលបានអនុវត្តដោយសាលាជាតិរដ្ឋបាលមូលដ្ឋានដល់រដ្ឋបាលថ្នាក់ក្រោមជាតិនៅមានចំនួនតិច មិនទាន់ឆ្លើយតបទៅនឹងតម្រូវការ។

### ៤.២.៤. សមាសភាគទី៤ ៖ វិមជ្ឈការហិរញ្ញវត្ថុ និងប្រព័ន្ធផែនការនិងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

សមាសភាគទី៤នេះ ផ្តោតលើការរៀបចំឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិមានថវិកាក្នុងទំហំសមស្រប និងអាចវិភាជថវិកាទាំងនោះប្រកបដោយភាពបត់បែនសម្រាប់អនុវត្តមុខងារ និងកិច្ចការអាទិភាពនានា ដើម្បីឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងរបស់ប្រជាពលរដ្ឋ ដែលបានកំណត់ក្នុងផែនការអភិវឌ្ឍន៍៥ឆ្នាំ និងកម្មវិធីវិនិយោគ៣ឆ្នាំរំកិលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិបានទាន់ពេល និងប្រកបដោយប្រសិទ្ធភាពខ្ពស់។ សមាសភាគទី៤ បានកំណត់លទ្ធផលរំពឹងទុកចំនួន**១០** សកម្មភាពជាអាទិភាពចំនួន**២២** និងសូចនាករចំនួន**៣៦** ដែលត្រូវអនុវត្តក្នុងរយៈពេល៥ឆ្នាំ។

#### ក. វឌ្ឍនភាព

គិតត្រឹមឆមាសទី១ ឆ្នាំ២០២៥ សកម្មភាពចំនួន**១៥** ស្មើនឹង**៦៨**% បានអនុវត្ត ក្នុងនោះមានសកម្មភាពចំនួន៩ ស្មើនឹង៤១% បានអនុវត្តចប់ជាស្ថាពរតាមផែនការ។ សូចនាករចំនួន**២៤** ក្នុងចំណោមសូចនាករសរុបចំនួន**៣៦** ស្មើនឹង**៦៧**% ត្រូវបានអនុវត្ត ក្នុងនោះសូចនាករចំនួន**១៣** ស្មើនឹង**៣៦**% ត្រូវបានអនុវត្តចប់ជាស្ថាពរតាមផែនការ។



ផ្អែកតាមលទ្ធផលនៃការឆ្លើយទៅនឹងបញ្ជីសំណួរជាលក្ខណៈបុគ្គលរបស់អ្នកផ្តល់ព័ត៌មាននានាដែលជាថ្នាក់ដឹកនាំក្រសួង ស្ថាប័នពាក់ព័ន្ធថ្នាក់ជាតិ ក្រុមប្រឹក្សា មន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិ និងថ្នាក់ដឹកនាំមន្ទីរជំនាញនៅថ្នាក់រាជធានី ខេត្តចំនួន ១២២នាក់ បានវាយតម្លៃថា ការអនុវត្តសកម្មភាពនៃសមាសភាគទី៤ សម្រេចជាមធ្យមបាន**៦៥%** ក្នុងចំណាត់ថ្នាក់ពីមធ្យមទៅល្អ។




សកម្មភាពជាអាទិភាពសំខាន់ៗដែលបានអនុវត្តរួមមានសង្ខេបដូចខាងក្រោម៖

– ក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ មន្ត្រីទទួលបន្ទុកការងារហិរញ្ញវត្ថុ និងមន្ត្រីទទួលបន្ទុកការងារកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិបានកត់សម្គាល់ថា បន្ទាប់ពីមានការកែសម្រួលប្រតិទិននៃការកសាងផែនការអភិវឌ្ឍន៍៥ឆ្នាំ និងកម្មវិធីវិនិយោគ៣ឆ្នាំរំកិល បានធ្វើឱ្យដំណើរការរៀបចំគម្រោងថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិផ្អែកលើគម្រោង/សកម្មភាពអាទិភាពនានាដែលបានកំណត់ក្នុងកម្មវិធីវិនិយោគ៣ឆ្នាំរំកិល។ ប្រការនេះមានន័យថា ដំណើរការរៀបចំគម្រោងថវិកាប្រចាំឆ្នាំមានភាពស៊ីសង្វាក់គ្នាជាមួយដំណើរការកសាងផែនការ ដែលបានធ្វើឱ្យគម្រោងថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិឆ្លើយតបទៅនឹងតម្រូវការ/គម្រោង/សកម្មភាពជាអាទិភាពនានាដែលបានកំណត់នៅក្នុងកម្មវិធីវិនិយោគបានទាន់ពេលវេលា

– ការរៀបចំ និងអនុវត្តថវិកា និងមូលនិធិនៃរដ្ឋបាលថ្នាក់ក្រោមជាតិបានដំណើរការប្រកបដោយប្រសិទ្ធភាពតាមប្រព័ន្ធអនឡាញ FMIS

– រដ្ឋបាលរាជធានី ខេត្តទាំង២៥ បាននិងកំពុងប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ (SARMIS) ដែលបានដាក់ឱ្យអនុវត្តចាប់ពីឆ្នាំ២០២១

– ការវិភាជថវិកាជាតិសម្រាប់មូលនិធិក្រុង ស្រុក និងមូលនិធិឃុំ សង្កាត់មានការកើនឡើងគួរឱ្យកត់សម្គាល់

– ក្នុងអំឡុងពេលនៃការអនុវត្ត កជទី២ រយៈពេល៥ឆ្នាំនេះ ជារួម ថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិមានការកើនឡើងគួរឱ្យកត់សម្គាល់ ជាអាទិ៍

- ថវិកាសរុបរបស់រដ្ឋបាលថ្នាក់ក្រោមជាតិទាំង៣កម្រិតថ្នាក់ នៅឆ្នាំ២០២១ មានចំនួន **៨៥៨លានដុល្លារអាមេរិក** កើនដល់ចំនួន **១.៧៩០លានដុល្លារអាមេរិក** នៅឆ្នាំ២០២៥
- ថវិកាសរុបរបស់រដ្ឋបាលរាជធានី ខេត្តនៅឆ្នាំ២០២១ មានចំនួន **៥៤៤លានដុល្លារអាមេរិក** កើនដល់ចំនួន **៨៦៧លានដុល្លារអាមេរិក**

- ថវិកាសរុបរបស់រដ្ឋបាលក្រុង ស្រុកនៅឆ្នាំ២០២១ មានចំនួន **១២៩លានដុល្លារអាមេរិក** កើនដល់ចំនួន **៥៨០លានដុល្លារអាមេរិក**។ នៅក្នុងឆ្នាំ២០២៥នេះ រដ្ឋបាលក្រុង ស្រុក នីមួយៗមានថវិកាជាមធ្យមប្រមាណ **២៧ម៉ឺនដុល្លារអាមេរិក**សម្រាប់ការអភិវឌ្ឍមូលដ្ឋាន
- ថវិកាសរុបរបស់រដ្ឋបាលឃុំ សង្កាត់នៅឆ្នាំ២០២១ មានចំនួន **១៨៤លានដុល្លារអាមេរិក** កើនដល់ចំនួន **៣៤៣លានដុល្លារអាមេរិក**។ នៅក្នុងឆ្នាំ២០២៥នេះ រដ្ឋបាលឃុំ សង្កាត់ នីមួយៗមានថវិកាជាមធ្យមប្រមាណ **១១ម៉ឺនដុល្លារអាមេរិក**សម្រាប់ការអភិវឌ្ឍមូលដ្ឋាន។

– មូលនិធិមានភ្ជាប់លក្ខខណ្ឌសម្រាប់មុខងារវិស័យអប់រំ យុវជន និងកីឡាត្រូវបានលើកឡើងថា បានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុកនីមួយៗតាមពេលវេលាដែលបានកំណត់ និងបានអនុវត្តប្រកបដោយប្រសិទ្ធភាព

– មូលនិធិមានភ្ជាប់លក្ខខណ្ឌសម្រាប់មុខងារវិស័យសុខាភិបាល ក៏ត្រូវបានរាយការណ៍ថា បានផ្ទេរទៅឱ្យរដ្ឋបាលរាជធានី ខេត្តតាមពេលវេលា និងបានអនុវត្តប្រកបដោយប្រសិទ្ធភាព

– ក្នុងរយៈពេលនៃការអនុវត្ត កជទី២ រដ្ឋបាលថ្នាក់ក្រោមជាតិទាំង៣កម្រិតថ្នាក់ ក៏ត្រូវបានវិភាជថវិកាសម្រាប់អនុវត្តសកម្មភាពផ្តល់សេវាសង្គម និងអនាម័យបរិស្ថាន។ ប្រការនេះ ជាការវិវឌ្ឍប្រកបដោយវិជ្ជមានក្នុងការធានារដ្ឋបាលថ្នាក់ក្រោមជាតិបានប្រើប្រាស់ធនធានសាធារណៈប្រកបដោយបរិយាបន្ន និងសមធម៌សង្គម។

លទ្ធផលលម្អិតដែលសម្រេចបានតាមសកម្មភាពនីមួយៗមានរៀបរាប់ក្នុងឧបសម្ព័ន្ធទី២ និងទី៣។

### ខ. សកម្មភាពជាអាទិភាពដែលមិនទាន់បានអនុវត្ត

ផ្អែកតាមរបាយការណ៍ប្រចាំឆ្នាំស្តីពីការអនុវត្ត ផ.ស.ថ. របស់ គ.ជ.អ.ប. ពីឆ្នាំ២០២១-២០២៥ សកម្មភាពជាអាទិភាពក្នុងសមាសភាគទី៤ ដែលមិនទាន់បានអនុវត្តមានចំនួន៥ សកម្មភាព គឺ៖

– ការរៀបចំឯកសារជាយុទ្ធសាស្ត្រនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

– ការរៀបចំយុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ២០២៦-២០៣០

– ការពង្រឹងប្រព័ន្ធគ្រប់គ្រងមូលនិធិរដ្ឋបាលថ្នាក់ក្រោមជាតិ

– ការលើកកម្ពស់ក្របខណ្ឌសម្រាប់ការគ្រប់គ្រងធនធានរបស់ដៃគូអភិវឌ្ឍន៍ដែលផ្តល់ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ

– ការពង្រឹងក្របខណ្ឌគ្រប់គ្រងការវិនិយោគសាធារណៈ ដែលប្រើប្រាស់ថវិកាផ្ទាល់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

### គ. បញ្ហាប្រឈម

ផ្អែកតាមរបាយការណ៍ប្រចាំឆ្នាំស្តីពីការអនុវត្ត ផ.ស.ថ. របស់ គ.ជ.អ.ប. ពីឆ្នាំ២០២១-២០២៥ និងការជួបប្រជុំពិភាក្សាជាមួយក្រុមប្រឹក្សា មន្ត្រីថ្នាក់ដឹកនាំនៃរដ្ឋបាលថ្នាក់ក្រោមជាតិ បានបង្ហាញឱ្យ

ឃើញថា ការអនុវត្តសមាសភាគទី៤ បានជួបបញ្ហាប្រឈមជាគន្លឹះមួយចំនួនដូចខាងក្រោម៖

- បើទោះបី ថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិមានការកើនឡើងក៏ដោយ ក៏រដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសរដ្ឋបាលក្រុង ស្រុក បានលើកឡើងអំពីការខ្វះថវិកាសម្រាប់គាំទ្រការអនុវត្តមុខងារតាមវិស័យមួយចំនួនជាអាទិ៍ មុខងារក្នុងវិស័យអភិវឌ្ឍន៍ជនបទ សាធារណការ ធនធានទឹក កសិកម្ម ទេសចរណ៍ សង្គមកិច្ច ធនធានធម្មជាតិ និងបរិស្ថានជាដើម

- រដ្ឋបាលថ្នាក់ក្រោមជាតិនៅមិនទាន់យល់ដឹងច្បាស់អំពីគោលការណ៍ និងនីតិវិធីគ្រប់គ្រង និងការប្រើប្រាស់ថវិកាមានភ្ជាប់លក្ខខណ្ឌដូចជា ថវិកាមានភ្ជាប់លក្ខខណ្ឌសម្រាប់មុខងារសុខាភិបាលដែលបានផ្ទេរទៅឱ្យរដ្ឋបាលរាជធានី ខេត្ត និងថវិកាមានភ្ជាប់លក្ខខណ្ឌសម្រាប់មុខងារក្នុងវិស័យអប់រំ យុវជន និងកីឡាដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ។ ប្រការនេះ បានធ្វើឱ្យមន្ត្រីនៃរដ្ឋបាលរាជធានី ខេត្ត និងក្រុង ស្រុកមួយចំនួនយល់ឃើញថា នៅរដ្ឋបាលរាជធានី ខេត្ត និងក្រុង ស្រុកមានប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ២ផ្សេងគ្នា គឺប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសម្រាប់សាលារាជធានី ខេត្ត សាលាក្រុង ស្រុកដែលស្ថិតក្រោមការងារទទួលខុសត្រូវរបស់រដ្ឋបាលរាជធានី ខេត្ត និងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសម្រាប់មន្ទីរសុខាភិបាល និងការិយាល័យអប់រំ យុវជន និងកីឡាដែលមានស្ថិតក្រោមការទទួលខុសត្រូវរបស់រដ្ឋបាលរាជធានី ខេត្ត និងក្រុង ស្រុក។

- រដ្ឋបាលក្រុង ស្រុកដែលក្រុមការងារវាយតម្លៃបានជួបពិភាក្សាបានលើកឡើងថា ការិយាល័យត្រួតពិនិត្យផ្ទៃក្នុងមិនមានដំណើរការ ដោយសារកិច្ចការនេះគឺជាកិច្ចការថ្មីរបស់រដ្ឋបាលក្រុង ស្រុក ហើយមកដល់ពេលនេះពុំទាន់មានសេចក្តីណែនាំ និងការបណ្តុះបណ្តាលអំពីគោលការណ៍ និងនីតិវិធីសម្រាប់អនុវត្តកិច្ចការនេះឡើយ។

### ៤.២.៥. សមាសភាគទី៥ ៖ ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន

សមាសភាគទី៥ ផ្តោតលើការធ្វើទំនើបកម្មយន្តការ និងនីតិវិធីផ្តល់សេវា ការអភិវឌ្ឍមូលដ្ឋាន និងការប្រាស្រ័យទាក់ទងជាសាធារណៈរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីលើកកម្ពស់ការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋាន ឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗប្រកបដោយប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព បរិយាបន្ន និងសមធម៌សង្គម។

សមាសភាគទី៥នេះ មានលទ្ធផលរំពឹងទុក៤ សកម្មភាពអាទិភាព១០ និងសូចនាករ១៣។

#### ក. វឌ្ឍនភាព

គិតត្រឹមឆមាសទី១ ឆ្នាំ២០២៥ សកម្មភាពចំនួន១០ ស្មើនឹង១00% ត្រូវបានអនុវត្ត។ សូចនាករចំនួន១២ ក្នុងចំណោមសូចនាករសរុបចំនួន១៣ ស្មើនឹង៩២% ត្រូវបានអនុវត្ត។







ផ្អែកតាមការឆ្លើយតបទៅនឹងបញ្ជីសំណួរជាលក្ខណៈបុគ្គលរបស់អ្នកផ្តល់ព័ត៌មាននានា ដែលជាថ្នាក់ដឹកនាំក្រសួង ស្ថាប័នពាក់ព័ន្ធនៅថ្នាក់ជាតិ ក្រុមប្រឹក្សា មន្ត្រីនៃរដ្ឋបាលថ្នាក់ក្រោមជាតិ និងថ្នាក់ដឹកនាំមន្ទីរជំនាញនៅថ្នាក់រាជធានី ខេត្តចំនួន ៤០៨នាក់បានវាយតម្លៃថា ការអនុវត្តសកម្មភាពនានានៃសមាសភាគទី៥ សម្រេចជាមធ្យមបានសម្រេច**៨៧**% នៅក្នុងចំណាត់ថ្នាក់ពីមធ្យមទៅល្អ។

សកម្មភាពជាអាទិភាពសំខាន់ៗដែលបានអនុវត្តរួមមានសង្ខេបដូចខាងក្រោម៖

– សេចក្តីណែនាំបច្ចេកទេសសម្រាប់អនុវត្តមុខងារដែលបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្តដោយក្រសួង ស្ថាប័នចំនួន៨ រួមមាន ក្រសួងសាធារណការនិងដឹកជញ្ជូន ក្រសួងសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទា ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្រសួងរ៉ែនិងថាមពល ក្រសួងទេសចរណ៍ ក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងក្រសួងអប់រំ យុវជននិងកីឡា

– រដ្ឋបាលក្រុង ស្រុកកំពុងខិតខំប្រឹងប្រែងទទួលខុសត្រូវ និងអនុវត្តការងារវិស័យជំនាញ តាមសមត្ថភាព និងធនធានដែលមាន។ ទន្ទឹមនេះ មន្ទីរ អង្គភាពជំនាញពាក់ព័ន្ធ (មន្ទីរអប់រំ មន្ទីរកិច្ចការនារី មន្ទីរផែនការ មន្ទីរសាធារណការ មន្ទីរកសិកម្ម មន្ទីរបរិស្ថាន...) ក៏បានគាំទ្រដល់រដ្ឋបាលក្រុង ស្រុក ក្នុងការអនុវត្តមុខងារដែលបានផ្ទេរ តាមរយៈការបណ្តុះបណ្តាល និងចុះគាំទ្រផងដែរ

- ការផ្តល់សេវារដ្ឋបាលតាមយន្តការច្រកចេញចូលតែមួយនៅរដ្ឋបាលថ្នាក់ក្រោមជាតិ បាននិងកំពុងធ្វើទំនើបកម្មជាបណ្តើរៗ និងជាទូទៅបានដំណើរការប្រកបដោយប្រសិទ្ធភាព តម្លាភាព និងទទួលបានការពេញចិត្តពីប្រជាពលរដ្ឋ។ ផ្អែកតាមការអង្កេតអភិបាលកិច្ចនៃ កជទី២ ឆ្នាំ២០២៥ សន្ទស្សន៍នៃការផ្តល់សេវាទូទៅមាន**០,៦៩ពិន្ទុ** ដែលក្នុងនោះសន្ទស្សន៍ការបំពេញការងារទទួលបាន**០,៦៧ពិន្ទុ** (ចំណាត់ថ្នាក់បង្គួរ) និងសន្ទស្សន៍ការឆ្លើយតបទទួលបាន**០,៧៤ពិន្ទុ** (ចំណាត់ថ្នាក់ល្អ)។ សន្ទស្សន៍ភាពពេញចិត្តរបស់ប្រជាពលរដ្ឋចំពោះការផ្តល់សេវារដ្ឋបាលតាមច្រកចេញចូលតែមួយទទួលបាន**០,៦៩ពិន្ទុ** ស្ថិតក្នុងចំណាត់ថ្នាក់បង្គួរផងដែរ

- ក្នុងការលើកកម្ពស់ប្រសិទ្ធភាពការបំពេញការងារ និងគុណភាពសេវារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ គ.ជ.អ.ប. បានសហការជាមួយក្រសួង ដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលក្នុងការបន្តជំរុញ ពង្រឹង និងពង្រីកការអនុវត្តការងារគណនេយ្យភាពសង្គមកំពុងអនុវត្តយ៉ាងសកម្មនៅក្នុងឃុំ សង្កាត់ចំនួន**៩៣%**នៃឃុំ សង្កាត់សរុបទូទាំងប្រទេស និងក្នុងក្រុង ស្រុក ខណ្ឌចំនួន**១៨%** នៃក្រុង ស្រុក ខណ្ឌទូទាំងប្រទេស។ ផ្អែកតាមការវាយតម្លៃចុងបញ្ចប់គម្រោងគណនេយ្យភាពសង្គម ដំណាក់កាលទី២ កាលពីខែតុលា ឆ្នាំ២០២៤ បង្ហាញថា**៩២%** នៃប្រជាពលរដ្ឋពេញចិត្តនឹងការបំពេញការងាររបស់អង្គភាពផ្តល់សេវាទាំង៣ រួមមានសេវារដ្ឋបាលឃុំ សង្កាត់ សេវាមណ្ឌលសុខភាព និងសេវាសាលាបឋមសិក្សា

- រដ្ឋបាលថ្នាក់ក្រោមជាតិទាំង៣កម្រិតថ្នាក់បានបន្តរៀបចំការអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច គម្រោងសេវាកម្ម គម្រោងសេវាសង្គម និងអនាម័យបរិស្ថានដោយប្រើប្រាស់ថវិការបស់ខ្លួន និងថវិកាដែលគៀរគរបានពីប្រភពស្របច្បាប់ផ្សេងទៀត ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋមានការកើនឡើងជារៀងរាល់ឆ្នាំ។ ជាមធ្យម រដ្ឋបាលថ្នាក់ក្រោមជាតិអនុវត្តគម្រោងប្រមាណជាង **២.៦០០ គម្រោង**ក្នុងមួយឆ្នាំ

- ពាក់ព័ន្ធនឹងការរៀបចំ និងការអនុវត្តគម្រោងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនៅក្នុងអំឡុងពេលនៃការអនុវត្ត កជទី២ ក្រុមការងារវាយតម្លៃបានកត់សម្គាល់ឃើញថា មានការវិវឌ្ឍជាវិជ្ជមានយ៉ាងល្អពាក់ព័ន្ធនឹងនិន្នាការនៃការប្រើប្រាស់ថវិការដ្ឋបាលថ្នាក់ក្រោមជាតិកាន់តែច្រើនសម្រាប់អនុវត្តគម្រោង ឬសកម្មភាពផ្តល់សេវាសង្គម និងអនាម័យបរិស្ថាន។ ការងារនេះត្រូវបានមើលឃើញថាបាន និងកំពុងផ្តោតការយកចិត្តទុកដាក់យ៉ាងខ្លាំងទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិក្នុងការរៀបចំលិខិតបទដ្ឋានគតិយុត្ត សេចក្តីណែនាំ និងការអនុវត្តជាក់ស្តែងយ៉ាងសកម្មនៅតាមរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗប្រកបដោយប្រសិទ្ធភាពក្រោមការដឹកនាំ និងសម្របសម្រួលរបស់ គ.ក.ន.ក.។ រដ្ឋបាលឃុំ សង្កាត់មួយចំនួនបានប្រគល់មូលនិធិផ្នែកសេវាសង្គម និងអនាម័យបរិស្ថានឱ្យ គ.ក.ន.ក. ទទួលខុសត្រូវទាំងស្រុង

- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃបានដាក់ចេញនូវសារាចរអន្តរក្រសួងលេខ ០០៧ ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២៥ ស្តីពីការគ្រប់គ្រង ចាត់ចែង និងកំណត់មុខសញ្ញាចំណាយថវិកាសេវាសង្គម និងអនាម័យបរិស្ថានត្រូវបានដាក់ចេញសម្រាប់ការអនុវត្ត។ ទន្ទឹមនេះ ក្រសួងមហាផ្ទៃក៏កំពុងពិនិត្យ និងកែសម្រួលសេចក្តីណែនាំ និងសៀវភៅណែនាំនានាពាក់ព័ន្ធនឹងការរៀបចំ និងអនុវត្តគម្រោង

រដ្ឋបាលថ្នាក់ក្រោមជាតិឱ្យស្របតាមរចនាសម្ព័ន្ធ និងមុខងារថ្មីរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដោយគិតគូរដល់ការបញ្ជ្រាបការប្រែប្រួលអាកាសធាតុ ការគ្រប់គ្រងគ្រោះមហន្តរាយ និងជំងឺឆ្លងកាចសាហាវនានា

– ពាក់ព័ន្ធនឹងការវិវឌ្ឍនេះ គឺមូលនិធិក្រុង ស្រុក និងមូលនិធិឃុំ សង្កាត់ត្រូវបានកំណត់ជាក់លាក់នូវសមាសភាគសេវាសង្គម និងអនាម័យបរិស្ថានដែលអាចប្រើប្រាស់សម្រាប់គាំទ្រគម្រោង និងសកម្មភាពនានាពាក់ព័ន្ធនឹងការជួយក្រុមគ្រួសារងាយរងគ្រោះ គាំពារកុមារងាយគ្រោះ អាហារូបត្ថម្ភសម្រាប់កុមារ និងស្ត្រីមានផ្ទៃពោះ ការប្រែប្រួលអាកាសធាតុ គ្រោះមហន្តរាយ និងជំងឺឆ្លងកាចសាហាវនានាជាដើម។ ដូចគ្នានេះដែរ រដ្ឋបាលរាជធានី ខេត្តក៏មានថវិកាផ្នែកសេវាសង្គមយ៉ាងតិច១០% នៃថវិកាគុណប្រយោជន៍សម្រាប់គាំទ្រគម្រោង និងសកម្មភាពទាំងនេះ។ ប្រការនេះ ជាការលើកកម្ពស់ការប្រើប្រាស់ធនធានថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិប្រកបដោយបរិយាបន្ន និងសមធម៌សង្គម។

លទ្ធផលលម្អិតដែលសម្រេចបានតាមសកម្មភាពនីមួយៗមានរៀបរាប់ក្នុងឧបសម្ព័ន្ធទី២ និងទី៣។

### ខ. សកម្មភាពជាអាទិភាពដែលមិនទាន់បានអនុវត្ត

ផ្អែកតាមរបាយការណ៍ប្រចាំឆ្នាំស្តីពីការអនុវត្ត ផ.ស.ថ. របស់ គ.ជ.អ.ប. ពីឆ្នាំ២០២១-២០២៥ សកម្មភាពជាអាទិភាពទាំងអស់នៃសមាសភាគទី៥ បាននិងកំពុងដំណើរការអនុវត្ត។

### គ. បញ្ហាប្រឈម

ផ្អែកតាមរបាយការណ៍ប្រចាំឆ្នាំស្តីពីការអនុវត្ត ផ.ស.ថ. របស់ គ.ជ.អ.ប. ពីឆ្នាំ២០២១-២០២៥ និងការជួបប្រជុំពិភាក្សាជាមួយក្រុមប្រឹក្សា ថ្នាក់ដឹកនាំ និងមន្ត្រីនៃរដ្ឋបាលថ្នាក់ក្រោមជាតិ បានបង្ហាញឱ្យឃើញថា ការអនុវត្តសមាសភាគទី៥ បានជួបបញ្ហាប្រឈមជាគន្លឹះមួយចំនួនដូចខាងក្រោម៖

– សេវារដ្ឋបាលមួយចំនួនដែលបានផ្ទេរពីក្រសួង ស្ថាប័នមកឱ្យក្រុង ស្រុក ខណ្ឌនៅមិនទាន់មានសេចក្តីណែនាំ និងនីតិវិធីច្បាស់លាស់សម្រាប់ការអនុវត្ត

– សេចក្តីណែនាំ និងនីតិវិធីសម្រាប់ការអនុវត្តមុខងារវិស័យជាច្រើនដែលបានផ្ទេរឱ្យក្រុង ស្រុក ខណ្ឌពុំទាន់បានរៀបចំដាក់ឱ្យអនុវត្ត និងផ្តល់ការបណ្តុះបណ្តាល

– ពុំទាន់មានសេចក្តីណែនាំ និងនីតិវិធី (សៀវភៅណែនាំ) ច្បាស់លាស់អំពីការរៀបចំ និងការអនុវត្តគម្រោងសេវាកម្ម ជាពិសេសគម្រោងសកម្មភាពផ្នែកសេវាសង្គម និងអនាម័យបរិស្ថានដែលត្រូវប្រើប្រាស់ និងគាំទ្រដោយមូលនិធិក្រុង ស្រុក និងមូលនិធិឃុំ សង្កាត់

– សេចក្តីណែនាំ និងសៀវភៅណែនាំមួយចំនួនសម្រាប់រៀបចំ និងអនុវត្តគម្រោងរដ្ឋបាលថ្នាក់ក្រោមជាតិមិនទាន់បានធ្វើបច្ចុប្បន្នភាពឱ្យស្របជាមួយរចនាសម្ព័ន្ធ តួនាទី និងភារកិច្ចថ្មីរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងបញ្ជ្រាបការងារអន្តរវិស័យ

– រដ្ឋបាលខេត្តភាគច្រើនកំពុងជួបប្រទះបញ្ហាកង្វះមន្ត្រីបច្ចេកទេស (ទាំងចំនួន និងសមត្ថភាព) ដើម្បីគាំទ្រដល់រដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់ក្នុងការរៀបចំ និងអនុវត្តគម្រោង

- ក្នុងខេត្តមួយចំនួន ការសិក្សា និងការរៀបចំឯកសារគម្រោងឃុំ សង្កាត់ត្រូវចំណាយពេលយូររហូតដល់៤ ទៅ៥ខែ ទើបឃុំ សង្កាត់អាចប្រកាសដេញថ្លៃបាន
- ខ្វះការចុះត្រួតពិនិត្យតាមដាន និងគាំទ្រឃុំ សង្កាត់ក្នុងការរៀបចំ និងអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់។

### ៥.៣. របកគំហើញពាក់ព័ន្ធនឹងការគ្រប់គ្រង និងការកាត់បន្ថយហានិភ័យ

ហានិភ័យសំខាន់ៗដែលបានកំណត់ក្នុង ផអ៥ទី១ សរុបមានចំនួន**៣៦** ក្នុងនោះហានិភ័យចំនួន**៣៤** ស្មើនឹង**៩៤%** បានអនុវត្ត រួមបញ្ចូលហានិភ័យចំនួន**១៣** (**៣៦%**) ត្រូវបានចាត់វិធានការទប់ស្កាត់ និងកាត់បន្ថយដោយជោគជ័យ។ វឌ្ឍនភាពនៃការគ្រប់គ្រង និងការកាត់បន្ថយហានិភ័យ បានរៀបចំ និងបញ្ចូលក្នុងរបាយការណ៍ប្រចាំឆមាស និងប្រចាំឆ្នាំស្តីពីវឌ្ឍនភាពការអនុវត្ត ផ.ស.ថ. របស់ គ.ជ.អ.ប. និងរបាយការណ៍ប្រចាំឆ្នាំស្តីពីវឌ្ឍនភាពនៃការអនុវត្ត ផ.ថ.ថ. របស់ស្ថាប័នអនុវត្តនានា។

វឌ្ឍនភាពនៃការគ្រប់គ្រង និងការកាត់បន្ថយហានិភ័យមានសង្ខេបក្នុងតារាងខាងក្រោម៖

**វឌ្ឍនភាពនៃការគ្រប់គ្រង និងការកាត់បន្ថយហានិភ័យនៃ ផអ៥ទី១**

| **សមាសភាគ** | **ចំនួនហានិភ័យ** | **វឌ្ឍនភាពនៃការអនុវត្ត** | | |
|---|---|---|---|---|
| | | **បញ្ចប់** | **កំពុងដំណើរការ** | **មិនទាន់អនុវត្ត** |
| ១ | ៤ | ២ | ២ | |
| ២ | ៩ | ៣ | ៥ | ១ |
| ៣ | ៨ | ៤ | ៤ | |
| ៤ | ៧ | ២ | ៤ | ១ |
| ៥ | ៨ | ២ | ៦ | |
| **សរុប** | **៣៦** | **១៣** | **២១** | **២** |

វិធានការទប់ស្កាត់ និងកាត់បន្ថយហានិភ័យនីមួយៗមានបរិយាយក្នុងឧបសម្ព័ន្ធទី៤។

### ៥.៤. របកគំហើញពាក់ព័ន្ធនឹងការអនុវត្តថវិកានៃកម្មវិធី

#### ក. ផែនការថវិកា

ថវិកាសរុបសម្រាប់អនុវត្ត កជទី២ ពីឆ្នាំ២០២១-២០២៥ មានសង្ខេបក្នុងតារាងខាងក្រោម។ ក្នុងរយៈពេល៥ឆ្នាំនេះ ថវិកាប៉ាន់ស្មានសរុបនៃ កជទី២ មានចំនួន **២៨.០២៣.៦៧៦លានរៀល** ស្មើនឹង **៧.០០៦លានដុល្លារអាមេរិក** ក្នុងនោះថវិការបស់រាជរដ្ឋាភិបាលចំនួន **២៧.២២៦.៥៥៩លានរៀល** ស្មើនឹង **៦.៨០៧លានដុល្លារអាមេរិក** (ស្មើនឹង**៩៧,១៦%**) និងថវិកាកម្ចីនិងជំនួយឥតសំណងគាំទ្រដោយដៃគូអភិវឌ្ឍន៍នានាមានចំនួន **៧៩៧.១១៧លានរៀល** ស្មើនឹង **១៩៩លានដុល្លារអាមេរិក** (ស្មើនឹង **២,៨៤%**)

នៃថវិកាសរុប។ ថវិកាសរុបនេះ រួមបញ្ចូលទាំងថវិកាសម្រាប់គាំទ្រដល់ការវិនិយោគរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងថវិកាសម្រាប់គាំទ្រដល់សកម្មភាពស្នូលនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។

ផែនការថវិកាសម្រាប់ការអនុវត្ត កជទី២ ពីឆ្នាំ២០២១-២០២៥ (គិតជាលានរៀល)

| ល.រ. | សមាសភាគ | ថវិកា | | | |
|---|---|---|---|---|---|
| | | រដ្ឋាភិបាល | កម្ចី | ជំនួយ | សរុប |
| ១ | ការដឹកនាំ និងសម្របសម្រួលការងារកំណែទម្រង់ | 42,889 | 60,966 | 38,608 | 142,463 |
| ២ | រចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាល | 41,362 | 0 | 53,260 | 94,622 |
| ៣ | ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស | 19,336 | 30,708 | 0 | 50,044 |
| ៤ | វិមជ្ឈការហិរញ្ញវត្ថុ និងប្រព័ន្ធផែនការនិងថវិកា | 27,094,234 | 166,025 | 0 | 27,260,259 |
| ៥ | ការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋាន | 28,738 | 369,691 | 77,859 | 476,288 |
| សរុប | | 27,226,559 | 627,390 | 169,727 | 28,023,676 |
| ភាគរយ | | 97.16% | 2.24% | 0.61% | 100% |

### ខ. ការអនុវត្តថវិកាថ្នាក់ក្រោមជាតិ

រដ្ឋបាលថ្នាក់ក្រោមជាតិទាំងអស់បានចំណាយសរុបចំនួន **១៩.១២៤.៨៨០លានរៀល** សមមូល **៤.៧៨១លានដុល្លារអាមេរិក** ស្មើនឹង៦៥% នៃថវិកាសរុបដែលមានចំនួន **២៩.៤៣១.១៩១លានរៀល** សមមូល **៧.៣៥៨លានដុល្លារអាមេរិក**។ ថវិកាចំណាយនេះ មិនទាន់បានបញ្ចូលចំណាយឆ្នាំ២០២៥ ឡើយ។

វឌ្ឍនភាពនៃការអនុវត្តថវិការដ្ឋបាលថ្នាក់ក្រោមជាតិ បានរៀបចំ និងបញ្ចូលក្នុងរបាយការណ៍ប្រចាំឆមាស និងប្រចាំឆ្នាំស្តីពីវឌ្ឍនភាពនៃការអនុវត្ត ផ.ស.ថ. របស់ គ.ជ.អ.ប.។

តារាង៖ ការអនុវត្តថវិកាថ្នាក់ក្រោមជាតិពីឆ្នាំ២០២១-២០២៥ (គិតជាលានរៀល)

| ល.រ. | ថ្នាក់ក្រោមជាតិ | ថវិកា | ចំណាយ |
|---|---|---|---|
| ១ | រាជធានី ខេត្ត | 17,718,285 | 11,447,725 |
| ២ | ក្រុង ស្រុក | 6,373,032 | 3,896,825 |
| ៣ | ឃុំ សង្កាត់ | 5,339,874 | 3,780,330 |
| | សរុប | 29,431,191 | 19,124,880 |

**សម្គាល់** ៖ តួលេខចំណាយគិតត្រឹមឆ្នាំ២០២៤

### គ. ការអនុវត្តថវិកាកំណែទម្រង់ស្នូល

ថវិកាប៉ាន់ស្មានសរុបនៃ កជទី២ សម្រាប់សកម្មភាពស្នូលនៃការងារកំណែទម្រង់ពីឆ្នាំ២០២១-២០២៥ មានចំនួន **៧៤១.១២៥លានរៀល** សមមូលនឹង**១៨៥លានដុល្លារអាមេរិក** រួមមានសកម្មភាព

ស្នូលនៃកំណែទម្រង់របស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិមានចំនួន **១៣៦.៧៩៣លានរៀល** សមមូលនឹង **៣៤លានដុល្លារអាមេរិក** និងថវិកាសកម្មភាពជាក់លាក់របស់គម្រោង កម្មវិធីនានារបស់ដៃគូអភិវឌ្ឍន៍គាំទ្រទៅលើកំណែទម្រង់ស្នូលមានចំនួន **៦០៤.៣៣២លានរៀល** សមមូលនឹង **១៥១លានដុល្លារអាមេរិក**។ ថវិកាចំណាយនេះ មិនទាន់បានបញ្ចូលចំណាយឆ្នាំ២០២៥។

វឌ្ឍនភាពនៃការអនុវត្តថវិការបស់សកម្មភាពស្នូលនៃការងារកំណែទម្រង់ បានរៀបចំ និងបញ្ចូលក្នុងរបាយការណ៍ប្រចាំឆមាស និងប្រចាំឆ្នាំស្តីពីការអនុវត្ត ផ.ស.ថ. របស់ គ.ជ.អ.ប.។

គិតត្រឹមចុងឆ្នាំ២០២៤ ចំណាយថវិការបស់ស្ថាប័នរាជរដ្ឋាភិបាលមានចំនួន **៧៩.៣៨៥លានរៀល** សមមូលនឹង **២០លានដុល្លារអាមេរិក** ស្មើនឹង៥៨% និងចំណាយថវិការបស់ដៃគូអភិវឌ្ឍន៍មានចំនួន **៣២៧.៩៤៨លានរៀល** សមមូលនឹង **៨២លានដុល្លារអាមេរិក** ស្មើនឹង៥៤%។

ការអនុវត្តថវិកានៃកំណែទម្រង់ស្នូល កជទី២ ពីឆ្នាំ២០២១-២០២៥ (គិតជាលានរៀល)

| ល.រ. | ស្ថាប័ន | ថវិកា | ចំណាយ |
|---|---|---|---|
| ១ | ស្ថាប័នរាជរដ្ឋាភិបាល | 136,793 | 79,385 |
| | ក្រសួង ស្ថាប័ន | 68,210 | 47,386 |
| | រាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ | 68,583 | 31,999 |
| ២ | គម្រោង កម្មវិធីនានារបស់ដៃគូអភិវឌ្ឍន៍ | 604,332 | 327,948 |
| **សរុបរួម** | | 741,125 | 407,333 |

**សម្គាល់** ៖ តួលេខចំណាយគិតត្រឹមឆ្នាំ២០២៤។

# ៦. ការវិភាគ

## ៦.១. ក្របខណ្ឌលទ្ធផល

### ក. ចក្ខុវិស័យ

ចក្ខុវិស័យមានខ្លឹមសារច្បាស់លាស់ផ្តោតលើ ៣ចំណុច គឺ (១). ប្រជាពលរដ្ឋទទួលបានសេវាសាធារណៈ និងផលប្រយោជន៍ពីការអភិវឌ្ឍមូលដ្ឋានដែលផ្តល់ដោយរដ្ឋបាលថ្នាក់ក្រោមជាតិ (២). ការរួមចំណែកសម្រេចគោលបំណងនៃការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមជាតិ និង (៣). ប្រែក្លាយប្រទេសកម្ពុជាឱ្យទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០។

ទោះជាយ៉ាងនេះក៏ដោយ កជទី២ ពុំបានកំណត់សូចនាករ និងចំណុចដៅ ដើម្បីវាស់វែង និងត្រួតពិនិត្យការសម្រេចបានចក្ខុវិស័យនេះឡើយ។

### ខ. គោលបំណង

គោលបំណងផ្តោតជាសំខាន់លើ **ការលើកកម្ពស់ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ**។ គោលបំណងនៃ កជទី២ ពុំបានរំលេចពាក្យ "**ការអភិវឌ្ឍមូលដ្ឋាន**" តែបានរំលេច

នូវពាក្យ "**ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ**" ដែលផ្អែកតាមច្បាប់រៀបចំអង្គការឆ្នាំ២០០៨ គោលការណ៍នៃការអភិវឌ្ឍតាមប្រជាធិបតេយ្យ រួមមាន (**១**). ភាពជាតំណាងសាធារណៈ (**២**). ស្វ័យភាពមូលដ្ឋាន (**៣**). ការពិគ្រោះយោបល់ និងការចូលរួម (**៤**). ការឆ្លើយតប និងគណនេយ្យភាព (**៥**). ការលើកកម្ពស់គុណភាពជីវិតរបស់ប្រជាជននៅមូលដ្ឋាន (**៦**). ការលើកស្ទួយសមធម៌ (**៧**). តម្លាភាព និងសុចរិតភាព និង (**៨**). វិធានការប្រឆាំងអំពើពុករលួយ និងការរំលោភអំណាច។

ខ្លឹមសារខាងលើបង្ហាញថា គោលបំណងនេះមានលក្ខណៈធំទូលាយជាងខ្លឹមសារនៃចក្ខុវិស័យ និងគោលដៅដែលផ្ដោតលើ **ការលើកកម្ពស់ការផ្ដល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន**។

ហេតុនេះ គួរកែសម្រួលគោលបំណងឱ្យបានច្បាស់លាស់ និងឆ្លើយតបទៅនឹងចក្ខុវិស័យ និងចាំបាច់ត្រូវកំណត់សូចនាករជាក់លាក់សម្រាប់ការវាស់វែង វាយតម្លៃគោលបំណងផងដែរ។

### គ. គោលដៅ

គោលដៅផ្ដោតលើ **ការរៀបចំរចនាសម្ព័ន្ធ និងប្រព័ន្ធអភិបាលកិច្ច** របស់រដ្ឋបាលថ្នាក់ក្រោមជាតិឱ្យមានលក្ខណៈទំនើប មានស្វ័យភាព ប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាពក្នុងការផ្ដល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន។

គោលដៅនេះ មានលក្ខណៈសមស្រប និងជាមូលដ្ឋានក្នុងការសម្រេចបានគោលបំណង ដើម្បីលើកកម្ពស់ការផ្ដល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន មានន័យថា រចនាសម្ព័ន្ធ និងប្រព័ន្ធអភិបាលកិច្ចដែលមានលក្ខណៈទំនើប មានស្វ័យភាព ប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាពនឹងនាំឱ្យការផ្ដល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានមានភាពល្អប្រសើរ។ ប៉ុន្តែ គោលដៅពុំមានការកំណត់សូចនាករ និងចំណុចដៅឱ្យបានច្បាស់លាស់ដែលនាំឱ្យមានការលំបាកក្នុងការវាស់វែង ការត្រួតពិនិត្យ និងការរៀបចំរបាយការណ៍។

### ឃ. សមិទ្ធផល ឬសមាសភាគ

សមិទ្ធផល ឬសមាសភាគទាំង៥ មានទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធ។ ការសម្រេចបានសមាសភាគទាំង៥នេះ នឹងឈានទៅការសម្រេចបានគោលដៅ គឺរចនាសម្ព័ន្ធ និងប្រព័ន្ធអភិបាលកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិមានលក្ខណៈទំនើប មានស្វ័យភាព ប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព។

ទោះជាយ៉ាងណាក៏ដោយ សមិទ្ធផលមួយចំនួនមានខ្លឹមសារស្រដៀងគ្នា និងឃ្លាលទ្ធផលរំពឹងទុក។ ទន្ទឹមនេះ ឃ្លាសមិទ្ធផលវែង និងពិបាកចងចាំ ព្រមទាំងពុំមានការកំណត់សូចនាករ និងចំណុចដៅឱ្យបានច្បាស់លាស់ដែលនាំឱ្យមានការលំបាកក្នុងការវាស់វែង ការត្រួតពិនិត្យ និងការរៀបចំរបាយការណ៍។

### ង. លទ្ធផលរំពឹងទុក

លទ្ធផលរំពឹងទុកតាមសមាសភាគនីមួយៗមានសារៈសំខាន់ ដើម្បីសម្រេចបានសមិទ្ធផលដែលបានកំណត់។ ទោះជាយ៉ាងណាក៏ដោយ លទ្ធផលរំពឹងទុកមួយចំនួនមានខ្លឹមសារស្រដៀងគ្នាជាមួយខ្លឹមសារនៃសមិទ្ធផល។ ជាងនេះទៀត លទ្ធផលរំពឹងទុកមួយចំនួនមានលក្ខណៈលម្អិតពេក និងស្រដៀង

គ្នាដែលអាចបូកបញ្ចូលគ្នាជាលទ្ធផលរំពឹងទុកតែមួយ ដូចជាលទ្ធផលរំពឹងទុកក្នុងសមាសភាគទី៣ សមាសភាគទី៤ និងសមាសភាគទី៥ ជាដើម។

### ច. សកម្មភាពជាអាទិភាព

សកម្មភាពអាទិភាពដែលបានកំណត់មានសារៈសំខាន់ ដើម្បីសម្រេចបានលទ្ធផលរំពឹងទុកនីមួយៗ។ ទោះជាយ៉ាងណាក៏ដោយ សកម្មភាពជាអាទិភាពមានចំនួនច្រើន និងមួយចំនួនមានលក្ខណៈលម្អិតពេក ដែលអាចដាក់បញ្ចូលគ្នាជាសកម្មភាពតែមួយ។ ជាមួយគ្នានេះដែរ ពុំមានសូចនាករ និងចំណុចដៅសម្រាប់សកម្មភាពជាអាទិភាពនីមួយៗដែលនាំឱ្យមានការលំបាកក្នុងការកំណត់សូចនាករប្រចាំឆ្នាំនៃ ផ.ស.ថ. ក៏ដូចជាការវាស់វែង ការត្រួតពិនិត្យ និងការរៀបចំរបាយការណ៍។

### ឆ. ផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ (ផ.ស.ថ.)

ជាទូទៅ ផ.ស.ថ. រួមទាំងសេចក្តីសម្រេចរួមមានលក្ខណៈសាមញ្ញ ងាយយល់ និងត្រូវបានរៀបចំដោយផ្អែកលើសកម្មភាពជាអាទិភាពនៃ កជទី២។ ជាគោលការណ៍ ផ.ស.ថ. រួមបញ្ចូលសកម្មភាពស្នូលនៃការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដែលត្រូវអនុវត្តដោយប្រតិបត្តិករនៃ កជទី២ រួមមានក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ប៉ុន្តែនិយមន័យអំពីសកម្មភាពស្នូលនៃការងារកំណែទម្រង់ហាក់បីដូចពុំទាន់មានការកំណត់ឱ្យបានច្បាស់លាស់។

រដ្ឋបាលថ្នាក់ក្រោមជាតិមួយចំនួននៅតែយល់ថា សកម្មភាពនានានៃ ផ.ស.ថ. ជាសកម្មភាពរបស់ថ្នាក់ជាតិដែលតម្រូវឱ្យថ្នាក់ក្រោមជាតិអនុវត្ត។ លើសពីនេះ ក្នុង ផ.ស.ថ. ពុំបានកំណត់លទ្ធផលរំពឹងទុកដែលត្រូវសម្រេចក្នុងឆ្នាំនីមួយៗ ពោលគឺយកសកម្មភាពជាអាទិភាពនៃ កជទី២ មកប្រើប្រាស់នៅកម្រិតលទ្ធផលរំពឹងទុក។ ចំណុចនេះ នាំឱ្យមានការលំបាកក្នុងការកំណត់សូចនាករដែលត្រូវសម្រេចក្នុងឆ្នាំនីមួយៗ ក៏ដូចជាការត្រួតពិនិត្យ និងការរៀបចំរបាយការណ៍។ ជាងនេះទៀត ផ.ស.ថ. មិនបានបញ្ចូលសកម្មភាពរបស់មន្ទីរ អង្គភាពជំនាញ និងភាគីពាក់ព័ន្ធផ្សេងទៀតដែលអនុវត្តសកម្មភាពស្នូលនៃកំណែទម្រង់ផងដែរ។ ក្រៅពីនេះ យន្តការ និងប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃ ផ.ស.ថ. មិនបានធ្វើបច្ចុប្បន្នភាព និងអនុវត្តជាប្រចាំ ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រង ការរៀបចំ និងការអនុវត្ត ផ.ស.ថ.។

### ៦.២. ការអនុវត្តកម្មវិធី

ឯកសារ កជទី២ បានរៀបចំក្នុងអំឡុងឆ្នាំ២០២០-២០២១ និងបានអនុម័តនៅខែធ្នូ ឆ្នាំ២០២១។ ផ្អែកលើ កជទី២ ផអ៥ទី១ បានរៀបចំក្នុងអំឡុងឆ្នាំ២០២១-២០២២ និងបានអនុម័តខែធ្នូ ឆ្នាំ២០២២។

ក្នុងអំឡុងពេលនេះ ប្រទេសកម្ពុជាក៏ដូចជាបណ្តាប្រទេសនានានៅលើសកលលោកបានជួបវិបត្តិនៃការរីករាលដាលដ៏ធ្ងន់ធ្ងរនៃជំងឺកូវីដ-១៩ ដែលបានជះឥទ្ធិពលជាអវិជ្ជមានដល់ការអនុវត្ត កជទី២ រហូតដល់ដើមឆ្នាំ២០២២។ ដូច្នេះ រយៈពេលពិតប្រាកដនៃការវាយតម្លៃអំពីវឌ្ឍនភាពនៃការអនុវត្ត កជទី២ គឺមានរយៈពេលប្រមាណជា៣ឆ្នាំប៉ុណ្ណោះ គិតចាប់ពីពាក់កណ្តាលឆ្នាំ២០២២ ដល់ពាក់កណ្តាលឆ្នាំ២០២៥។

អាស្រ័យហេតុនេះ បើគិតត្រឹមឆមាសទី១ ឆ្នាំ២០២៥ មានតែសកម្មភាពជាអាទិភាពចំនួន**២៧** ស្មើនឹង**២៤%** នៃសកម្មភាពសរុបចំនួន**១១២** ដែលបានអនុវត្តចប់តាមផែនការ។ សកម្មភាពចំនួន**៦៣** ស្មើនឹង**៥៦%** កំពុងដំណើរការ និងសកម្មភាពចំនួន**២២** ស្មើនឹង**២០%** មិនទាន់បានអនុវត្ត។




ចំពោះសូចនាករ គិតត្រឹមឆមាសទី១ ឆ្នាំ២០២៥ មានតែសូចនាករចំនួន**៣៨** ស្មើនឹង**២៣%** នៃសូចនាករសរុបចំនួន**១៦៥** ដែលបានសម្រេចតាមផែនការ។ សូចនាករចំនួន**៨៩** ស្មើនឹង**៥៦%** កំពុងដំណើរការ និងសូចនាករចំនួន**៣៨** ស្មើនឹង**២៣%** មិនទាន់បានចាប់ផ្តើមអនុវត្ត។




ជារួម គិតត្រឹមឆមាសទី១ ឆ្នាំ២០២៥ ក្នុងចំណោមសកម្មភាពជាអាទិភាព និងសូចនាករទាំងអស់ មានសកម្មភាពជាអាទិភាព និងសូចនាករចំនួន៨៤% បានអនុវត្ត ក្នុងនោះសកម្មភាពជាអាទិភាព និងសូចនាករចំនួន **២៣%**បានអនុវត្តចប់តាមផែនការ **៥៥%**កំពុងដំណើរការ និង **២២%**មិនទាន់បានចាប់ផ្តើមអនុវត្តនៅឡើយ។

### ៦.៣. ការគ្រប់គ្រង និងការកាត់បន្ថយហានិភ័យ

ជារួម ការគ្រប់គ្រង និងការកាត់បន្ថយហានិភ័យនៃ កជទី២ ផអ៥ទី១ ត្រូវបានត្រួតពិនិត្យតាមដាន និងធ្វើបច្ចុប្បន្នភាពប្រចាំឆមាស តាមរយៈរបាយការណ៍ប្រចាំឆមាសស្តីពីការអនុវត្ត ផ.ស.ថ. របស់ គ.ជ.អ.ប.។ សកម្មភាពនៃការគ្រប់គ្រង និងការកាត់បន្ថយហានិភ័យ ក៏ត្រូវបានបញ្ចូលក្នុង ផ.ស.ថ. របស់ គ.ជ.អ.ប. និងក្នុងសេចក្តីសម្រេចរួមរបស់ស្ថាប័នអនុវត្តនានា។ ចំណុចនេះ បង្ហាញថា ការគ្រប់គ្រង និងការកាត់បន្ថយហានិភ័យនៃ កជទី២ ត្រូវបានយកចិត្តទុកដាក់ និងអនុវត្តជាប្រចាំ។

ដូចបានរៀបរាប់ក្នុងផ្នែក ៤.៣. ខាងលើ គិតត្រឹមឆមាសទី១ ឆ្នាំ២០២៥ ហានិភ័យចំនួន**៣៤** ស្មើនឹង**៩៤%** ក្នុងចំណោមហានិភ័យសរុបចំនួន**៣៦** បានអនុវត្ត ក្នុងនោះ ហានិភ័យចំនួន**១៣** (**៣៦%**) ត្រូវបានចាត់វិធានការទប់ស្កាត់ និងកាត់បន្ថយដោយជោគជ័យ។




## ៦.៤. ការអនុវត្តថវិកា

ជាមធ្យម ថវិកាសម្រាប់ការអនុវត្ត កជទី២ មានចំនួនប្រមាណ **១.៤៧២លានដុល្លារអាមេរិក** ក្នុងមួយឆ្នាំដែលក្នុងនោះថវិការបស់រាជរដ្ឋាភិបាលមានចំនួន**៩៧%** និងដៃគូអភិវឌ្ឍន៍ចូលរួមបដិភាគចំនួន**៣%**។

ការវាយតម្លៃ កជទី២ ផ្តោតលើការអនុវត្តថវិការជួរបស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិដែលបានគាំទ្រសកម្មភាពស្នូលនៃការងារកំណែទម្រង់។ ជាទូទៅ ថវិកាសម្រាប់អនុវត្តសកម្មភាពស្នូលនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ត្រូវបានគាំទ្រស្ទើរតែទាំងស្រុងដោយថវិការជួរបស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈការអនុវត្តសេចក្តីសម្រេចរួមរវាង គ.ជ.អ.ប. ជាមួយក្រសួង ស្ថាប័នចំនួន២២ និងរាជធានី ខេត្តចំនួន២៥។ ជាមធ្យម ថវិកាសម្រាប់អនុវត្ត ផ.ស.ថ. មានចំនួនពី **៥-៦លានដុល្លារអាមេរិក**ក្នុងមួយឆ្នាំ ក្នុងនោះថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិរួមចំណែកប្រហាក់ប្រហែលគ្នាចំនួន**៥០%**។ ថវិកាសរុបនេះ មានចំនួនប្រហាក់ប្រហែលគ្នាជាមួយនឹងថវិការជួដែលគាំទ្រ ផ.ស.ថ. សម្រាប់ការអនុវត្ត កជទី១ ពីឆ្នាំ២០១៨-២០២០ និងថវិកាដែលគាំទ្រដោយដៃគូអភិវឌ្ឍន៍ពីឆ្នាំ២០១១-២០១៧ (មិនគិតចំណាយសម្រាប់ទីប្រឹក្សាបច្ចេកទេស)។

ជារៀងរាល់ឆ្នាំ ចំណាយថវិកានៃការអនុវត្តសេចក្តីសម្រេចរួម ជាមធ្យមមានចំនួនពី ៧០-៨០%។ ចំណុចនេះ បង្ហាញថា ថវិកានៃសេចក្តីសម្រេចរួមត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាព។



# ៧. អនុសាសន៍

## ៧.១. ឯកសារ កជទី២

| ក្របខណ្ឌលទ្ធផល | អនុសាសន៍ |
|---|---|
| **ចក្ខុវិស័យ** | គួររក្សាខ្លឹមសារដដែល ប៉ុន្តែត្រូវកំណត់សូចនាករ និងចំណុចដៅសម្រាប់៖<br>– ប្រជាពលរដ្ឋទទួលបានសេវា និងផលប្រយោជន៍ពីការអភិវឌ្ឍមូលដ្ឋាន និង<br>– រួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមជាតិ។ |
| **គោលបំណង** | – បន្ថែមពាក្យ **ការអភិវឌ្ឍមូលដ្ឋាន** ដើម្បីឱ្យស្របគ្នាជាមួយវិសាលភាពនៃចក្ខុវិស័យ និងគោលដៅ<br>– កែសម្រួលឱ្យខ្លី ងាយស្រួលយល់ និងចងចាំ **លើកកម្ពស់ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន ស្របតាមគោលការណ៍នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ធានាលើកកម្ពស់បរិយាបន្ន សមធម៌សង្គម និងយុត្តិធម៌។**<br>– កំណត់សូចនាករ និងចំណុចដៅសម្រាប់គោលបំណងឱ្យបានច្បាស់លាស់។ |
| **គោលដៅ** | កែសម្រួលឱ្យខ្លី ងាយស្រួលយល់ និងចងចាំ **រចនាសម្ព័ន្ធ និងប្រព័ន្ធអភិបាលកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិមានលក្ខណៈទំនើប មានស្វ័យភាព ប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព**។ |
| **សមិទ្ធផល** | – ខ្លឹមសារសំខាន់នៃសមិទ្ធផលគួររក្សាដដែល ប៉ុន្តែគួរកែសម្រួលឱ្យខ្លី ងាយចងចាំ និងងាយយល់<br>– កំណត់សូចនាករ និងចំណុចដៅសម្រាប់សមិទ្ធផលនីមួយៗ។ |
| **លទ្ធផលរំពឹងទុក** | – ច្របាច់បញ្ចូលគ្នា និងកាត់បន្ថយចំនួនលទ្ធផលរំពឹងទុកនៃ កជទី២ ក្នុងសមាសភាគមួយចំនួន៖<br>• **សមាសភាគទី១** ៖ រក្សាដដែល<br>• **សមាសភាគទី២** ៖ រក្សាដដែល<br>• **សមាសភាគទី៣** ៖<br>  ▪ លទ្ធផលរំពឹងទុកទី១ លទ្ធផលរំពឹងទុកទី២ និងលទ្ធផលរំពឹងទុកទី៣ គួរបញ្ចូលគ្នាជាលទ្ធផលរំពឹងទុកតែមួយ<br>  ▪ លទ្ធផលរំពឹងទុកទី៨ លទ្ធផលរំពឹងទុកទី៩ និងលទ្ធផលរំពឹងទុកទី១០ គួរបញ្ចូលគ្នាជាលទ្ធផលរំពឹងទុកតែមួយ។<br>• **សមាសភាគទី៤** ៖<br>  ▪ លទ្ធផលរំពឹងទុកទី១ និងលទ្ធផលរំពឹងទុកទី២ គួរបញ្ចូលគ្នាជាលទ្ធផលរំពឹងទុកតែមួយ |

| ក្របខណ្ឌលទ្ធផល | អនុសាសន៍ |
|---|---|
| | ▪ លទ្ធផលរំពឹងទុកទី៣ និងលទ្ធផលរំពឹងទុកទី៤ គួរបញ្ចូលគ្នាជាលទ្ធផលរំពឹងទុកតែមួយ<br>▪ លទ្ធផលរំពឹងទុកទី៧ និងលទ្ធផលរំពឹងទុកទី៨ គួរបញ្ចូលគ្នាជាលទ្ធផលរំពឹងទុកតែមួយ។<br>• **សមាសភាគទី៥** ៖ លទ្ធផលរំពឹងទុកទី១ និងលទ្ធផលរំពឹងទុកទី២ គួរបញ្ចូលគ្នាជាលទ្ធផលរំពឹងទុកតែមួយ។ |
| **សកម្មភាពជាអាទិភាព** | – ពិនិត្យ និងកាត់បន្ថយចំនួនលទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាព តាមរយៈការដាក់បញ្ចូលគ្នានៃលទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាពដែលមានលក្ខណៈស្រដៀងគ្នា និងពាក់ព័ន្ធគ្នា<br>– ពិនិត្យ និងកាត់បន្ថយសកម្មភាពជាអាទិភាពមួយចំនួនដែលមិនអាចអនុវត្តបានក្នុងអំឡុង កជទី២<br>– ពិនិត្យ និងកែសម្រួលលទ្ធផលរំពឹងទុក និងសកម្មភាពជាអាទិភាពនៃ កជទី២ ពីឆ្នាំ ២០២៦-២០៣០ ដោយផ្តោតលើអាទិភាពដែលអាចគាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិ និងប្រជាពលរដ្ឋដែលរងគ្រោះដោយសារសង្គ្រាមរវាងថៃ និងកម្ពុជា<br>– គួររៀបចំសូចនាករ និងចំណុចដៅតាមសកម្មភាពជាអាទិភាពនីមួយៗ ដើម្បីឱ្យមានភាពងាយស្រួលក្នុងការរៀបចំសូចនាករនៃ ផ.ស.ថ. ការត្រួតពិនិត្យ ការវាយតម្លៃ និងការរៀបចំរបាយការណ៍។ |

### ៧.២. ការអនុវត្ត កជទី២

#### ៧.២.១. ការអនុវត្តកម្មវិធី

សមាសភាគទី១ ៖ ការដឹកនាំ និងសម្របសម្រួលកំណែទម្រង់

– ពិនិត្យ និងកែសម្រួលរចនាសម្ព័ន្ធ និងតួនាទីភារកិច្ចរបស់ គ.ជ.វ.វ. នៅតាមក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយពង្រីកការទទួលខុសត្រូវលើការងារកំណែទម្រង់គន្លឹះនានារបស់រាជរដ្ឋាភិបាល និងពង្រឹងការអនុវត្តយន្តការនេះប្រកបដោយប្រសិទ្ធភាព

– លើកកម្ពស់ការផ្សព្វផ្សាយអំពី កជទី២ ផអ៥ទី១ ដល់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈសិក្ខាសាលា និងកិច្ចប្រជុំនានាដោយមានបទបង្ហាញ និងសេចក្តីពន្យល់ឱ្យបានច្បាស់លាស់ ដើម្បីឱ្យស្ថាប័នទាំងនោះផ្សព្វផ្សាយបន្តដល់អង្គភាពក្នុងស្ថាប័នរបស់ខ្លួន និងអ្នកពាក់ព័ន្ធ

– ពិនិត្យ និងកែសម្រួលសេចក្តីណែនាំស្តីពីការរៀបចំ និងអនុវត្ត ផ.ស.ថ. រួមបញ្ចូលការកែសម្រួលទម្រង់ និងខ្លឹមសារនៃ ផ.ស.ថ. របស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិដោយកំណត់ឱ្យបានច្បាស់នូវលទ្ធផល និងសកម្មភាពនានាដែលត្រូវបញ្ចូលក្នុង ផ.ស.ថ.។ ទន្ទឹមនេះ គួរកំណត់លទ្ធផលរំពឹងទុកប្រចាំឆ្នាំនីមួយៗសម្រាប់ ផ.ស.ថ. ផ្អែកលើសកម្មភាពជាអាទិភាពនៃ កជទី២

– ពង្រឹងការត្រួតពិនិត្យវឌ្ឍនភាពនៃការអនុវត្ត ផ.ស.ថ.៖

- ការរៀបចំកិច្ចប្រជុំត្រួតពិនិត្យប្រចាំត្រីមាសឱ្យបានទៀងទាត់ជាមួយក្រសួង ស្ថាប័ន និងរដ្ឋបាលរាជធានី ខេត្ត
- ទន្ទឹមនេះ ក្រសួង ស្ថាប័ន និងរដ្ឋបាលរាជធានី ខេត្ត ក៏ត្រូវពង្រឹងការតាមដាន ត្រួតពិនិត្យការអនុវត្ត ផ.ស.ថ. របស់ខ្លួនជាប្រចាំ

– ពង្រឹងការត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការយុទ្ធសាស្ត្រស្តីពីការបង្កើនចំនួនស្ត្រីក្នុងមុខតំណែងគ្រប់គ្រងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

– លើកកម្ពស់ការផ្សព្វផ្សាយអំពីតួនាទី និងភារកិច្ចរបស់សមាគមក្រុមប្រឹក្សាក្រុង ស្រុក ឃុំ សង្កាត់ និងសមាគមក្រុមប្រឹក្សាខណ្ឌ សង្កាត់នៅថ្នាក់រាជធានី ខេត្ត

– ពង្រឹងការអនុវត្តតួនាទី និងភារកិច្ចរបស់សមាគមក្រុមប្រឹក្សាមូលដ្ឋាននៅរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការអភិវឌ្ឍសមត្ថភាព និងគាំទ្រសមាជិករបស់ខ្លួន

– ពិនិត្យកែសម្រួល និងរៀបចំបញ្ចប់សេចក្តីព្រាងយុទ្ធសាស្ត្រស្តីពីការងារអន្តរវិស័យនៃ កជទី២ ដើម្បីជាមូលដ្ឋានក្នុងការបញ្ជ្រាបក្នុង ផអ៥ទី២ រួមមាន៖

- យុទ្ធសាស្ត្រស្តីពីការកាត់បន្ថយភាពងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុ
- យុទ្ធសាស្ត្រស្តីពីការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ និងជំងឺឆ្លងកាចសាហាវ
- យុទ្ធសាស្ត្រស្តីពីអភិបាលកិច្ចឌីជីថល។

សមាសភាគទី២ ៖ រចនាសម្ព័ន្ធ និងប្រព័ន្ធរដ្ឋបាលថ្នាក់ក្រោមជាតិ

– បន្តពង្រឹង និងគាំទ្ររដ្ឋបាលក្រុង ស្រុក ដើម្បីពង្រឹងការអនុវត្តតួនាទី និងភារកិច្ចរបស់ខ្លួនស្របតាមរចនាសម្ព័ន្ធ និងមុខងារដែលបានកែសម្រួល ដោយផ្តោតលើការពិនិត្យ និងដោះស្រាយបញ្ហាធនធានមនុស្ស

– ផ្តល់អាទិភាព និងពន្លឿនការរៀបចំ និងដាក់ចេញនូវសេចក្តីណែនាំ និងលិខិតបទដ្ឋានស្តីពីការកំណត់កញ្ចប់ថវិកាដោយឡែកសម្រាប់ក្រុមប្រឹក្សា និងគណៈកម្មាធិការនានាចំណុះក្រុមប្រឹក្សារាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ ដើម្បីលើកកម្ពស់ការបំពេញតួនាទី និងភារកិច្ចរបស់យន្តការនេះ

– ពង្រឹង និងគាំទ្រការអនុវត្តតួនាទី ភារកិច្ច សមត្ថភាព និងធនធានមនុស្សរបស់ការិយាល័យប្រជាពលរដ្ឋនៅថ្នាក់រាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌក្នុងការទទួល និងសម្រុះសម្រួលដោះស្រាយបណ្តឹងនានារបស់ប្រជាពលរដ្ឋ ទាំងផ្នែកសេវារដ្ឋបាល គម្រោង និងសកម្មភាពនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

សមាសភាគទី៣ ៖ ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស

– ផ្តល់អាទិភាព និងយកចិត្តទុកដាក់ក្នុងការដោះស្រាយបញ្ហាប្រឈមរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ពាក់ព័ន្ធនឹងកង្វះបុគ្គលិក កង្វះសមត្ថភាពជំនាញរបស់បុគ្គលិកនៅតាមការិយាល័យជំនាញ ស្របតាមតួនាទី និងភារកិច្ចដែលបានកំណត់ និងកង្វះសេចក្តីណែនាំបច្ចេកទេស និងនីតិវិធីស្តីពីការអនុវត្តមុខងារ

របស់ការិយាល័យជំនាញនីមួយៗ ពិសេសការិយាល័យត្រួតពិនិត្យផ្ទៃក្នុង ការិយាល័យនីតិកម្ម និងសម្រុះសម្រួលវិវាទមូលដ្ឋានជាដើម

– សិក្សាអំពីជម្រើសក្នុងការកំណត់ និងតែងតាំងមុខតំណែងមន្ត្រីបច្ចេកទេសនៅថ្នាក់ក្រុង ស្រុក ដើម្បីគាំទ្រឃុំ សង្កាត់ក្នុងការសិក្សា និងរៀបចំគម្រោងមូលនិធិឃុំ សង្កាត់

– ពង្រឹងការផ្សព្វផ្សាយអំពីឯកសារ កជទី២ និងផអ៥ទី១ ដល់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការចូលរួម ការគាំទ្រ និងការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

– រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវយកចិត្តទុកដាក់ក្នុងការរៀបចំ និងអនុវត្តផែនការ ឬសកម្មភាពអភិវឌ្ឍសមត្ថភាពប្រចាំឆ្នាំដល់បុគ្គលិករបស់ខ្លួន និងអ្នកពាក់ព័ន្ធនានា ព្រមទាំងវិភាជថវិកាឱ្យបានសមស្រប ដើម្បីអនុវត្តផែនការនេះ

– សាលាជាតិរដ្ឋបាលមូលដ្ឋាន និងក្រសួង ស្ថាប័នពាក់ព័ន្ធនានា ត្រូវពង្រឹងការរៀបចំ និងអនុវត្តវគ្គបណ្តុះបណ្តាល និងវគ្គរម្លឹកឡើងវិញជាប្រចាំដល់រដ្ឋបាលថ្នាក់ក្រោមជាតិអំពីការអនុវត្តតួនាទី ភារកិច្ចរបស់ខ្លួន និងជំនាញនានាសម្រាប់ការដឹកនាំ និងការអនុវត្តជាក់ស្តែង

– ពង្រឹងការរៀបចំ និងអនុវត្តវគ្គបណ្តុះបណ្តាលដល់មន្ត្រីគាំទ្របច្ចេកទេសរាជធានី ខេត្តអំពីបទដ្ឋានបច្ចេកទេសសម្រាប់សិក្សា និងរៀបចំគម្រោងមូលនិធិឃុំ សង្កាត់

– សិក្សាអំពីជម្រើសក្នុងការប្រើប្រាស់វិស័យឯកជនក្នុងការរៀបចំ និងអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់។

សមាសធាតុទី៤ ៖ វិមជ្ឈការហិរញ្ញវត្ថុ

– ពង្រឹងការអនុវត្តប្រកាសអន្តរក្រសួងរវាងក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងផែនការ លេខ០១៤៩ ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០២០ ស្តីពីការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់

– យកចិត្តទុកដាក់ និងផ្តល់អាទិភាពក្នុងការរៀបចំ និងវិភាជថវិកាសម្រាប់អនុវត្តមុខងារតាមវិស័យនានាដែលបានផ្ទេរឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌឱ្យបានសមស្រប

– ពន្លឿនការរៀបចំ និងដាក់ចេញនូវសេចក្តីណែនាំ និងនីតិវិធីសម្រាប់ការងារត្រួតពិនិត្យផ្ទៃក្នុងនៅថ្នាក់ក្រុង ស្រុក។

សមាសធាតុទី៥ ៖ ការផ្តល់សេវា និងការអនុវត្តមូលដ្ឋាន

– ពន្លឿនការរៀបចំ និងបណ្តុះបណ្តាលអំពីសេចក្តីណែនាំ និងនីតិវិធីនានាសម្រាប់អនុវត្តមុខងារវិស័យដែលផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ

– ពិនិត្យ និងកែសម្រួលសេចក្ដីណែនាំ និងនីតិវិធីនានាសម្រាប់អនុវត្តគម្រោង និងសកម្មភាពរដ្ឋបាលថ្នាក់ក្រោមជាតិ ស្របតាមរចនាសម្ព័ន្ធ និងមុខងារថ្មីដែលបានកែសម្រួល ព្រមទាំងបញ្ជ្រាបការងារអន្តរវិស័យនានាក្នុងនីតិវិធីទាំងនោះ

– ពិនិត្យ និងកែសម្រួលសៀវភៅណែនាំបច្ចេកទេសគម្រោងមូលនិធិឃុំ សង្កាត់ឱ្យស្របតាមរចនាសម្ព័ន្ធ និងមុខងាររបស់ថ្នាក់ក្រោមជាតិដែលបានកែសម្រួល និងការបញ្ជ្រាបការប្រែប្រួលអាកាសធាតុ គ្រោះមហន្តរាយ និងការងារពាក់ព័ន្ធផ្សេងទៀត

– រៀបចំ និងដាក់ចេញសេចក្ដីណែនាំ និងនីតិវិធីនានាសម្រាប់អនុវត្តគម្រោង សកម្មភាពនានាពាក់ព័ន្ធនឹងសេវាសង្គម និងអនាម័យបរិស្ថាននៃរដ្ឋបាលថ្នាក់ក្រោមជាតិ

– យកចិត្តទុកដាក់ និងពង្រឹងការត្រួតពិនិត្យ តាមដាន និងគាំទ្រការរៀបចំ និងអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់

– ពិនិត្យ និងកែសម្រួលសមាជិកភាព តួនាទី និងភារកិច្ចរបស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់ក្រោមជាតិ ដោយបញ្ចូលការទទួលខុសត្រូវលើការប្រែប្រួលអាកាសធាតុ ជំងឺឆ្លងកាចសាហាវនានា និងការងារពាក់ព័ន្ធផ្សេងទៀត។

### ៧.២.២. ការគ្រប់គ្រង និងការកាត់បន្ថយហានិភ័យ

អនុសាសន៍សម្រាប់ការពង្រឹងការគ្រប់គ្រង និងការកាត់បន្ថយហានិភ័យ រួមមាន៖

– ពិនិត្យ និងធ្វើបច្ចុប្បន្នភាពបញ្ជីហានិភ័យរៀងរាល់ ៦ខែម្ដង

– ជារៀងរាល់ឆ្នាំ លេខាធិការដ្ឋាន គ.ជ.អ.ប. ត្រូវរៀបចំផែនការការងារស្ដីពីការគ្រប់គ្រង និងការកាត់បន្ថយហានិភ័យប្រចាំឆ្នាំដោយមានការបែងចែកអ្នកទទួលខុសត្រូវ និងវិភាជថវិកាគាំទ្រឱ្យបានសមស្រប ដើម្បីធានាប្រសិទ្ធភាពក្នុងការអនុវត្តផែនការនេះ

– ពង្រឹងការតាមដាន ត្រួតពិនិត្យការអនុវត្តផែនការគ្រប់គ្រង និងការកាត់បន្ថយហានិភ័យ តាមរយៈការរៀបចំកិច្ចប្រជុំយ៉ាងតិចក្នុងរយៈពេល៦ខែម្ដង ជាមួយភាគីពាក់ព័ន្ធនានា

– បញ្ចូល និងរាយការណ៍អំពីវឌ្ឍនភាពនៃផែនការគ្រប់គ្រង និងការកាត់បន្ថយហានិភ័យក្នុងកិច្ចប្រជុំនានានៃយន្តការដឹកនាំ និងសម្របសម្រួលការងារកំណែទម្រង់ និងយន្តការពាក់ព័ន្ធផ្សេងទៀត ដើម្បីពិនិត្យ និងចាត់វិធានការដោះស្រាយ។

### ៧.២.៣. ការអនុវត្តថវិកានៃកម្មវិធី

– ពង្រឹងការយកចិត្តទុកដាក់ និងផ្ដល់អាទិភាពរបស់ថ្នាក់ដឹកនាំក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការវិភាជថវិកាគាំទ្រសកម្មភាពស្នូលនៃការងារកំណែទម្រង់

– ពង្រឹងតួនាទីរបស់លេខាធិការដ្ឋាន គ.ជ.អ.ប. ក្នុងការពិនិត្យ និងផ្ដល់ការឯកភាពលើគម្រោង

ថវិកាប្រចាំឆ្នាំរបស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់សកម្មភាពស្នូលនៃការងារកំណែទម្រង់ មុននឹងដាក់ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុពិនិត្យ និងអនុម័ត

– ពង្រឹងការត្រួតពិនិត្យជាប្រចាំលើការអនុវត្តថវិការបស់ ជ.ស.ថ.។

## ៧.៣. កិច្ចការជាអាទិភាពសម្រាប់ ផអ៥ទី២

កិច្ចការជាអាទិភាពសំខាន់ៗដែលគួរយកចិត្តទុកដាក់ក្នុង ផអ៥ទី២ ត្រូវបានបញ្ចូលជាអនុសាសន៍ក្នុងផ្នែកខាងលើ។ ក្រៅពីនេះ កិច្ចការជាអាទិភាពផ្សេងទៀតដែលត្រូវយកចិត្តទុកដាក់បន្ថែមក្នុង ផអ៥ទី២ រួមមាន៖

– ការវាយតម្លៃអំពីប្រសិទ្ធភាពនៃការអនុវត្តលិខិតបទដ្ឋាននានា ដែលបានដាក់ចេញដោយលេខាធិការដ្ឋាន គ.ជ.អ.ប. និងក្រសួង ស្ថាប័នពាក់ព័ន្ធ

– ការសិក្សា និងការរៀបចំយុទ្ធសាស្ត្រស្ដីពីសុខដុមនីយកម្មនៃកំណែទម្រង់គន្លឹះទាំង៥ ជាមួយគោលនយោបាយភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាពរបស់រាជរដ្ឋាភិបាល

– ការរៀបចំ និងការដាក់ឱ្យអនុវត្តនូវយុទ្ធសាស្ត្រស្ដីពីភាពជាដៃគូរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលក្នុងការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

– សិក្សាអំពីជម្រើសក្នុងការរៀបចំរចនាសម្ព័ន្ធ មុខងារ សិទ្ធិអំណាច និងធនធានរបស់រដ្ឋបាលខេត្ត ក្រុង ស្រុក និងឃុំ សង្កាត់នៅតាមតំបន់ព្រំដែនក្នុងគោលបំណងលើកកម្ពស់ការអភិវឌ្ឍ និងការរក្សាសន្តិសុខនៅក្នុងតំបន់ទាំងនោះ

– ការជំរុញលើកទឹកចិត្តឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិប្រើប្រាស់ធនធានរបស់ខ្លួនក្នុងការលើកកម្ពស់សកម្មភាពអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន

– ការពិនិត្យ កែសម្រួល និងធ្វើបច្ចុប្បន្នភាពតួនាទី ភារកិច្ចរបស់មន្ត្រីភូមិ

– ការរៀបចំសេចក្ដីណែនាំ និងអភិវឌ្ឍន៍សមត្ថភាពស្ដីពីជំនាញក្នុងការសម្រុះសម្រួល និងដោះស្រាយបណ្ដឹងក្រៅប្រព័ន្ធតុលាការដោយរដ្ឋបាលថ្នាក់ក្រោមជាតិ

– ការសិក្សា និងរៀបចំសេចក្ដីណែនាំ ដើម្បីបញ្ចូលការងារគណនេយ្យភាពសង្គមទៅក្នុងភារកិច្ចរបស់អង្គភាពនៃរដ្ឋបាលរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ

– បញ្ចូលសកម្មភាពជាអាទិភាពស្ដីពីការលើកកម្ពស់ការអភិវឌ្ឍមូលដ្ឋានក្នុងសមាសភាគទី៥

– ការរៀបចំ និងការដាក់ចេញនូវយុទ្ធសាស្ត្រស្ដីពីចលនាប្រលងប្រណាំងក្នុងការបំពេញការងារការផ្ដល់សេវា ការអភិវឌ្ឍមូលដ្ឋាន និងការអនុវត្តគោលនយោបាយភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាពដោយរដ្ឋបាលថ្នាក់ក្រោមជាតិ។

## ៨. សេចក្ដីសន្និដ្ឋាន

ជារួម ក្នុងរយៈពេល៥ឆ្នាំកន្លងមកនេះ ពោលគឺពីឆ្នាំ២០២១-២០២៥ ទោះបីការអនុវត្ត កជទី២ បានជួបប្រទះនូវវិបត្តិដ៏ធ្ងន់ធ្ងរបណ្ដាលមកពីការរីករាលដាលនៃជំងឺកូវីដ-១៩ វិបត្តិសេដ្ឋកិច្ចសកល និង វិបត្តិជម្លោះព្រំដែនរវាងថៃ-កម្ពុជាក៏ដោយ ក៏ការអនុវត្ត កជទី២ ត្រូវបានដំណើរការយ៉ាងសកម្មក្រោម ការដឹកនាំ និងសម្របសម្រួលរបស់ គ.ជ.អ.ប. និងដោយមានកិច្ចសហការ និងការចូលរួមពីក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល វិស័យឯកជន និងភាគីពាក់ព័ន្ធនានា និង សម្រេចលទ្ធផលជាច្រើនប្រៀបធៀបទៅនឹងផែនការគ្រោងទុក។

ជាក់ស្ដែងសកម្មភាពជាអាទិភាពចំនួន**៩០** ស្មើនឹង**៨០%** នៃសកម្មភាពជាអាទិភាពសរុបចំនួន**១១២** នៃ កជទី២ ត្រូវបានអនុវត្ត ក្នុងនោះសកម្មភាពជាអាទិភាពចំនួន**២៧** ស្មើនឹង**២៤%** សម្រេចបាន**១០០%** តាមផែនការ។ សូចនាករចំនួន**១២៧** ស្មើនឹង**៧៧%** នៃសូចនាករសរុបចំនួន**១៦៥** ត្រូវបានអនុវត្ត ក្នុងនោះ សូចនាករចំនួន**៣៨** ស្មើនឹង**២៣%** សម្រេចបាន**១០០%** តាមផែនការគ្រោងទុក។ លទ្ធផលនេះ ស្របគ្នាជាមួយលទ្ធផលនៃការវាយតម្លៃជាបុគ្គលដោយអ្នកផ្ដល់ព័ត៌មានអំពីការអនុវត្ត កជទី២ តាម សមាសភាគនីមួយៗ ដែលជាមធ្យមសម្រេចបាន**៨០%**។

ក្នុងរយៈពេល៥ឆ្នាំនេះ លទ្ធផលសំខាន់ៗនៃ កជទី២ ដែលសម្រេចបានរួមមាន រចនាសម្ព័ន្ធ និង សមាសភាព គ.ជ.អ.ប. ត្រូវបានពិនិត្យ និងកែសម្រួល រួមបញ្ចូលអនុគណៈកម្មាធិការនានានៃ គ.ជ.អ.ប. និង គ.ដ.វ.វ. នៅតាមក្រសួង ស្ថាប័ន និងរដ្ឋបាលរាជធានី ខេត្ត និងក្រុង ស្រុក ដើម្បីពង្រឹងការដឹកនាំ និងសម្របសម្រួលការអនុវត្ត កជទី២។ គ.ជ.អ.ប. ក៏បានសម្របសម្រួល និងរៀបចំវេទិការវាង រាជរដ្ឋាភិបាល និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃកំណែទម្រង់វិមជ្ឈការ និង វិសហមជ្ឈការ។ ព័ត៌មានស្ដីពីការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការដែលពាក់ព័ន្ធនឹងការផ្ទេរ មុខងារ សិទ្ធិអំណាច ធនធាន ការផ្ដល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានត្រូវបានផ្សព្វផ្សាយ តាមរយៈមធ្យោបាយផ្សេងៗ និងបានយល់ដឹងកាន់តែប្រសើរឡើងដោយរដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូ អភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធនានា។

រដ្ឋបាលក្រុង ស្រុកក្នុងតួនាទីជារដ្ឋបាលមូលដ្ឋាន បានខិតខំប្រឹងប្រែងបំពេញតួនាទី និងភារកិច្ច របស់ខ្លួនយ៉ាងសកម្ម ស្របតាមរចនាសម្ព័ន្ធ និងមុខងារដែលបានកែសម្រួល។ ដូចគ្នានេះដែរ រដ្ឋបាល រាជធានី ខេត្តបានគ្រប់គ្រង និងផ្ដល់សេវាសុខាភិបាលដែលបានប្រគល់ពីក្រសួងសុខាភិបាលប្រកបដោយ ប្រសិទ្ធភាព។ ទន្ទឹមនេះ លេខាធិការដ្ឋាន គ.ជ.អ.ប. ក៏កំពុងសិក្សា ប្រមូលចងក្រងមេរៀន បទពិសោធន៍ នៃបណ្ដាប្រទេសទាំងក្នុង និងក្រៅតំបន់ ព្រមទាំងស្ថានភាពជាក់ស្ដែងនៅកម្ពុជាសម្រាប់ជាមូលដ្ឋានក្នុង ការរៀបចំរដ្ឋបាលខេត្តឱ្យក្លាយជារដ្ឋបាលដែលមានលក្ខណៈជារដ្ឋបាលតំបន់ និងរដ្ឋបាលរាជធានីភ្នំពេញ ឱ្យក្លាយជារដ្ឋបាលដែលមានលក្ខណៈជារដ្ឋបាលទីក្រុងមេត្រូប៉ូលីតែន។

ក្នុងការគ្រប់គ្រងធនធានមនុស្ស អនុក្រឹត្យស្តីពីកំណត់មុខតំណែងវិជ្ជាជីវៈ និងការពិពណ៌នាមុខតំណែងរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌត្រូវបានដាក់ចេញ ដែលជាមូលដ្ឋានសម្រាប់ការរៀបចំបុគ្គលិកនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌឱ្យត្រូវតាមជំនាញវិជ្ជាជីវៈ ស្របតាមតម្រូវការជាក់ស្តែងរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌនីមួយៗ។ ទន្ទឹមនេះ ផែនការយុទ្ធសាស្ត្រស្តីពីការបង្កើនចំនួនស្ត្រីក្នុងមុខតំណែងគ្រប់គ្រងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ (២០២៤-២០២៨) ក៏ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត។

រដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសប្រធាន គ.ក.ស.ក. អភិបាលរងជាស្ត្រី និងប្រធានមន្ទីរកិច្ចការនារីកំពុងដើរតួយ៉ាងសំខាន់ក្នុងការផ្តល់មតិយោបល់ដល់ក្រុមប្រឹក្សា និងគណៈអភិបាលក្នុងការតែងតាំង និងផ្លាស់ប្តូរបុគ្គលិកនានា។ រដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសរដ្ឋបាលរាជធានី ខេត្តបានរៀបចំ និងអនុវត្តសកម្មភាពអភិវឌ្ឍសមត្ថភាពជាប្រចាំដល់បុគ្គលិករបស់ខ្លួន។ នៅថ្នាក់ជាតិ សាលាជាតិរដ្ឋបាលមូលដ្ឋានបាននិងកំពុងបំពេញតួនាទីយ៉ាងសំខាន់ក្នុងការសម្របសម្រួល និងផ្តល់វគ្គបណ្តុះបណ្តាលនានាដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការអនុវត្តតួនាទី ភារកិច្ចរបស់ខ្លួន និងការអនុវត្តមុខងារនានាដែលបានផ្ទេរពីក្រសួង ស្ថាប័នទៅឱ្យរដ្ឋបាលរាជធានី ខេត្ត និងរដ្ឋបាលក្រុង ស្រុក ខណ្ឌ។

ក្នុងគោលបំណងលើកកម្ពស់ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាននៅថ្នាក់ក្រោមជាតិ រាជរដ្ឋាភិបាលបានបង្កើនការវិភាជ និងផ្ទេរថវិការដ្ឋជូនរដ្ឋបាលថ្នាក់ក្រោមជាតិជាប្រចាំ។ ជាក់ស្តែង មូលនិធិក្រុង ស្រុកមានការកើនឡើងពី**១,៣%** ដល់**១,៦%** នៃចំណូលចរន្តថវិកាជាតិ និងមូលនិធិឃុំ សង្កាត់កើនឡើងពី**៣,២%** ដល់**៣,៥%** នៃចំណូលចរន្តថវិកាជាតិពីឆ្នាំ២០២១ ដល់ឆ្នាំ២០២៨។ ជាមធ្យម រដ្ឋបាលឃុំ សង្កាត់មានមូលនិធិអភិវឌ្ឍន៍ចំនួន **១១០.០០០ដុល្លារអាមេរិក**ក្នុងមួយឆ្នាំ និងរដ្ឋបាលក្រុង ស្រុកមានមូលនិធិអភិវឌ្ឍន៍ចំនួន **២៧០.០០០ដុល្លារអាមេរិក**ក្នុងមួយឆ្នាំ ចាប់ពីឆ្នាំ២០២៤-២០២៨។ ជាមួយនឹងមូលនិធិនេះ រដ្ឋបាលថ្នាក់ក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់បានអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច និងគម្រោងសេវាសង្គមចំនួនប្រមាណ **៣.០០០គម្រោង**ក្នុងមួយឆ្នាំ ដើម្បីឆ្លើយតបនឹងតម្រូវការរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន។ ទន្ទឹមនេះ រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់បាននិងកំពុងផ្តល់សេវារដ្ឋបាលតាមយន្តការច្រកចេញចូលតែមួយចំនួនប្រមាណជាង **៨០០ប្រភេទសេវា** យ៉ាងសកម្មប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគុណភាពហើយទទួលបានការពេញចិត្តយ៉ាងខ្លាំងពីប្រជាពលរដ្ឋ៕

**លេខាធិការដ្ឋាន គ.ជ.អ.ប.** ស្ថិតក្នុងបរិវេណក្រសួងមហាផ្ទៃ

អគារ (V) មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ

អ៊ីម៉ែល: info@ncdd.gov.kh

គេហទំព័រ: www.ncdd.gov.kh

ទំព័រហ្វេសប៊ុក: www.facebook.com/ncdds

**គាំទ្រដោយ៖**

From the People of Japan

UNDP